# មាតិកា

## I~ ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ

២៨-៦-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៦១៦/៦៧៨ ស្តីពី ការអនុញ្ញាតឱ្យលះបង់សញ្ជាតិខ្មែរ ដោយគ្មានការបង្ខិតបង្ខំ ដល់លោក **ខិន សុខេង** (KHIN SOKHENG) ជនជាតិខ្មែរ សញ្ជាតិខ្មែរ បច្ចុប្បន្នកំពុងរស់នៅប្រទេសហូឡង់ ៦១៦៩

២៨-៦-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៦១៦/៦៧៩ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ទៀន ព្រាយយ៉ាន់យន់** (TIEN BRYAN YUAN) ជនជាតិម៉ាឡេស៊ី សញ្ជាតិម៉ាឡេស៊ី ៦១៧០

២៨-៦-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៦១៦/៦៨០ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់កញ្ញា **គួន មុីសៀង** (KUAN MEE SIANG) ជនជាតិម៉ាឡេស៊ី សញ្ជាតិម៉ាឡេស៊ី ៦១៧១

២៨-៦-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៦១៦/៦៨១ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ហឺ ហ្សឺប៊ីន** (HE ZEBIN) ជនជាតិចិន សញ្ជាតិចិន ដោយប្តូរឈ្មោះជា **លី រតនា** (LI ROTHANA) ៦១៧២

២៩-៦-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៦១៦/៦៨២ ស្តីពី ការតែងតាំងអ្នកអង្គ **ស៊ីសុវត្ថិ ឫទ្ធីរ៉ាវង្ស** ជាឯកអគ្គរាជទូតអមព្រះរាជលេខាធិការដ្ឋាន ព្រះមហាក្សត្រ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ៦១៧៣

២៩-៦-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៦១៦/៦៨៣ ស្តីពី ការផ្ទេរ និងតែងតាំងមុខតំណែងព្រះរាជអាជ្ញា ចំនួន ០២ រូប ៦១៧៤

២៩-៦-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៦១៦/៦៨៤ ស្តីពី ការលើកលែងទោសឱ្យទណ្ឌិតឈ្មោះ Marret Frank Christophe Henri ភេទ ប្រុស អាយុ ៤៧ ឆ្នាំ ជនជាតិបារាំង ៦១៧៥

២៩-៦-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៦១៦/៦៨៥ ស្តីពី ការតែងតាំងឯកឧត្តម **ប៉ូច ប៊ុណ្ណាក់** ជាអនុរដ្ឋលេខាធិការ ក្រសួងផែនការ ៦១៧៦

២៩-៦-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៦១៦/៦៨៦ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ឧត្តមសេនីយ៍ត្រី ដល់នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ចំនួន ០២ រូប ៦១៧៧

| | | |
|---|---|---|
| ២៩-៦-២០១៦ | -ព្រះរាជក្រឹត្យ នស/រកត/០៦១៦/៦៨៧ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ជូននាយនគរបាល ថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ចំនួន ០៥ រូប | ៦១៧៨ |
| ២៩-៦-២០១៦ | -ព្រះរាជក្រឹត្យ នស/រកត/០៦១៦/៦៨៨ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់អ្នកស្រី **មៀង សឿនលី** (MYEONG SEON LEE) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ ដោយសុំប្តូរឈ្មោះជា **សាន់ នី** (SUN NY) | ៦១៧៩ |
| ២៩-៦-២០១៦ | -ព្រះរាជក្រឹត្យ នស/រកត/០៦១៦/៦៨៩ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម លោកជំទាវ និងអស់លោក ចំនួន ១១ រូប | ៦១៨០ |
| ២៩-៦-២០១៦ | -ព្រះរាជក្រឹត្យ នស/រកត/០៦១៦/៦៩០ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ ប្រគេន ព្រះតេជគុណ **គង់ វិច្ឆិកា** | ៦១៨១ |
| ២៩-៦-២០១៦ | -ព្រះរាជក្រឹត្យ នស/រកត/០៦១៦/៦៩១ ស្តីពី ការប្រោសព្រះរាជទាន ជាកិច្ចបច្ឆាមរណៈ នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ សពឯកឧត្តម **ញ៉ារ៉ាង ចាន់** | ៦១៨២ |
| ២៩-៦-២០១៦ | -ព្រះរាជក្រឹត្យ នស/រកត/០៦១៦/៦៩២ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម លោកជំទាវ អស់លោក និងលោកស្រី ចំនួន ៦៨ រូប | ៦១៨៣ |


## II-រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ


| | | |
|---|---|---|
| ០៥-៧-២០១៦ | -អនុក្រឹត្យលេខ ១៣៤ អនក្រ.បក ស្តីពី មន្ត្រីអគ្រានុកូលដ្ឋានថ្នាក់ជាតិ | ៦១៨៥ |
| ១១-៧-២០១៦ | -អនុក្រឹត្យលេខ ១៣៩ អនក្រ.បក ស្តីពី ការគ្រប់គ្រងថវិកា និងទ្រព្យសម្បត្តិរដ្ឋ នៃគ្រឹះស្ថានសាធារណៈរដ្ឋបាល | ៦១៨៨ |
| ១២-៧-២០១៦ | -អនុក្រឹត្យលេខ ១៤០ អនក្រ.បក ស្តីពី ឯកសណ្ឋានសញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចការងារ | ៦២០២ |
| ២៥-៥-២០១៦ | -អនុក្រឹត្យលេខ ៥៨៣ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ | ៦២៣៥ |
| ០៤-៧-២០១៦ | -អនុក្រឹត្យលេខ ៧៥២ អនក្រ.តត ស្តីពី ការជូនមេដាយ | ៦២៣៦ |
| ០៤-៧-២០១៦ | -អនុក្រឹត្យលេខ ៧៥៣ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា | ៦២៣៧ |
| ០៤-៧-២០១៦ | -អនុក្រឹត្យលេខ ៧៥៤ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា ជាកិច្ចបច្ឆាមរណៈ | ៦២៣៨ |

០៤-៧-២០១៦ -អនុក្រឹត្យលេខ ៧៥៥ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា ៦២៣៩

០៤-៧-២០១៦ -អនុក្រឹត្យលេខ ៧៥៦ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា ជាកិច្ចបច្ឆាមរណៈ ៦២៤០

០៤-៧-២០១៦ -អនុក្រឹត្យលេខ ៧៥៧ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៦២៤១

០៤-៧-២០១៦ -អនុក្រឹត្យលេខ ៧៥៨ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៦២៤២

០៤-៧-២០១៦ -អនុក្រឹត្យលេខ ៧៥៩ អនក្រ.តត ស្តីពី ការតែងតាំងមុខងារ នាយទាហាន ៦២៤៣

០៥-៧-២០១៦ -អនុក្រឹត្យលេខ ៧៦០ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា ៦២៤៤

០៥-៧-២០១៦ -អនុក្រឹត្យលេខ ៧៦១ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៦២៤៥

០៥-៧-២០១៦ -អនុក្រឹត្យលេខ ៧៦២ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា ៦២៤៦

០៥-៧-២០១៦ -អនុក្រឹត្យលេខ ៧៦៣ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា ៦២៤៧

០៥-៧-២០១៦ -អនុក្រឹត្យលេខ ៧៦៤ អនក្រ.តត ស្តីពី ការផ្ទេរបញ្ចូលទៅក្នុងឋានន្តរស័ក្តិនាយក្រមការ នៃក្របខ័ណ្ឌមន្ត្រីក្រមការ ក្រសួងមហាផ្ទៃ ៦២៤៨

## ២-សេចក្តីសម្រេច

០៨-៧-២០១៦ - សេចក្តីសម្រេចលេខ ៦៣ សសរ ស្តីពី ការជ្រើសរើសពលទាហាន ៦២៥០

១១-៧-២០១៦ -សេចក្តីសម្រេចលេខ ៦៤ សសរ ស្តីពី ការបង្កើតគណៈកម្មាធិការសម្របសម្រួល អនុវត្តនីកាតព្វកិច្ចក្រោមក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក និងរៀបចំឯកសារសម្រាប់ត្រួតពិនិត្យគោលនយោបាយពាណិជ្ជកម្មកម្ពុជា ៦២៥១

១១-៧-២០១៦ -សេចក្តីសម្រេចលេខ ៦៥ សសរ ស្តីពី ការកែសម្រួលសមាសភាពគណៈកម្មការអន្តរក្រសួងដើម្បីរៀបចំ និងចូលរួមពិព័រណ៍ពិភពលោក និងពិព័រណ៍ពាណិជ្ជកម្មអន្តរជាតិ ៦២៥៥

## III-ការងារបណ្តាក្រសួង

## ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

០៦-៦-២០១៦ -ប្រកាសរួមលេខ ៦៥៧ សហវ.ប្រក ស្តីពី ការផ្តល់សេវាសាធារណៈរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ៦២៥៨

០៦-៦-២០១៦ -ប្រកាសរួមលេខ ៦៥៨ សហវ.ប្រក ស្តីពី ការផ្តល់រង្វាន់លើកទឹកចិត្តលើការផ្តល់សេវាសាធារណៈរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ៦២៧៨

១៧-៥-២០១៦ -ប្រកាសអន្តរក្រសួងលេខ ៦០៦ សហវ.ប្រក ស្តីពី ការបង្កើតរង្វាន់ទេយ្យបុរេប្រទានសម្រាប់ឆ្នាំ ២០១៦ របស់អគ្គនាយកដ្ឋានកីឡា ៦២៨៤

នស/រកត/០៦១៦/៦៧៨

# ព្រះរាជក្រឹត្យ

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានតូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសញ្ជាតិ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** អនុញ្ញាតឱ្យលះបង់សញ្ជាតិខ្មែរ ដោយគ្មានការបម្រិតបង្ខំ ដល់ លោក ខិន សុខេង( KHIN SOKHENG ) ជនជាតិខ្មែរ សញ្ជាតិខ្មែរ កើតនៅថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៨៣ ទីកន្លែងកំណើត ភូមិចំការហ្លួង ឃុំវាំងចាស់ ស្រុកឧត្តុង្គ ខេត្តកំពង់ស្ពឺ បច្ចុប្បន្នកំពុងរស់នៅប្រទេសហូឡង់។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧-១៦០៦-៦៩៥

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦*

លេខ: ៦៦៤ ស.ណ

**សំណៅចែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៦/៦៩៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានត្តមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ទៀន ប្រ៊ីយ៉ាន់យន់** (TIEN BRYAN YUAN) ជនជាតិម៉ាឡេស៊ី សញ្ជាតិម៉ាឡេស៊ី កើតថ្ងៃទី០៣ ខែមិថុនា ឆ្នាំ១៩៨៥ នៅរដ្ឋធានីគូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧.១៦០៦.៦៩៦

លេខៈ ៦៦៥ ស.ណ
**សំណៅចែលមានតម្លៃជាការចែកផ្សាយ**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦*

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ៦ ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៦/៦៩០

**យើង**

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ១០៩៦ / ៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីសញ្ជាតិ
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយ របស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១** : ផ្ដល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់កញ្ញា **គួន ម៉ីសៀង** (KUAN MEE SIANG) ជនជាតិម៉ាឡេស៊ី សញ្ជាតិម៉ាឡេស៊ី កើតថ្ងៃទី២២ ខែឧសភា ឆ្នាំ១៩៧៣ នៅក្រុងជហ័រ ប្រទេសម៉ាឡេស៊ី។

**មាត្រា ២** : សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ដលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧៧.១៦០៦.៦៩៧

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦*

លេខៈ ៦៦៦ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៦/៦៧១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានតូមិជាតិសាសនា រក្ខតខត្តិយា ខេមរាដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ១០៩៦ / ៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ហឺ ហ្សឺប៊ីន** (HE ZEBIN) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី១៨ ខែមិថុនា ឆ្នាំ១៩៨៨ នៅខេត្តក្វាងទុង សាធារណរដ្ឋប្រជាមានិតចិន ដោយប្តូរឈ្មោះជា **លី រតនា** (LI ROTHANA)។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរល. ១៦០៦.៦៧៧

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦*

លេខ: ៦៦៤ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៦/៦៧២

**យើង**

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្មូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ត្រាស់បង្គាប់**

**តែងតាំង:**

អ្នកអង្គ **ស៊ីសុវត្ថិ ឫទ្ធីរ៉ាវង្ស**

**ជា**

**ឯកអគ្គរាជទូតអមព្រះរាជលេខាធិការដ្ឋាន ព្រះមហាក្សត្រ**
មានឋានៈស្មើ **អនុរដ្ឋលេខាធិការ**

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

តរល. ១៦០៦. ៦៧៩
**បានប្រទាប់ព្រះរាជលញ្ឆករហើយ**
*ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦*

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
លេខ: ...១៤៩...៥៦... រវ. ចច
រាជធានីភ្នំពេញ, ថ្ងៃទី ...០៦... ខែ ...កក្កដា... ឆ្នាំ ...២០១៦
សម្ដេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីឧរ្ការ គង់ សំអុល
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

នស/រកត/០៦១៦/៦៨៣

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៧ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំអង្គការតុលាការ
-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

**ត្រាស់បង្គាប់**

**មាត្រា១:** ផ្ទេរ និងតែងតាំងមុខតំណែងព្រះរាជអាជ្ញា ចំនួន ០២រូប:

១-ផ្ទេរលោក **ផាន់ វណ្ណារ័ត្ន** ពីព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ ឲ្យមកបំពេញការងារនៅក្រសួងយុត្តិធម៌។

២-ផ្ទេរ និងតែងតាំងលោក **មាស ច័ន្ទពិសិដ្ឋ** ពីព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ មកជាព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ។

**មាត្រា២:** ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខ: ៦៦៧ ស.ណ
**សំណៅចែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

៣រម. ១៦០៦.៦៩០

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦*

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៦/៦៨៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១១/០២១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីពន្ធនាគារ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានលើកលែងទោសឲ្យទណ្ឌិតឈ្មោះ Marret Frank Christophe Henri ភេទ ប្រុស អាយុ ៤៧ឆ្នាំ ជនជាតិបារាំង ដែលត្រូវបានតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់រយៈពេល ០១ ឆ្នាំ ០៦ ខែ ពីបទ អំពើលួច តាមអំណាចសាលក្រមលេខ ១៧២៤ "យ" ក.ព.ព្រ.ទ ចុះថ្ងៃទី ២៧-០៨-២០១៥ របស់សាលាដំបូងរាជធានីភ្នំពេញ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចតាមព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧៧. ១៦០៦. ៦៩១

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦*

លេខ:៦៨៥ ស.ណ
**សំណៅចម្លងដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែកក្កដា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៦/៦៩៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តែងតាំងឯកឧត្តម **ប៉ូច ប៊ុណ្ណាក់** ជាអនុរដ្ឋលេខាធិការ ក្រសួងផែនការ ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរស.១៦០៦.៦៩៤

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦*

លេខ: ៦៩៣ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែកក្កដា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៦/៦៨៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១** : តម្លើងឋានន្តរសក្តិ **ឧត្តមសេនីយ៍ត្រី** ដល់នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៖

១-វរសេនីយ៍ឯក **ឈឹម ថន** អត្តលេខ ០៩១៦

២-វរសេនីយ៍ឯក **ហាច ចាន់សិទ្ធី** អត្តលេខ ០៦៦៧៨ ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៤៨. ១៦០៦. ៦៨៣

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦*

លេខៈ ៦៨២ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែកក្កដា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

នស/រកត/០៦១៦/៦៨៧

# ព្រះរាជក្រឹត្យ

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តម្លើងឋានន្តរស័ក្តិ ជូននាយនគរបាល ថ្នាក់ឧត្តមសេនីយ៍ ក្របខណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ចំនួន ០៥ រូបៈ

**ក- ឋានន្តរស័ក្តិ ឧត្តមសេនីយ៍ឯក**

១- ឧត្តមសេនីយ៍ទោ **បេង សុវត្ថិ** អត្តលេខ ០១៦៨៧
២- ឧត្តមសេនីយ៍ទោ **ឃៀង សុគន្ធា** អត្តលេខ ០៧០៦៦
៣- ឧត្តមសេនីយ៍ទោ **ព្រហ្ម ចាន់សុខា** អត្តលេខ ០៧០៦៨ ។

**ខ- ឋានន្តរស័ក្តិ ឧត្តមសេនីយ៍ទោ**

១- ឧត្តមសេនីយ៍ត្រី **អ៊ឹម ស៊ីយុត** អត្តលេខ ០៨៨៤
២- ឧត្តមសេនីយ៍ត្រី **ហែម សារិ** អត្តលេខ ០១៨៨៩ ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខៈ ៦៧៩ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែកក្កដា ឆ្នាំ២០១៦
អគ្គលេខាធិការរាជរដ្ឋាភិបាល

ការ៧.១៦០៦.៦៩៤

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៦/ ៦៧៨

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ១០៩៦ / ៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១** : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់អ្នកស្រី **មៀង សឿនលី** (MYEONG SEON LEE) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតថ្ងៃទី២៤ ខែឧសភា ឆ្នាំ១៩៥៩ នៅទីក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ ដោយសុំប្តូរឈ្មោះជា **សាន់ នី** (SUN NY)។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧. ១៦០៦. ៦៩៥

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៦

លេខៈ ៦៨៧ ស.ណ
**សំណៅចម្លងចេញពីច្បាប់ដើម សម្រាប់ផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៦/៦៧៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពុហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

**ប្រោសព្រះរាជទាន**

នូវ

**ក-គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍:**

១- លោកជំទាវ **កោ សុផានី សុ ជុងហ្សូរ**
២- លោកជំទាវ **ទ៉ូច ម៉ីចលួង**
៣- លោក **ឯម ភាព**

**ខ-គ្រឿងឥស្សរិយយសសម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិ មុនីវង្សកុសុមៈនារីរ័ត្ន ថ្នាក់ មហាសេរីវឌ្ឍន៍:**

១- លោក **ស៊ីង សារិន**
២- លោក **ឃួន សុខន**
៣- លោក **ប៉ែន សំបូរ**
៤- លោក **គីម ស៊ីថា**

**គ-គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា:**

១- ឯកឧត្តម **ធីង គីមហេង**
២- លោក **ចន្ទ សាមិត្ត**
៣- លោក **ចន្ទ លី**

**ឃ-គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា:**

- លោក **សេង ហាន**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧.១៦០៦.៦៩៦

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦

លេខៈ ៦៧៩ ស.ណ
**សំណៅដែលមានគំរូមេចារការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែកក្កដា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៦/៦៩០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា )

**ប្រោសព្រះរាជទាន**

**នូវ**

**គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់  មហាសេរីវឌ្ឍន៍**

ប្រគេន

ព្រះតេជគុណ **គង់  វិច្ឆិកា**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរជ. ១៦០៦.៦៩៧

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៦

លេខៈ ៦៥៧ ស.ណ
**សំណៅចំលងមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែកក្កដា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៦/៦៩១

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

ប្រោសព្រះរាជទាន

ជាកិត្តិយសបច្ឆាមរណៈ

នូវ

**គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍**

ចំពោះ

សពឯកឧត្តម **ញ៉ាភ៊ង ចាន់**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧.១៦០៦.៦៩៨

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦*

លេខៈ ៦៩០ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ .ថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៦/៦៩៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា )

## ប្រោសព្រះរាជទាន

**ក-គ្រឿងឥស្សរិយយស ជាតូបការ :**

| | |
|---|---|
| ១-ឯកឧត្តម **យក់ ម៉ិនណា** | ២-លោកជំទាវ **ខ៊ាន់ ម៉ារា** |
| ៣-ឯកឧត្តម **ម៉ុល ពីឌូ** | ៤-ឯកឧត្តម **ឈឿន ម៉ុណារ័ត្ន** |
| ៥-ឯកឧត្តម **ចាន់ វណ្ណី** | |

**ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :**

| | |
|---|---|
| ១-លោកជំទាវ **សៅ សុគន្ធារី** | ២-ឯកឧត្តម **ប្រាក់ វីរ៉ា** |
| ៣-ឯកឧត្តម **ហង្ស សាំឆាន** | ៤-លោកជំទាវ **ឈី វិជ្ជរ៉ា** |
| ៥-លោកជំទាវ **ហូ សុវណ្ណិកា** | ៦-ឯកឧត្តម **អុល រ៉ូ** |
| ៧-ឯកឧត្តម **គង់ សុគី** | ៨-ឯកឧត្តម **ពេជ្រ វិជ្ជាគន្ធី** |
| ៩-ឯកឧត្តម **រឿន រដ្ឋា** | ១០-ឯកឧត្តម **ស សាម៉ុឌី** |
| ១១-លោកស្រី **ឆាយ គីមសុទ្ធី** | ១២-លោក **អ៊ុក សុភាព** |
| ១៣-លោកស្រី **អ៊ុក ទូច** | ១៤-លោក **នូ សុវណ្ណារ៉ា** |
| ១៥-លោក **ឫទ្ធី សុគន្ធារិទ្ធ** | ១៦-លោកស្រី **ពេជ សុរិយា** |
| ១៧-លោកស្រី **ថោ សេដ្ឋចាន់លីដា** | ១៨-លោក **ខៀវ ម៉ុន្លា** |
| ១៩-លោកស្រី **ហ៊ល សាធាលីន** | ២០-លោក **រស់ សុភ័ក្ត** |

**គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :**

| | |
|---|---|
| ១-លោកជំទាវ **នាង លីណា** | ២-ឯកឧត្តម **ឆាយ ឆត្រាធុច** |
| ៣-លោក **អ៊ុយ ភារក្ស** | ៤-លោក **មាស ពេជ្រ** |
| ៥-លោក **ប្រាក់ ម៉ូវ** | ៦-លោកស្រី **ស្រី សន្ធា** |
| ៧-លោកស្រី **ពេជ្រម៉ុនធិន បុប្ផាច័ន្ទ** | ៨-លោក **ស៊ិន សុឃន** |
| ៩-លោក **សុខ សំអាត** | ១០-លោកស្រី **អ៊ុង ចាន់ធី** |
| ១១-លោក **ម៉ែន ពិសិដ្ឋ** | ១២-លោក **អេង សុធីរៈ** |
| ១៣-លោក **ហុក វិចិត្រ** | ១៤-លោកស្រី **ថោ សេដ្ឋាមុនី** |

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

**ឃ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មិបឌិន្ទ :**

| | |
|---|---|
| ១-ឯកឧត្តម **ស៊ុង មិនមិ** | ២-ឯកឧត្តម **សួន វ៉ានី** |
| ៣-លោក **សិក ហេងឡុង** | ៤-លោក **មិន សុផ័ក** |
| ៥-លោក **លី សុគន្ធីរ៉ា** | ៦-លោក **ប្រាក់ កុសុមស៊ុនដេត** |

**ង-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា :**

| | |
|---|---|
| ១-លោក **ទេព កុសល** | ២-លោក **ស្រ៊ាង ផានិត** |
| ៣-លោកស្រី **ផ្លែក រីណែត** | ៤-លោក **ម៉េង ម៉ង់មិត** |
| ៥-លោក **ឡុង សារឿន** | ៦-លោក **តាន់ បេងលាង** |
| ៧-លោក **ឆន់ ប៊ុនធឿន** | ៨-លោក **ប្រាក់ ប្រានីដ្ឋា** |
| ៩-លោក **សយ រាសី** | ១០-លោក **ស្វាយ សំណាង** |
| ១១-លោកស្រី **យ៉េម សុគន្ធារី** | ១២-លោក **សយ មិសាល** |
| ១៣-លោកស្រី **សំ សុតា** | ១៤-លោកស្រី **ណុប ចន្ថា** |
| ១៥-លោកស្រី **ឃិន ស័យយ៉ាណា** | ១៦-លោក **សូ ទ៉ាង** |
| ១៧-លោក **ប៉ុន គីណារ៉ា** | ១៨-លោក **យ៉ង់ មណីរ័ត្ន** |

**ច-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ :**

| | |
|---|---|
| ១-លោក **សួន ដាថា** | ២-លោក **សារអាត ចន្ទ្យនា** |
| ៣-លោក **ខៀវ សត្យា** | ៤-លោក **ហ៊ាន ញូញឹម** |
| ៥-លោក **ឯក ទាសនា** | |

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស/រកត.០៦១៦.៥៨៩

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៦*

លេខៈ ៦៨៦ ស.ណ

**សំណៅចម្លងចេញពីច្បាប់ដើម**

រាជធានីភ្នំពេញ .ថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០១៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

សយ សុខា

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ  សាសនា  ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៣៤ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១០៩អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១០៣អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពីអត្រានុកូលដ្ឋាន
- បានឃើញអនុក្រឹត្យលេខ៦០អនក្រ.បក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០២ ស្តីពីការកែសម្រួលមាត្រា៨និងមាត្រា៥៩នៃអនុក្រឹត្យលេខ១០៣អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពីអត្រានុកូលដ្ឋាន
- បានឃើញអនុក្រឹត្យលេខ១៧អនក្រ.បក ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០០៤ ស្តីពីការកែសម្រួលអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន
- បានឃើញអនុក្រឹត្យលេខ១៨៣អនក្រ.បក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកំណត់បែបបទនិងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរនិងជនបរទេស
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះមានគោលបំណងលើកកម្ពស់ប្រសិទ្ធភាពការគ្រប់គ្រងការងារអត្រានុកូលដ្ឋាននៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២.-**

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣.-**

អនុក្រឹត្យនេះមានវិសាលភាពលើការគ្រប់គ្រងការងារអត្រានុកូលដ្ឋាននៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២
## មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ

**មាត្រា៤.-**

អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ។

**មាត្រា៥.-**

មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិមានភារកិច្ចៈ

- ធានាការអនុវត្តច្បាប់និងបទប្បញ្ញត្តិនានាស្តីពីអត្រានុកូលដ្ឋាន
- ដាក់ចេញនូវគោលការណ៍ សេចក្តីណែនាំ បែបបទនិងនីតិវិធីនានាស្របតាមការកំណត់នៃច្បាប់
- បញ្ជានិងណែនាំដល់មន្ត្រីអត្រានុកូលដ្ឋានលើការអនុវត្តការងារអត្រានុកូលដ្ឋាន
- រាយការណ៍ពីការរំលោភបទប្បញ្ញត្តិច្បាប់ដែលប្រព្រឹត្តដោយមន្ត្រីអត្រានុកូលដ្ឋានទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃដើម្បីចាត់វិធានការដាក់វិន័យតាមច្បាប់
- ពិនិត្យសម្រេចនិងអនុញ្ញាតឱ្យកែតម្រូវទិន្នន័យអត្រានុកូលដ្ឋានឬអនុញ្ញាតឱ្យចុះបញ្ជីអត្រានុកូលដ្ឋានឡើងវិញស្របតាមបទប្បញ្ញត្តិនៃច្បាប់
- ពិនិត្យសម្រេចមោឃភាពបញ្ជីអត្រានុកូលដ្ឋានគ្រប់ប្រភេទដែលបានអនុវត្តមិនស្របតាមនីតិវិធីនៃការចុះបញ្ជីអត្រានុកូលដ្ឋាន
- ពិនិត្យសម្រេចលើការចុះបញ្ជីអត្រានុកូលដ្ឋានក្នុងករណីមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ក្រោមជាតិមិនអាចសម្រេចបាន
- ដាក់ឱ្យប្រើប្រាស់សៀវភៅអត្រានុកូលដ្ឋានតាមឆ្នាំនីមួយៗជាផ្លូវការ
- ចេញសេចក្តីចម្លងនិងសម្រង់អត្រានុកូលដ្ឋានក្នុងករណីមានការស្នើសុំ។

**មាត្រា៦.-**

បែបបទនិងនីតិវិធីនៃការកែតម្រូវទិន្នន័យអត្រានុកូលដ្ឋានត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

**មាត្រា៧.-**

កម្រៃសេវារដ្ឋបាលលើការងារអត្រានុកូលដ្ឋាននៅថ្នាក់ជាតិត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៣
## អវសានប្បញ្ញត្តិ

**មាត្រា៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៣៥ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការគ្រប់គ្រងថវិកា និងទ្រព្យសម្បត្តិរដ្ឋ នៃគ្រឹះស្ថានសាធារណៈរដ្ឋបាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត-ក្រុង-ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១៣ អនក្រ.បក ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ ២០១៥ ស្តីពីនីតិវិធីនៃការបង្កើតការរៀបចំ និងប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្ម
- បានឃើញអនុក្រឹត្យលេខ១១៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការតម្លើងនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ ទៅជាអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍, តម្លើងនាយកដ្ឋានសហប្រតិបត្តិការ និងគ្រប់គ្រងបំណុលទៅជាអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល និងបង្កើតនាយកដ្ឋានសវនកម្មបច្ចេកវិទ្យាព័ត៌មានស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះ មានគោលបំណងធានាប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព និងគណនេយ្យភាពក្នុងការគ្រប់គ្រងថវិកានិងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល។

**មាត្រា២.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់វិធាន និងនីតិវិធីគោលនៃការគ្រប់គ្រងថវិកានិងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល។

**មាត្រា៣.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះគ្រឹះស្ថានសាធារណៈរដ្ឋបាលទាំងអស់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២

## ការគ្រប់គ្រងថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល

### ផ្នែកទី១

### ក្របខ័ណ្ឌទូទៅនៃថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល

**មាត្រា៤.-**

**គ្រឹះស្ថានសាធារណៈរដ្ឋបាល** គឺជានីតិបុគ្គលនៃនីតិសាធារណៈ ដែលមានថវិកាស្វយ័ត និងត្រូវឆ្លុះបញ្ចាំងនូវគ្រប់ប្រភពចំណូល និងគ្រប់មុខសញ្ញាចំណាយ ដែលជាឧបសម្ព័ន្ធនៃថវិការបស់ក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេស។ ថវិកានេះ ត្រូវរៀបចំស្របតាមគោលបំណងគោលនយោបាយ ដែលត្រូវបានកំណត់ដោយក្រសួងស្ថាប័នអាណាព្យាបាលបច្ចេកទេស និងដោយផ្អែកលើសារាចរណែនាំស្តីពីការរៀបចំថវិកាប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាល និងស្របតាមផែនការយុទ្ធសាស្ត្រថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល។

**អាណាប័កដើមខ្សែ** នៃថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល គឺជាអាណាព្យាបាលបច្ចេកទេស។

**អាណាប័កផ្ទេរសិទ្ធិ** នៃថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល គឺជានាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល។

**ថវិកាស្វយ័តរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល** សំដៅដល់ថវិកាដែលកញ្ចប់ចំណូល ចំណាយត្រូវបានអនុញ្ញាតឱ្យរៀបចំជាឧបសម្ព័ន្ធនៃថវិកាក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេស និងដោយមានការប្រគល់សិទ្ធិ

អំណាច និងការទទួលខុសត្រូវក្នុងកម្រិតកំណត់មួយ ដោយលិខិតបទដ្ឋានពាក់ព័ន្ធក្នុងការគ្រប់គ្រង និងចាត់ចែងអនុវត្ត។

គ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលស្ថិតនៅក្រោមក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេស ដែលអនុវត្តថវិកាកម្មវិធី ត្រូវរៀបចំ និងអនុវត្តថវិកាឱ្យស្របតាមគោលការណ៍ និងការណែនាំអំពីថវិកាកម្មវិធី។

## ជំពូកទី២
## ការរៀបចំថវិកា

**មាត្រា៥.–**

ថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល គឺជាផែនការចំណូលចំណាយ ដែលទទួលបានការអនុម័តប្រចាំឆ្នាំនីមួយៗរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលនោះ។

**មាត្រា៦.–**

ថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវមានតុល្យភាពរវាងចំណូល និងចំណាយ។

ចំណូល និងចំណាយរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលនីមួយៗ ត្រូវគ្រោងក្នុងថវិកាប្រចាំឆ្នាំរបស់ខ្លួន។

ចំណូល និងចំណាយរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវគោរពតាមវិធាននៃចំណាត់ថ្នាក់ និងការគ្រប់គ្រងដូចថវិការដ្ឋ។ ចំពោះថវិកាដែលផ្តល់ហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ ត្រូវគោរពតាមវិធាននៃកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល និងដៃគូពាក់ព័ន្ធ។

ចំណូលរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល រួមមានចំណូលផ្ទាល់ ការឧបត្ថម្ភពីថវិការដ្ឋ និងចំណូលផ្សេងៗទៀត។

ចំណាយ ត្រូវឆ្លុះបញ្ចាំងនូវគ្រប់មុខសញ្ញានៃការប្រើប្រាស់ពីគ្រប់ប្រភពឥណទាន។

គ្រឹះស្ថានសាធារណៈរដ្ឋបាល មិនអាចបង្កើតលក្ខខណ្ឌ ដែលនាំឱ្យមានឱនភាពថវិកាឡើយ ក្នុងអំឡុងពេលនៃការអនុវត្តថវិកាប្រចាំឆ្នាំ លើកលែងតែមានការយល់ព្រមពីក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេស និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៧.–**

ដំណាក់កាលនៃការរៀបចំថវិកាប្រចាំឆ្នាំរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវអនុលោមតាមប្រតិទិននៃការរៀបចំថវិកាប្រចាំឆ្នាំ ដូចខាងក្រោម÷

- នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវចូលរួមរៀបចំផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេស ដោយផ្អែកលើមូលដ្ឋានសារាចរណែនាំរបស់រាជរដ្ឋាភិបាល ស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា
- នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំគម្រោងចំណូល ចំណាយថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលឱ្យបានលម្អិត និងគ្រប់ជ្រុងជ្រោយ ដោយផ្អែកលើមូលដ្ឋានសារាចរណែនាំរបស់រាជរដ្ឋាភិបាលស្តីពីបច្ចេកទេសនៃការរៀបចំគម្រោងថវិកា ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងអនុម័ត រួចបញ្ជូនទៅក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេសពិនិត្យ និងសម្រេចមុនថ្ងៃទី០១ ខែកក្កដា
- យ៉ាងយឺតបំផុតត្រឹមថ្ងៃទី១៥ ខែកក្កដា គម្រោងចំណូល ចំណាយថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវផ្ញើជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេស
- ក្នុងអំឡុងខែកក្កដា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អញ្ជើញតំណាងក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេស និងនាយកគ្រប់គ្រឹះស្ថានសាធារណៈរដ្ឋបាល មកពិភាក្សាកម្រិតជំនាញបច្ចេកទេសដើម្បីការពារគម្រោងថវិការបស់ខ្លួន។ ក្នុងអំឡុងពេលនៃកិច្ចពិភាក្សានេះ ត្រូវរំលេចឱ្យឃើញអំពីអតិរេក ឬឱនភាពនៃថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងសំណើឧបត្ថម្ភធនពីថវិការដ្ឋ
- ក្នុងអំឡុងខែសីហា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អញ្ជើញតំណាងក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេស និងនាយកគ្រប់គ្រឹះស្ថានសាធារណៈរដ្ឋបាល មកពិភាក្សាកម្រិតថ្នាក់ដឹកនាំស្របតាមបទប្បញ្ញត្តិជាធរមាន
- នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរាយការណ៍ជូនក្រុមប្រឹក្សាភិបាលអំពីលទ្ធផលនៃការពិភាក្សាគម្រោងថវិកា រួចត្រូវចាត់ចែងរៀបចំកែសម្រួលគម្រោងថវិកាប្រចាំឆ្នាំរបស់ខ្លួនឡើងវិញស្របតាមលទ្ធផលដែលបានពិភាក្សាខាងលើ រួចត្រូវផ្ញើជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេសយ៉ាងយូរត្រឹមដំណាច់ខែវិច្ឆិកា។ គម្រោងថវិកានេះនឹងត្រូវកែសម្រួលបន្ថែមទៀតតាមការចាំបាច់ ក្នុងករណីដែលខ្លឹមសារនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំដែលត្រូវបានអនុម័ត មានការផ្លាស់ប្តូរពាក់ព័ន្ធនឹងឧបត្ថម្ភធនដល់គ្រឹះស្ថានសាធារណៈរដ្ឋបាល
- បន្ទាប់ពីច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំត្រូវបានអនុម័ត ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចេញប្រកាសដាក់ឱ្យអនុវត្តថវិកាគ្រឹះស្ថានសាធារណៈរដ្ឋបាល។

**មាត្រា៨.-**

ក្នុងករណីដែលអាណាព្យាបាលបច្ចេកទេសជំទាស់លើគម្រោងថវិកាប្រចាំឆ្នាំ របស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេស ត្រូវផ្ញើជូនសេចក្តីជំទាស់នេះទៅនាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល ដើម្បីពិនិត្យ ផ្តល់ការបំភ្លឺ ឬ/និងកែតម្រូវតាមការចាំបាច់។ កិច្ចដំណើរការនេះ ត្រូវធ្វើឡើងស្របតាមប្រតិទិនការងារដែលមានចែងក្នុងមាត្រា៧។

## ជំពូកទី៣
## ការអនុវត្តថវិកា

**មាត្រា៩.-**

ក្រោយពេលបានទទួលប្រកាស ស្តីពីការបែងចែកឥណទានថវិកាផ្ទៃក្នុងរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវផ្ទេរថវិកាឧបត្ថម្ភធន ដែលជាចំណែករបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល តាមរយៈអាណត្តិបើកប្រាក់ តាមសំណើរបស់នាយកគ្រឹះស្ថាន ចូលគណនីប្រាក់បញ្ញើរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលនៅរតនាគារជាតិក្នុងរយៈពេល១ត្រីមាសម្តង។

អាណាប័កដើមខ្សែ ត្រូវធ្វើប្រកាសប្រគល់សិទ្ធិជាអាណាប័កផ្ទេរសិទ្ធិ ជូននាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល ដើម្បីចាត់ចែងបញ្ជានិងជម្រះចំណាយ និងធ្វើប្រតិបត្តិការចំណាយស្របតាមច្បាប់ និងនីតិវិធីហិរញ្ញវត្ថុជាធរមាន។

**មាត្រា១០.-**

នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល មានសិទ្ធិអំណាច និងទទួលខុសត្រូវលើការបញ្ជា និងជម្រះចំណូល។

គ្រឹះស្ថានសាធារណៈរដ្ឋបាលទាំងអស់ ត្រូវបើកគណនីប្រាក់បញ្ញើនៅរតនាគារជាតិជាចាំបាច់ លើកលែងតែមានបដិប្បញ្ញត្តិ ដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ចំណូលរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវបង់ចូលគណនីប្រាក់បញ្ញើ។ រាល់ការប្រមូល និងបង់ចំណូលចូលគណនីប្រាក់បញ្ញើរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល គណនេយ្យករត្រូវធ្វើការកត់ត្រាចំណូលទៅតាមមាតិកាថវិកា រួចត្រូវរាយការណ៍ជូននាយកគ្រឹះស្ថាន និងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ។

គណនេយ្យករ ត្រូវធ្វើការបូកសរុបចំណូល ដែលគ្រឹះស្ថានសាធារណៈរដ្ឋបាលទទួលបាន និងបានបង់ទៅរតនាគារជាតិ រួចរាយការណ៍ក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល។

**មាត្រា១១.-**

ចំណាយថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ជាកម្មវត្ថុនៃការឆ្លងទិដ្ឋាការពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាលនោះ ដែលបានទទួលការតែងតាំងពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ នីតិវិធីអនុវត្តថវិកាលម្អិត នឹងត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១២.-**

ចំណាយថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលសម្រាប់ការទិញ ការជួសជុល ការសាងសង់ និងការជួលសេវា ត្រូវអនុវត្តតាមវិធីសាស្ត្រ និងនីតិវិធីលទ្ធកម្មសាធារណៈ ដែលត្រូវបានកំណត់ដោយច្បាប់ និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ។

**មាត្រា១៣.-**

ការផ្ទេរឥណទានថវិកាពីជំពូកមួយទៅជំពូកមួយ នៃថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមសំណើរបស់នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោយពីមានការសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងដោយមានការឯកភាពពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល និងអាណាព្យាបាលបច្ចេកទេស។ ប្រកាសផ្ទេរឥណទាននេះ ត្រូវចម្លងជូនក្រសួងស្ថាប័នអាណាព្យាបាលបច្ចេកទេស។

ការផ្ទេរឥណទានថវិកានៅក្នុងជំពូកតែមួយនៃថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវធ្វើឡើងដោយសេចក្តីសម្រេចរបស់នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល ក្រោយទទួលបានការឯកភាពពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុប្រចាំគ្រឹះស្ថាន។ សេចក្តីសម្រេចនេះត្រូវចម្លងជូនក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេស និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ការផ្ទេរឥណទានថវិកាកម្មវិធី សម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវធ្វើឡើងដូចខាងក្រោម÷

- ការផ្ទេរឥណទានថវិកាពីកម្មវិធីមួយ ទៅកម្មវិធីមួយ
  - ពីជំពូកមួយទៅជំពូកមួយ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
  - ក្នុងជំពូកតែមួយ ត្រូវធ្វើឡើងដោយសេចក្តីសម្រេចរបស់នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល ក្រោយទទួលបានការឯកភាពពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុប្រចាំគ្រឹះស្ថាន។ សេចក្តីសម្រេចនេះ ត្រូវចម្លងជូនក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេស និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។
- ការផ្ទេរឥណទានថវិកាពីអនុកម្មវិធីមួយ ទៅអនុកម្មវិធីមួយក្នុងកម្មវិធីតែមួយ
  - ពីជំពូកមួយទៅជំពូកមួយ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- ក្នុងជំពូកតែមួយ ត្រូវធ្វើឡើងដោយសេចក្តីសម្រេចរបស់នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល ក្រោយទទួលបានការឯកភាពពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុប្រចាំគ្រឹះស្ថាន។ សេចក្តីសម្រេចនេះ ត្រូវចម្លងជូនក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេស និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

- ការផ្ទេរឥណទានថវិកាពីចង្កោមសកម្មភាពមួយ ទៅចង្កោមសកម្មភាពមួយក្នុងអនុកម្មវិធីតែមួយ/ឬ នៅផ្ទៃក្នុងចង្កោមសកម្មភាពតែមួយ
  - ពីជំពូកមួយទៅជំពូកមួយ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
  - ក្នុងជំពូកតែមួយ ត្រូវធ្វើឡើងដោយសេចក្តីសម្រេចរបស់នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល ក្រោយទទួលបានការឯកភាពពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុប្រចាំគ្រឹះស្ថាន។ សេចក្តីសម្រេចនេះ ត្រូវចម្លងជូនក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេស និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

រាល់ការផ្ទេរឥណទានថវិកាត្រូវមានមូលដ្ឋាននៃការវិភាគច្បាស់លាស់ ដែលធានាថានឹងមិនធ្វើឱ្យប៉ះពាល់ដល់ប្រសិទ្ធភាពការងារ គោលដៅយុទ្ធសាស្ត្រជាអាទិភាពរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ក៏ដូចជាគោលបំណងគោលនយោបាយរបស់ក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេសដែលបានកំណត់។

**មាត្រា១៤.-**

កិច្ចប្រតិបត្តិការចំណាយថវិកាគ្រឹះស្ថានសាធារណៈរដ្ឋបាលមាន ៤ ដំណាក់កាលសំខាន់ៗ÷

- ដំណាក់កាលធានាចំណាយ
- ដំណាក់កាលលទ្ធកម្មសាធារណៈ
- ដំណាក់កាលជម្រះបញ្ជី
- ដំណាក់កាលអាណត្តិកិច្ច និងទូទាត់។

**មាត្រា១៥.-**

មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាលអាចយល់ព្រម ឬមិនយល់ព្រមផ្តល់ទិដ្ឋាការធានាចំណាយស្របតាមគោលការណ៍ហិរញ្ញវត្ថុដែលមានចែងជាធរមាន។

ទិដ្ឋាការធានាចំណាយរបស់មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវបញ្ជាក់អំពី÷

- កម្មវត្ថុចំណាយដែលស្របតាមមាតិកាថវិកា ក៏ដូចជាស្របតាមគម្រោងថវិកាដែលបានអនុម័ត និងធានាបាននូវប្រសិទ្ធភាពចំណាយ ឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល

- កំណត់ចំនួនទឹកប្រាក់ដែលត្រូវផ្តល់ទិដ្ឋាការចំណាយ

- ភាពទំនេរនៃឥណទាន និងស្ថានភាពប្រាក់បញ្ញើនៅរតនាគារជាតិ ដើម្បីជាមូលដ្ឋានពិចារណាលទ្ធភាពដែលអាចទូទាត់បាន។

**មាត្រា១៦.-**

នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវទទួលខុសត្រូវលើកិច្ចជម្រះបញ្ជី។

កិច្ចជម្រះបញ្ជីអាចធ្វើទៅបាន បន្ទាប់ពីការបញ្ជាទិញ កិច្ចសន្យាលទ្ធកម្មទំនិញ សំណង់ ឬសេវានានាត្រូវបានបំពេញរួចរាល់។

**មាត្រា១៧.-**

នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវបោះផ្សាយអាណត្តិបើកប្រាក់ ដោយឆ្លងការត្រួតពិនិត្យហិរញ្ញវត្ថុពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល។

អាណត្តិបើកប្រាក់ ដែលគ្មានទិដ្ឋាការពីអភិបាលហិរញ្ញវត្ថុ ឬមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ គឺពុំអាចប្រើប្រាស់បានសម្រាប់ការទូទាត់ ឬដកប្រាក់ពីគណនីប្រាក់បញ្ញើនៅរតនាគារជាតិបានឡើយ។

រតនាគារជាតិ ត្រូវធ្វើការដកប្រាក់ចេញពីគណនីប្រាក់បញ្ញើរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ជូនគ្រឹះស្ថានសាធារណៈរដ្ឋបាលតាមរូបភាពបង្វែរ ឬមូលប្បទានបត្រ ក្រោយពីទទួលបានសំណើសុំដកប្រាក់ដោយភ្ជាប់ជាមួយអាណត្តិបើកប្រាក់ជាច្បាប់ថតចម្លង។

អាណត្តិបើកប្រាក់ និងសលាកបត្រកត់ត្រាចំណាយថវិកា និងត្រួតពិនិត្យហិរញ្ញវត្ថុសម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំ និងដាក់ឱ្យប្រើប្រាស់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១៨.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គឺជាអភិបាលហិរញ្ញវត្ថុនៃថវិកាគ្រឹះស្ថានសាធារណៈរដ្ឋបាល។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចប្រគល់សិទ្ធិជាអភិបាលហិរញ្ញវត្ថុនេះ ជូនមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល ឬថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតាមការចាំបាច់។

**មាត្រា១៩.-**

មន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមានចែងក្នុងមាត្រា២៦ នៃព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល ជាមន្ត្រីមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងវិស័យគ្រប់គ្រងហិរញ្ញវត្ថុ ដែលត្រូវបានជ្រើសរើសជាសេនាធិការឱ្យនាយកគ្រឹះស្ថានសាធារណៈរដ្ឋបាលក្នុងកិច្ចប្រតិបត្តិការហិរញ្ញវត្ថុ។

មន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុ ត្រូវតែងតាំងដោយក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេស តាមសំណើរបស់នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល និងមានការយល់ព្រមពីក្រុមប្រឹក្សាភិបាល។ មន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុមានភារកិច្ចដូចខាងក្រោម÷

- រៀបចំផែនការយុទ្ធសាស្ត្រថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ស្របតាមគោលនយោបាយយុទ្ធសាស្ត្រ ដែលក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេសបានកំណត់ និងផែនការសកម្មភាពរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលសម្រេចដោយក្រុមប្រឹក្សាភិបាល
- រៀបចំផែនការអភិវឌ្ឍន៍ គម្រោងថវិកាប្រចាំឆ្នាំ និងគម្រោងវិនិយោគរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល
- ធ្វើទំនាក់ទំនងជាមួយក្រសួង ស្ថាប័នអាណាព្យាបាលទាំងពីរពាក់ព័ន្ធនឹងការរៀបចំការអនុវត្ត និងការត្រួតពិនិត្យថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល
- រៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល
- គ្រប់គ្រង និងចាត់ចែងការអនុវត្តថវិកា ស្របតាមគោលការណ៍ហិរញ្ញវត្ថុជាធរមាន
- តាមដានលទ្ធផលនៃការអនុវត្តថវិកា
- សម្របសម្រួលក្នុងនាមជាសេនាធិការរបស់នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល សម្រាប់ការតាមដាន ត្រួតពិនិត្យ ការធ្វើអធិការកិច្ច និងសវនកម្ម។

**មាត្រា២០.-**

នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំរបាយការណ៍ស្ដីពីការអនុវត្តថវិកាប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងអនុម័ត មុននឹងផ្ញើជូនអាណាព្យាបាលបច្ចេកទេស និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវកំណត់លក្ខខណ្ឌនៃការរៀបចំ និងគំរូរបាយការណ៍ ដូចមានកំណត់ក្នុងកថាខណ្ឌខាងលើ សម្រាប់ដាក់ឱ្យគ្រឹះស្ថានសាធារណៈរដ្ឋបាលអនុវត្ត។

**មាត្រា២១.-**

ការបង្កើតរជ្ជទេយ្យចំណូល និង/ឬរជ្ជទេយ្យបុរេប្រទាន និងការតែងតាំងរជ្ជទេយ្យករចំណូល និងរជ្ជទេយ្យករបុរេប្រទានរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវធ្វើឡើងដោយប្រកាសអន្តរក្រសួង រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេស បន្ទាប់ពីទទួលបានសំណើពីនាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល និងដោយមានការសម្រេចជាមុនពីក្រុមប្រឹក្សាភិបាល។

កិច្ចបញ្ជិការជ្ជទេយ្យចំណូល និងរជ្ជទេយ្យបុរេប្រទាន ត្រូវអនុវត្តតាមប្រកាសស្ដីពីកិច្ចបញ្ជិការជ្ជទេយ្យចំណូល និងប្រកាសស្ដីពីកិច្ចបញ្ជិការជ្ជទេយ្យបុរេប្រទានរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលចេញដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ក្នុងករណីចាំបាច់ដែលត្រូវស្នើសុំប្រាក់បុរេប្រទានសម្រាប់ចំណាយ គ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវសុំយោបល់ឯកភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុប្រចាំគ្រឹះស្ថាន។

**មាត្រា២២.-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចេញគោលការណ៍ណែនាំលម្អិតពាក់ព័ន្ធនឹងអតិរេករបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល។

## ជំពូកទី៣

## លទ្ធកម្មសាធារណៈ

**មាត្រា២៣.-**

ការគ្រប់គ្រង ការអនុវត្ត និងការត្រួតពិនិត្យការងារលទ្ធកម្មនៅគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវអនុលោមតាមច្បាប់ស្តីពីលទ្ធកម្មសាធារណៈ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**មាត្រា២៤.-**

កិច្ចលទ្ធកម្មសាធារណៈនៅគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវដំណើរការប្រតិបត្តិតាមគោលការណ៍ វិធីសាស្ត្រ នីតិវិធីលទ្ធកម្មដូចគ្នាទៅនឹងការអនុវត្តនៅគ្រប់ស្ថាប័នអនុវត្តលទ្ធកម្ម។

**មាត្រា២៥.-**

កិច្ចលទ្ធកម្មរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវប្រតិបត្តិដោយអង្គភាពប្រតិបត្តិរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលដែលគ្រប់គ្រង និងដឹកនាំអនុវត្តដោយគណៈកម្មាធិការលទ្ធកម្មមួយ ដែលមាននាយកគ្រឹះស្ថានសាធារណៈរដ្ឋបាលជាប្រធាន និងមានអង្គភាពលទ្ធកម្មមួយជាលេខាធិការដ្ឋាន។ ប្រធានអង្គភាពលទ្ធកម្ម ជាលេខាធិការរបស់គណៈកម្មាធិការលទ្ធកម្ម។

**មាត្រា២៦.-**

គណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្ម ត្រូវបានសម្រេចបង្កើតដោយនាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល ដោយមានការយល់ព្រមពីក្រុមប្រឹក្សាភិបាល។

**មាត្រា២៧.-**

នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល និងជាប្រធានគណៈកម្មាធិការលទ្ធកម្ម ដែលមានអង្គភាពលទ្ធកម្មជាសេនាធិការ ត្រូវរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ ផែនការលទ្ធកម្មកែតម្រូវ ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងអនុម័ត មុននឹងផ្ញើជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុផ្តល់ការយល់ព្រម។

**មាត្រា២៨.-**

គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវផ្ញើរបាយការណ៍លទ្ធកម្មប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ឱ្យបានទៀងទាត់ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៤
## ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

**មាត្រា២៩.-**

គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវទទួលខុសត្រូវគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋតាមលក្ខខណ្ឌ កំណត់ដោយច្បាប់ និងបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។

**មាត្រា៣០.-**

ទ្រព្យសម្បត្តិរដ្ឋ ដែលកំពុងស្ថិតនៅក្រោមការកាន់កាប់របស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវចុះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល តាមបែបបទ និងនីតិវិធី ដែលត្រូវកំណត់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៣១.-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចេញគោលការណ៍ណែនាំលម្អិតអំពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៅគ្រឹះស្ថានសាធារណៈរដ្ឋបាល។

## ជំពូកទី៥
## កិច្ចបញ្ជិកាគណនេយ្យ

**មាត្រា៣២.-**

គោលការណ៍នៃកិច្ចបញ្ជិកាគណនេយ្យរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំស្របតាមវិធានទូទៅ និងប្លង់គណនេយ្យសាធារណៈ ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវមានប្លង់គណនេយ្យ ដែលដកស្រង់ពីប្លង់គណនេយ្យសាធារណៈ។ ប្លង់គណនេយ្យនេះមានការទទួលស្គាល់ និងយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

គណនេយ្យរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល រួមមាន÷

- គណនេយ្យ ដែលគោរពតាមគោលការណ៍ទ្វេភាគ ដែលឆ្លុះបញ្ចាំងគ្រប់ប្រតិបត្តិការថវិកា ប្រតិបត្តិការសាច់ប្រាក់ ប្រតិបត្តិការជាមួយតតិយជន និងកំណត់សំគាល់
- គណនេយ្យអចលនទ្រព្យ ទ្រព្យសកម្ម និងគណនេយ្យតម្លៃ
- គណនេយ្យវិភាគ ប្រសិនបើមានការចាំបាច់។

ការិយបរិច្ឆេទគណនេយ្យនីមួយៗ នៃគ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវកំណត់រយៈពេល១២(ដប់ពីរ)ខែ ដោយគិតចាប់ពីថ្ងៃទី០១ ខែមករា រហូតដល់កាលបរិច្ឆេទបិទបញ្ជីគណនេយ្យនៅថ្ងៃទី៣១ ខែធ្នូនៃឆ្នាំដដែល។

ចំពោះគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលបង្កើតឡើងថ្មី ការិយបរិច្ឆេទទី១ ត្រូវគិតចាប់ពីកាលបរិច្ឆេទបង្កើតគ្រឹះស្ថាននោះជាផ្លូវការ រហូតដល់ថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំដដែល។

**មាត្រា៣៣.-**

គណនេយ្យករមានភារកិច្ចដូចខាងក្រោម÷

- គ្រប់គ្រងការប្រមូលចំណូល

- ទូទាត់ចំណាយ
- កាន់កាប់បញ្ជីគណនេយ្យ និងរក្សាទុកលិខិតយុត្តិការជាច្បាប់ដើម
- ចូលរួមរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល។

គណនេយ្យករ ត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដាក់ជូននាយក និងក្រុមប្រឹក្សាភិបាលនៃគ្រឹះស្ថាន-សាធារណៈរដ្ឋបាល ដើម្បីពិនិត្យ និងអនុម័ត និងបញ្ជូនទៅក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេស និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

គ្រឹះស្ថានសាធារណៈរដ្ឋបាល មានកាតព្វកិច្ចរក្សាទុករាល់បញ្ជី និងឯកសារគណនេយ្យ ព្រមទាំងឯកសារ និងលិខិតយុត្តិការនានារបស់ខ្លួន ឱ្យបានគង់វង្សក្នុងរយៈពេលយ៉ាងតិច១០(ដប់)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការបង្កើតឯកសារទាំងនោះ។

## ជំពូកទី៦
## អធិការកិច្ច និងសវនកម្ម

**មាត្រា៣៤.-**

នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវទទួលខុសត្រូវលើការរៀបចំបង្កើត និងរក្សាឱ្យមានប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់អង្គភាពប្រកបដោយប្រសិទ្ធភាព។

តួនាទីសវនកម្មផ្ទៃក្នុង គឺត្រូវវាយតម្លៃដោយឯករាជ្យនូវអនុលោមភាព ភាពសមស្រប និងសមហេតុផលនៃកិច្ចប្រតិបត្តិការទាំងឡាយរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល និងស័ក្តិសិទ្ធភាព នៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។

ផែនការ និងរបាយការណ៍សវនកម្មផ្ទៃក្នុង ត្រូវផ្ញើជូនក្រុមប្រឹក្សាភិបាល និងក្រសួងអាណាព្យាបាលទាំងពីរ។

**មាត្រា៣៥.-**

ការគ្រប់គ្រងថវិកា និងទ្រព្យសម្បត្តិរដ្ឋរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល គឺជាកម្មវត្ថុនៃការធ្វើអធិការ-កិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងសវនកម្មស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី៧
## ទោសប្បញ្ញត្តិ

**មាត្រា៣៦.-**

មន្ត្រីរាជការពាក់ព័ន្ធគ្រប់ប្រភេទ និងគ្រប់ឋានៈ ដែលមិនបានគោរពការអនុវត្តមុខងារ និងភារកិច្ចរបស់ខ្លួនមិនបានត្រឹមត្រូវពាក់ព័ន្ធនឹងប្រាក់កាសសាធារណៈ ដែលរដ្ឋបានប្រគល់ជូន ត្រូវទទួលទោសតាមច្បាប់ជាធរមាន។

## ជំពូកទី៨
## អវសានប្បញ្ញត្តិ

**មាត្រា៣៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងគ្រឹះស្ថានសាធារណៈរដ្ឋបាលទាំងអស់ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**__កន្លែងទទួល__÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមានត្រា៣៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៤០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ឯកសណ្ឋានសញ្ញាសម្គាល់និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចការងារ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ២៨៣អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់នូវការបង្កើតឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចការងារសម្រាប់ប្រើប្រាស់បំពេញការងារចុះអនុវត្តច្បាប់ស្តីពីការងារនិងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យការងារ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២ .-**

ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិនេះ អនុញ្ញាតឱ្យមន្ត្រីអធិការកិច្ចការងារបម្រើការនៅអគ្គនាយកដ្ឋានការងារ អគ្គលេខាធិការដ្ឋាននៃគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញា បេឡាជាតិរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ នាយកដ្ឋានពាក់ព័ន្ធនៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ មន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត និងអង្គភាពពាក់ព័ន្ធតាមការប្រគល់ភារកិច្ចរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ប្រើប្រាស់សម្រាប់៖

១- បំពេញការងារប្រចាំថ្ងៃក្នុងអង្គភាព។

២- បំពេញបេសកកម្មពាក់ព័ន្ធនឹងការងារអធិការកិច្ចការងារ។

៣- បំពេញបេសកកម្មពង្រឹងការអនុវត្តច្បាប់ក្នុងប្រតិបត្តិការស្រាវជ្រាវ ទប់ស្កាត់ ដោះស្រាយវិវាទការងារ និងកូដកម្ម បាតុកម្មគ្រប់មុខសញ្ញា។

៤- ពិធីបុណ្យទិវាពលកម្មអន្តរជាតិ ១ឧសភា និងពិធីប្រជុំផ្លូវការផ្សេងៗ។

៥- សវនាការតុលាការ។

## ជំពូកទី២
## ឯកសណ្ឋាន

**មាត្រា៣ .-**

ឯកសណ្ឋានរបស់មន្ត្រីអធិការកិច្ចការងារត្រូវកំណត់ដូចខាងក្រោម៖

មានសាច់ក្រណាត់ពណ៌កាគី។

**ក- ចំពោះបុរស**

**១- អាវមាន៤ប្រភេទ៖**

- អាវការងារដៃខ្លី
- អាវការងារដៃវែង
- អាវសាហារីយែនដៃខ្លី
- អាវសាហារីយែនដៃវែង

**១.១- អាវការងារដៃខ្លី**

កាត់ជាទម្រង់អាវធម្មតាដៃខ្លី កឌុប មានប៉ូលស្មា មានហោប៉ៅចំនួន២នៅខាងលើដេរជាលក្ខណៈប៉ះបត់ជាពីរផ្នត់ឆ្វេងស្តាំ គម្របរាងស្លឹកពោធិ៍ ដាក់ឡេវធម្មតាដូចពណ៌អាវ(រូបភាពទី១)។

ឧបសម្ព័ន្ធទី១)។ ឯកសណ្ឋាននេះប្រើប្រាស់សម្រាប់មន្ត្រីអធិការកិច្ចការងារបំពេញការងារប្រចាំថ្ងៃ ទិវាពលកម្មអន្តរជាតិ ១ឧសភា បុណ្យជាតិ សន្និបាត សវនាការ និងករណីតម្រូវក្នុងពិធីនីមួយៗ។

**១.២- អាវការងារដៃវែង**

កាត់ជាទម្រង់អាវធម្មតាដៃវែង កឧប មានប៉ូលស្មា មានហោប៉ៅចំនួន២ នៅខាងលើ ដេរជាលក្ខណៈប៉ះបត់ជាពីរផ្នត់ឆ្វេងស្តាំ គម្របរាងស្លឹកពោធិ៍ ដាក់ឡេវធម្មតាដូចពណ៌អាវ(រូបភាពទី២ ឧបសម្ព័ន្ធទី១)។ ឯកសណ្ឋាននេះប្រើប្រាស់សម្រាប់មន្ត្រីអធិការកិច្ចការងារបំពេញការងារប្រចាំថ្ងៃ ទិវាពលកម្មអន្តរជាតិ ១ឧសភា បុណ្យជាតិ សន្និបាត សវនាការ និងករណីតម្រូវក្នុងពិធីនីមួយៗ។

**១.៣- អាវសាហារីយែនដៃខ្លី**

កាត់ជាទម្រង់អាវធម្មតាដៃខ្លី កបើកពីរសន្លឹក មានឆែកខាងក្រោយមួយ មានប៉ូលស្មា នៅសងខាងភ្ជាប់ដោយឡេវពណ៌ដូចអាវ។ នៅផ្នែកខាងមុខនៃអាវមានដាក់ឡេវរូបព្រះសង្ហារពណ៌មាស ចំនួន៤គ្រាប់ មានហោប៉ៅចំនួន៤ ដេរជាលក្ខណៈប៉ះមានគម្របកាត់ជារាងស្លឹកពោធិ៍ភ្ជាប់ដោយឡេវរូប ព្រះសង្ហារពណ៌មាស(រូបភាពទី៣ឧបសម្ព័ន្ធទី១)។ ឯកសណ្ឋាននេះប្រើប្រាស់បានចាប់ពីថ្នាក់ប្រធាន ការិយាល័យថ្នាក់កណ្តាល និងថ្នាក់ប្រហាក់ប្រហែលឡើងទៅ សម្រាប់ការងារប្រចាំថ្ងៃទិវាពលកម្មអន្តរជាតិ ១ឧសភា បុណ្យជាតិ សន្និបាត សវនាការ និងករណីតម្រូវក្នុងពិធីនីមួយៗ។

**១.៤- អាវសាហារីយែនដៃវែង**

កាត់ជាទម្រង់អាវឈុតធម្មតាដៃវែង កឧប ដៃបំពង់ មានប៉ូលស្មានៅសងខាងភ្ជាប់ ដោយឡេវធម្មតាតាមពណ៌ដូចអាវ មានហោប៉ៅចំនួន៤ ខាងលើ២ ខាងក្រោម២ ដេរជាលក្ខណៈប៉ះមាន បត់ជាពីរឆ្វេងស្តាំ ចង់ហោប៉ៅទាំង៤ ដេរសង្កត់របៀបស្ព័រ មានគម្របរាងស្លឹកពោធិ៍ ដាក់ឡេវចានធម្មតា ស្រដៀងពណ៌អាវ។ ផ្នែកខាងក្រោយមានឆែកមួយ កាត់ដេរតាមលក្ខណៈបច្ចេកទេសធម្មតាទៅតាមទំហំអ្នក ប្រើប្រាស់។ ឯកសណ្ឋាននេះប្រើប្រាស់បានចាប់ពីថ្នាក់អនុប្រធានការិយាល័យថ្នាក់កណ្តាល និងថ្នាក់ ប្រហាក់ប្រហែលឡើងទៅ សម្រាប់ការងារប្រចាំថ្ងៃ ទិវាពលកម្មអន្តរជាតិ១ឧសភា បុណ្យជាតិ សន្និបាត សវនាការ និងករណីតម្រូវក្នុងពិធីនីមួយៗ(រូបភាពទី៤ ឧបសម្ព័ន្ធទី១)។

**២- ខោជើងវែង**

ពណ៌ដូចអាវ ចង្កេះតថ្មេរបង្កប់ជីបខាងមុខម្ខាងពីរៗ មានហោប៉ៅចំនួន៤ ហោប៉ៅ២ ខាង ក្រោយដេរបង្កប់ មានឡេវបង្កប់ក្រោមគម្របរាងស្លឹកពោធិ៍ និងហោប៉ៅចំហៀង២ ដេរបង្កប់តាមថ្មេរ (រូបភាពទី៥ ឧបសម្ព័ន្ធទី១)។

**៣- មួក**

មួកកាស្កេត ត្រូវបានរៀបចំជា៥(ប្រាំ)ថ្នាក់ប្រើបានទាំងបុរសនិងស្ត្រី(រូបភាពទី៦ឧបសម្ព័ន្ធទី១)៖

**៣.១- ថ្នាក់អគ្គនាយក**

មួកកាស្កេតធ្វើពីក្រណាត់ពណ៌ដូចឯកសណ្ឋានដែលផ្នែកខាងមុខខាងលើ មានភ្ជាប់ រូបព្រះសង្ហារពណ៌មាសកម្ពស់៧៨មិល្លីម៉ែត្រ និងទទឹង៦៨មិល្លីម៉ែត្រ។ នៅខាងក្រោមរូបព្រះសង្ហារមាន ខ្សែឆ្វាក់វេញធំពណ៌មាស ដែលនៅចុងសងខាងនៃខ្សែវេញនេះ មានភ្ជាប់ឡេវរូបព្រះសង្ហារពណ៌មាស។ ក្បាំងមួកពណ៌ខ្មៅ មានប៉ាក់ក្បាច់ភ្ញីទេសឌិនពណ៌មាសទម្រង់ស្នែងក្របីដល់ជើងមួក។

**៣.២- ថ្នាក់អគ្គនាយករងនិងប្រធាននាយកដ្ឋាន**

មួកកាស្កេតធ្វើពីក្រណាត់ពណ៌ដូចឯកសណ្ឋាន ដែលផ្នែកខាងមុខខាងលើ មានភ្ជាប់ រូបព្រះសង្ហារពណ៌មាស កម្ពស់៧៨មិល្លីម៉ែត្រ និងទទឹង៦៨មិល្លីម៉ែត្រ។ នៅខាងក្រោមរូបព្រះសង្ហារមាន

ខ្សែឆ្នាក់វេញតូចពណ៌មាស ដែលនៅចុងសងខាងនៃខ្សែវេញនេះ មានភ្ជាប់ឡេវរូបព្រះសង្ការពណ៌មាស។ ក្បាំងមួកពណ៌ខ្មៅ មានប៉ាក់ក្បាច់ភ្ញីទេសខិនពណ៌មាសទម្រង់ស្លែងក្របីដល់ជើងមួក។

**៣.៣- ថ្នាក់អនុប្រធាននាយកដ្ឋាននិងប្រធានមន្ទីររាជធានី ខេត្ត**

មួកកាស្កេតធ្វើពីក្រណាត់ពណ៌ដូចឯកសណ្ឋាន ដែលផ្នែកខាងមុខខាងលើ មានភ្ជាប់រូបព្រះសង្ការពណ៌មាសកម្ពស់៧៨មិល្លីម៉ែត្រ និងទទឹង៦៨មិល្លីម៉ែត្រ។ នៅខាងក្រោមរូបព្រះសង្ការគ្មានខ្សែឆ្នាក់វេញពណ៌មាសទេ។ ក្បាំងមួកពណ៌ខ្មៅ មានប៉ាក់ក្បាច់ភ្ញីទេសខិនពណ៌មាសទម្រង់ស្លែងក្របីដល់ជើងមួក។

**៣.៤- ថ្នាក់ប្រធានការិយាល័យ អនុប្រធានមន្ទីររាជធានី ខេត្ត និងអនុប្រធានការិយាល័យ**

មួកកាស្កេតធ្វើពីក្រណាត់ពណ៌ដូចឯកសណ្ឋាន ដែលផ្នែកខាងមុខខាងលើ មានភ្ជាប់រូបព្រះសង្ការពណ៌មាសកម្ពស់៧៨មិល្លីម៉ែត្រ និងទទឹង៦៨មិល្លីម៉ែត្រ។ នៅខាងក្រោមរូបព្រះសង្ការគ្មានខ្សែឆ្នាក់វេញពណ៌មាសទេ។ ក្បាំងមួកពណ៌ខ្មៅ មានប៉ាក់ក្បាច់ភ្ញីទេសខិនពណ៌មាសទម្រង់ស្លែងក្របីដោយចុងសងខាងទុកចន្លោះ៤០មិល្លីម៉ែត្រ ពីជើងមួក។

**៣.៥- អនុប្រធានការិយាល័យមន្ទីររាជធានី ខេត្ត និងមន្ត្រី**

មួកកាស្កេតធ្វើពីក្រណាត់ពណ៌ដូចឯកសណ្ឋាន ដែលផ្នែកខាងមុខខាងលើ មានភ្ជាប់រូបព្រះសង្ការពណ៌មាសកម្ពស់៧៨មិល្លីម៉ែត្រ និងទទឹង៦៨មិល្លីម៉ែត្រ។ នៅខាងក្រោមរូបព្រះសង្ការគ្មានខ្សែឆ្នាក់វេញពណ៌មាសទេ។ ក្បាំងមួកពណ៌ខ្មៅ មានប៉ាក់ក្បាច់ភ្ញីទេសខិនពណ៌ប្រាក់ទម្រង់ស្លែងក្របីដោយចុងសងខាងទុកចន្លោះ៤០មិល្លីម៉ែត្រ ពីជើងមួក។

**៤- ក្រវ៉ាត់ក**

ក្រវ៉ាត់ក ធ្វើពីក្រណាត់ពណ៌ខៀវ(រូបភាពទី៧ ឧបសម្ព័ន្ធទី១)។

**៥- ខ្សែក្រវ៉ាត់**

ខ្សែក្រវ៉ាត់ពណ៌ខ្មៅ ក្បាលខ្សែក្រវ៉ាត់ពណ៌មាស ទំហំទទឹង៣៨មិល្លីម៉ែត្រនិងបណ្ដោយ៦៥មិល្លីម៉ែត្រ ដែលមានរូបសញ្ញាក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ នៅចំកណ្ដាល(រូបភាពទី៨ ឧបសម្ព័ន្ធទី១)។

**៦- ស្បែកជើង**

ស្បែកជើងឃ្លុបពណ៌ខ្មៅកខ្លី មានខ្សែចង(រូបភាពទី៩ ឧបសម្ព័ន្ធទី១)។

**៧- ស្រោមជើង**

ស្រោមជើងពណ៌ខ្មៅ(រូបភាពទី១០ ឧបសម្ព័ន្ធទី១)។

**ខ- ចំពោះស្ត្រី**

**១- អាវមាន ៤ប្រភេទ**

- អាវការងារដៃខ្លី ដូចបុរស តែមានជីបរាង(រូបភាពទី១១ ឧបសម្ព័ន្ធទី១)។
- អាវការងារដៃវែងដូចបុរស តែមានជីបរាង(រូបភាពទី១២ ឧបសម្ព័ន្ធទី១)។
- អាវសាហារីយែនដៃខ្លីដូចបុរស តែមានជីបរាង(រូបភាពទី១៣ ឧបសម្ព័ន្ធទី១)។
- អាវសាហារីយែនដៃវែងដូចបុរស តែមានជីបរាង(រូបភាពទី១៤ ឧបសម្ព័ន្ធទី១)។

**២- ខោ**

មានលក្ខណៈដូចខោបុរស (រូបភាពទី៥ ឧបសម្ព័ន្ធទី១)។

**៣- សំពត់បំពង់**

មានពណ៌ដូចអាវ កាត់សំពត់រាងបំពង់តចង្អេះ សម្រុងចុះក្រោមដល់ពាក់កណ្ដាលស្មងជើង ផ្នែកខាងក្រោយ មានរូតនៅចំហៀង(រូបភាពទី១៥ ឧបសម្ព័ន្ធទី១)។

**៤- មួក**

មានលក្ខណៈដូចមួកបុរស(រូបភាពទី៦ ឧបសម្ព័ន្ធទី១)។

**៥- ខ្សែក្រវាត់**

មានលក្ខណៈដូចខ្សែក្រវាត់បុរស(រូបភាពទី១៦ ឧបសម្ព័ន្ធទី១)។

**៦- ស្បែកជើង**

៦.១- ស្បែកជើងកែងចោត ធ្វើពីស្បែកពណ៌ខ្មៅ កម្ពស់កែង៥៥មិល្លីម៉ែត្រ(រូបភាពទី១៧ ឧបសម្ព័ន្ធទី១)។

៦.២- ស្បែកជើងកែងរាបធ្វើពីស្បែកពណ៌ខ្មៅ(រូបភាពទី១៨ ឧបសម្ព័ន្ធទី១)។

**៧- ស្រោមជើង**

ស្រោមជើងពណ៌កាគី(រូបភាពទី១៩ ឧបសម្ព័ន្ធទី១)។

## ជំពូកទី៣
## សញ្ញាសម្គាល់

**មាត្រា៤ .-**

សញ្ញាសម្គាល់របស់មន្ត្រីអធិការកិច្ចការងារ មានដូចខាងក្រោម៖

១- សញ្ញាសម្គាល់និមិត្តសញ្ញាក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ជាប៉ាក់សម្រាប់ដេរប៉ះដាក់លើដៃអាវខាងស្ដាំ មានប្រវែង៥០មិល្លីម៉ែត្រពីថ្នេរស្មាអាវ ក្រណាត់ប៉ាក់កម្ពស់៨៧មិល្លីម៉ែត្រ និងទទឹង៧៤មិល្លីម៉ែត្រ(រូបភាពទី២០ ឧបសម្ព័ន្ធទី២)។

២- សញ្ញាសម្គាល់និមិត្តសញ្ញាជាអក្សរ **អធិការកិច្ចការងារ** ជាប៉ាក់សម្រាប់ដេរប៉ះដាក់លើដៃអាវខាងឆ្វេងមានប្រវែង៥០មិល្លីម៉ែត្រពីថ្នេរស្មាអាវ ក្រណាត់ប៉ាក់កម្ពស់២២មិល្លីម៉ែត្រ និងទទឹង១០៥មិល្លីម៉ែត្រ (រូបភាពទី២១ ឧបសម្ព័ន្ធទី២)។

៣- ស្លាកសញ្ញាសម្គាល់សម្រាប់ខ្ទាស់លើហោប៉ៅអាវខាងស្ដាំមានរាងមូលប៉ោងទំហំ៥៥មិល្លីម៉ែត្រ ធ្វើអំពីស្ពាន់ ភ្ជាប់ដោយបន្ទះស្បែកមានទម្រង់ជានិមិត្តសញ្ញាអក្សរ **អធិការកិច្ចការងារ** នៅផ្នែកខាងលើ នៅចំកណ្ដាលមានរង្វង់ស្ពឺមួយ និងមានរូបជើងពានមាសទ្រសៀវភៅបើកដែលមានចារឹកអក្សរ **ក.ប.** និងផ្នែកខាងក្រោមមានអក្សរ **LABOUR INSPECTION** (រូបភាពទី២២ ឧបសម្ព័ន្ធទី២)។

៤- ស្លាកសញ្ញាសម្គាល់សម្រាប់ពាក់នៅចុងកអាវទាំងសងខាង ធ្វើពីក្រណាត់កម្ទីពណ៌ខៀវចាស់ មានរាងជាប្រលេឡូក្រាម មានស៊ុមព័ទ្ធជុំវិញដោយក្បាច់អង្គរភ្ញីទេសកន្ទុយហង្សធ្វើពីស្ពាន់ពណ៌មាស ទទឹង៣៥មិល្លីម៉ែត្រ និងបណ្ដោយ៧០មិល្លីម៉ែត្រ នៅចំកណ្ដាលមានអក្សរ **ក.ប.** ធ្វើពីស្ពាន់ពណ៌មាស ទំហំ១៥មិល្លីម៉ែត្រ(រូបភាពទី២៣ ឧបសម្ព័ន្ធទី២)។

៥- ស្លាកសញ្ញាសម្គាល់ឈ្មោះសម្រាប់មន្ត្រីអធិការកិច្ចការងារ

ស្លាកសម្គាល់ឈ្មោះមន្ត្រី សម្រាប់ពាក់នៅពីលើហោប៉ៅអាវខាងស្ដាំមានរាងចតុកោណ មានបណ្ដោយប្រវែង៨០មិល្លីម៉ែត្រ ទទឹង២៥មិល្លីម៉ែត្រដែលសរសេរអក្សរពណ៌មាស និងញ៉ុតដោយជ័រ

រឹងថ្លាមានផ្ទៃពណ៌ខៀវចាស់ និងមានខ្សែបន្ទាត់ស្តើងពណ៌មាសព័ទ្ធជុំវិញដែលមានទំហំ០,១៥មិល្លីម៉ែត្រ មានសរសេរគោត្តនាមនិងនាមជាអក្សរខ្មែរ អក្សរឡាតាំង តួនាទីនិងលេខសម្គាល់មន្ត្រីអធិការកិច្ចការងារ (រូបភាពទី២៤ ឧបសម្ព័ន្ធទី២)។

## ជំពូកទី៤
## សញ្ញាសក្តិ

**មាត្រា៥ .-**

សញ្ញាសក្តិសម្រាប់ពាក់លើស្មាអាវសងខាង(រូបភាពទី២៥ ឧបសម្ព័ន្ធទី៣) ដូចខាងក្រោមៈ

ក- ខ្នាតនៃសញ្ញាសក្តិ

- មានរាងទ្រវែងស្តួចប្រវែង១៣២មិល្លីម៉ែត្រ
- មានទំហំខាងគល់ប្រវែង៥៧មិល្លីម៉ែត្រ
- មានទំហំខាងចុងប្រវែង៤៥មិល្លីម៉ែត្រ រាងកោងជាមុំទាល។

ខ- សញ្ញាឋានន្តរសក្តិសម្រាប់ពាក់លើស្មានេះ មានចំនួន៧ថ្នាក់ៈ

**១- ថ្នាក់អគ្គនាយក** : ធ្វើពីក្រណាត់កម្ពីពណ៌ខៀវចាស់ ផ្នែកកណ្តាលមានរូបសញ្ញាមកុដរាជ្យ។ នៅផ្នែកខាងក្រោមមកុដរាជ្យ មានប៉ាក់ភ្ជីរាងត្រីកោណពីរឈមគ្នាពណ៌មាស ផ្នែកខាងលើមកុដរាជ្យភ្ជាប់ដោយឡេវរូបព្រះសង្ការពណ៌មាស មានអង្កត់ផ្ចិតប្រវែង១៦មិល្លីម៉ែត្រ មានវ័ណ្ឌពណ៌មាសព័ទ្ធជុំវិញដែលមានបីជុំ។

**២- ថ្នាក់អគ្គនាយករង** : មានលក្ខណៈដូចគ្នាទៅនឹងថ្នាក់អគ្គនាយកប៉ុន្តែវ័ណ្ឌទី៣ ខាងក្នុងមានលក្ខណៈដាច់ៗ។

**៣- ថ្នាក់ប្រធាននាយកដ្ឋាន** : ធ្វើពីក្រណាត់កម្ពីពណ៌ខៀវចាស់ ផ្នែកកណ្តាលមានរូបសញ្ញាមកុដរាជ្យនិងផ្នែកខាងក្រោមមកុដរាជ្យមានប៉ាក់ភ្ជីរាងត្រីកោណពីរឈមគ្នាពណ៌មាស ផ្នែកខាងលើមកុដរាជ្យភ្ជាប់ដោយឡេវរូបព្រះសង្ការពណ៌មាស មានអង្កត់ផ្ចិតប្រវែង១៦មិល្លីម៉ែត្រ មានវ័ណ្ឌពណ៌មាសព័ទ្ធជុំវិញដែលមានពីរជុំ។

**៤- ថ្នាក់អនុប្រធាននាយកដ្ឋាននិងប្រធានមន្ទីររាជធានី ខេត្ត** : មានលក្ខណៈដូចគ្នាទៅនឹងថ្នាក់ប្រធាននាយកដ្ឋានប៉ុន្តែវ័ណ្ឌមួយជាប់ និងវ័ណ្ឌបន្ទាប់ខាងក្នុងលក្ខណៈដាច់ៗ។

**៥- ថ្នាក់ប្រធានការិយាល័យនិងអនុប្រធានមន្ទីររាជធានី ខេត្ត** : មានលក្ខណៈដូចគ្នាទៅនឹងថ្នាក់អនុប្រធាននាយកដ្ឋាននិងប្រធានមន្ទីររាជធានី ខេត្តប៉ុន្តែបន្ទះនៅលើស្មាមានវ័ណ្ឌពណ៌មាសព័ទ្ធជុំវិញដែលមានមួយជុំ។

**៦- ថ្នាក់អនុប្រធានការិយាល័យនិងប្រធានការិយាល័យមន្ទីររាជធានី ខេត្ត** : មានលក្ខណៈដូចគ្នាទៅនឹងថ្នាក់ប្រធានការិយាល័យនិងអនុប្រធានមន្ទីររាជធានី ខេត្ត ប៉ុន្តែបន្ទះលើស្មាមានវ័ណ្ឌមួយជុំដែលមានលក្ខណៈដាច់ៗ។

**៧- ថ្នាក់មន្ត្រីនិងអនុប្រធានការិយាល័យមន្ទីររាជធានី ខេត្ត** : មានលក្ខណៈដូចគ្នាទៅនឹងថ្នាក់អនុប្រធានការិយាល័យនិងប្រធានការិយាល័យមន្ទីររាជធានី ខេត្ត ប៉ុន្តែខុសគ្នាត្រង់បន្ទះលើស្មាគ្មានវ័ណ្ឌពណ៌មាសឡើយ។

**មាត្រា៦ .-**

គំរូឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិគ្រប់ប្រភេទសម្រាប់មន្ត្រីអធិការកិច្ចការងារមានកំណត់ក្នុងឧបសម្ព័ន្ធទី១ ទី២ និងទី៣នៃអនុក្រឹត្យនេះ។

**មាត្រា៧ .-**

មន្ត្រីអធិការកិច្ចការងារម្នាក់ៗតម្រូវទទួលបានឯកសណ្ឋានដូចខាងក្រោម៖

១- ក្នុងចំណោមឯកសណ្ឋានដូចមានចែងខាងលើ ផ្តល់ជូន២(ពីរ)សម្រាប់ក្នុងរយៈពេលមួយឆ្នាំម្តង។ ប្រភេទឯកសណ្ឋានដែលបានផ្តល់ជូន ត្រូវសមស្របទៅតាមការប្រើប្រាស់ក្នុងការបំពេញភារកិច្ចប្រចាំថ្ងៃរបស់មន្ត្រីអធិការកិច្ចការងារម្នាក់ៗ ដូចមានចែងក្នុងអនុក្រឹត្យនេះ។

២- សញ្ញាសម្គាល់និងសញ្ញាសក្តិ ជូនមួយសម្រាប់ក្នុងរយៈពេល៣(បី)ឆ្នាំម្តង។

ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ ប្រើប្រាស់ដោយថវិកាជាតិ ហើយត្រូវសមស្របទៅនឹងទំហំនៃថវិកាជាតិប្រចាំឆ្នាំដែលបានវិភាជជូន។

## ជំពូកទី៥
## បណ្ណសម្គាល់ខ្លួន

**មាត្រា៨ .-**

មន្ត្រីអធិការកិច្ចការងារ ត្រូវប្រើប្រាស់បណ្ណសម្គាល់ខ្លួនមន្ត្រីរាជការនិងលិខិតបង្គាប់ការ ដែលចេញដោយរដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

## ជំពូកទី៦
## ទោសប្បញ្ញត្តិ

**មាត្រា៩ .-**

ជនណាក្លែងបន្លំខ្លួនស្លៀកពាក់ឯកសណ្ឋាន សញ្ញាសក្តិឬសញ្ញាសម្គាល់ និងបណ្ណសម្គាល់ខ្លួនរបស់មន្ត្រីអធិការកិច្ចការងារ ដូចមានកំណត់ក្នុងអនុក្រឹត្យនេះ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

## ជំពូកទី៧
## អន្តរប្បញ្ញត្តិ

**មាត្រា១០ .-**

ឯកសណ្ឋាន សញ្ញាសក្តិ សញ្ញាសម្គាល់ និងបណ្ណសម្គាល់ខ្លួនរបស់មន្ត្រីអធិការកិច្ចការងារដែលកំពុងប្រើប្រាស់សព្វថ្ងៃ ត្រូវបន្តរហូតដល់ឯកសណ្ឋាន សញ្ញាសក្តិ សញ្ញាសម្គាល់ និងបណ្ណសម្គាល់ខ្លួនថ្មីមកជំនួស។

## ជំពូកទី៨
## អវសានប្បញ្ញត្តិ

**មាត្រា១១ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា១២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី  រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ  រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ  រដ្ឋមន្ត្រីគ្រប់ក្រសួង  និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ  ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា
**រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**អ៊ិត សំហេង**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

## រូបភាពទី១ ឧបសម្ព័ន្ធទី១

**នៃអនុក្រឹត្យលេខ៤០ អនក្រ.បក ចុះថ្ងៃទី១៤ ខែ កក្កដា...... ឆ្នាំ២០១៦**

**ស្ដីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចការងារ**

**អាវការងារដៃខ្លី កខុប បុរស**



**មើលពីខាងមុខ**



**មើលពីខាងក្រោយ**

**រូបភាពទី២ ឧបសម្ព័ន្ធទី១**

**នៃអនុក្រឹត្យលេខ៧៤០.អនក្រ.បក ចុះថ្ងៃទី១៤ ខែ...កក្កដា...... ឆ្នាំ២០១៦**

**ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចការងារ**

**អាវការងារដៃវែង កឧុប បុរស**



**មើលពីខាងមុខ**  **មើលពីខាងក្រោយ**

## រូបភាពទី៣ ឧបសម្ព័ន្ធទី១

**នៃអនុក្រឹត្យលេខ១៤០.អនក្រ.បក ចុះថ្ងៃទី១៧ ខែ..កក្កដា....... ឆ្នាំ២០១៦**

**ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចការងារ**

**អាវសាហារីយែនដៃខ្លី កបើកពីសន្លឹក បុរស**



**មើលពីខាងមុខ**



**មើលពីខាងក្រោយ**

## រូបភាពទី៤ ឧបសម្ព័ន្ធទី១

**នៃអនុក្រឹត្យលេខ១៤០អនក្រ.បក ចុះថ្ងៃទី១៧ ខែ កក្កដា....... ឆ្នាំ២០១៦**

**ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចការងារ**

**អាវសាហារីយ៉ែនដៃវែង កខុប បុរស**



**មើលពីខាងមុខ**



**មើលពីខាងក្រោយ**

## រូបភាពទី៥ ឧបសម្ព័ន្ធទី១

**នៃអនុក្រឹត្យលេខ១៤០អនក្រ.បក ចុះថ្ងៃទី១៧.. ខែ..កក្កដា...... ឆ្នាំ២០១៦**

**ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចការងារ**

**ខោជើងវែងបុរសនិងស្ត្រី**



**មើលពីខាងមុខ**



**មើលពីខាងក្រោយ**

## រូបភាពទី៦ ឧបសម្ព័ន្ធទី១

**នៃអនុក្រឹត្យលេខ១៤៨អនក្រ.បកចុះថ្ងៃទី១៧ ខែ..កក្កដា...... ឆ្នាំ២០១៦**

**ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចការងារ**

**មួកការស្កេត**



*សម្រាប់ថ្នាក់អគ្គនាយក*



*ថ្នាក់អគ្គនាយករងនិងប្រធាននាយកដ្ឋាន*



*ថ្នាក់អនុប្រធាននាយកដ្ឋាន និងប្រធានមន្ទីររាជធានី ខេត្ត*



*ថ្នាក់ប្រធានការិយាល័យ អនុប្រធានមន្ទីររាជធានី ខេត្ត*

*និងអនុប្រធានការិយាល័យ*



*អនុប្រធានការិយាល័យ មន្ទីររាជធានី ខេត្ត និងមន្ទី*

## រូបភាពទី៧ ឧបសម្ព័ន្ធទី១

**នៃអនុក្រឹត្យលេខ៤៤០ អនក្រ.បក ចុះថ្ងៃទី១៤. ខែ.កក្កដា....... ឆ្នាំ២០១៦**

**ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចការងារ**

**ក្រវាត់ ក**



## រូបភាពទី៨ ឧបសម្ព័ន្ធទី១

**នៃអនុក្រឹត្យលេខ**១៤៤ អនក្រ.បក **ចុះថ្ងៃទី**១៦. **ខែ**...កក្កដា..... **ឆ្នាំ២០១៦**

**ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចការងារ**

**ខ្សែក្រវាត់( ទំហំ៣៨មិល្លីម៉ែត្រ x ៦៥មិល្លីម៉ែត្រ)**



## រូបភាពទី៩ ឧបសម្ព័ន្ធទី១

នៃអនុក្រឹត្យលេខ១៤០ អនក្រ.បក ចុះថ្ងៃទី១២ ខែ...កក្កដា...... ឆ្នាំ២០១៦

ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចការងារ

ស្បែកជើង បុរស



## រូបភាពទី១០ ឧបសម្ព័ន្ធទី១

**នៃអនុក្រឹត្យលេខ៦៤០ អនក្រ.បក ចុះថ្ងៃទី១២.. ខែ..កក្កដា....... ឆ្នាំ២០១៦**

**ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចការងារ**

**ស្រោមជើង បុរស**



១០

## រូបភាពទី១១ ឧបសម្ព័ន្ធទី១

**នៃអនុក្រឹត្យលេខ១៤០អនក្រ.បក ចុះថ្ងៃទី១២ ខែ...កក្កដា...... ឆ្នាំ២០១៦**

**ស្ដីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្ដិរបស់មន្ត្រីអធិការកិច្ចការងារ**

**អាងការងារដៃខ្លី កខុប ស្ត្រី**



**មើលពីខាងមុខ**



**មើលពីខាងក្រោយ**

១១/...

## រូបភាពទី១២ ឧបសម្ព័ន្ធទី១

### នៃអនុក្រឹត្យលេខ១៤០ អនក្រ.បក ចុះថ្ងៃទី១៤ ខែ កក្កដា...... ឆ្នាំ២០១៦

### ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចការងារ

### អាវការងារដៃវែង កខុប ស្ត្រី



មើលពីខាងមុខ



មើលពីខាងក្រោយ

១២/

## រូបភាពទី១៣ ឧបសម្ព័ន្ធទី១

**នៃអនុក្រឹត្យលេខ១៤០អនក្រ.បក ចុះថ្ងៃទី១៧ ខែ..កក្កដា...... ឆ្នាំ២០១៦**

**ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចការងារ**

**អាវសាហារីយែនដៃខ្លី កបើកពីរសន្លឹក ស្ត្រី**



**មើលពីខាងមុខ**



**មើលពីខាងក្រោយ**

១៣

## រូបភាពទី១៤ ឧបសម្ព័ន្ធទី១

**នៃអនុក្រឹត្យលេខ១៤០ អនក្រ.បក ចុះថ្ងៃទី១៧. ខែ.កក្កដា...... ឆ្នាំ២០១៦**

**ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចការងារ**

**អាវសាហារីយែនដៃវែង កខុប ដៃបំពង់ ស្ត្រី**



**មើលពីខាងមុខ**



**មើលពីខាងក្រោយ**



## រូបភាពទី១៥ ឧបសម្ព័ន្ធទី១

### នៃអនុក្រឹត្យលេខ១៤០ អនក្រ.បក ចុះថ្ងៃទី១៤. ខែ...កក្កដា...... ឆ្នាំ២០១៦

### ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចការងារ

### សំពត់បំពង់ ស្ត្រី



មើលពីខាងមុខ



មើលពីខាងក្រោយ

១៥/៧/៤

## រូបភាពទី១៦ ឧបសម្ព័ន្ធទី១

**នៃអនុក្រឹត្យលេខ១៤០ អនក្រ.បក ចុះថ្ងៃទី១៧ ខែ កក្កដា ឆ្នាំ២០១៦**

**ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចការងារ**

**ខ្សែក្រវាត់ ( ទំហំ៣៨មិល្លីម៉ែត្រ x ៦៥មិល្លីម៉ែត្រ )**



១៦

**រូបភាពទី១៧ ឧបសម្ព័ន្ធទី១**

**នៃអនុក្រឹត្យលេខ................ ចុះថ្ងៃទី...... ខែ............... ឆ្នាំ២០១៦**

**ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចការងារ**

**ស្បែកជើងកែងចោត ស្ត្រី**





១៧/ញ

**រូបភាពទី១៨ ឧបសម្ព័ន្ធទី១**

**នៃអនុក្រឹត្យលេខ១៤៤ អនក្រ.បក ចុះថ្ងៃទី.១៤. ខែ....កក្កដា.... ឆ្នាំ២០១៦**

**ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចការងារ**

**ស្បែកជើងកែងរាប ស្ត្រី**



# រូបភាពទី១៩ ឧបសម្ព័ន្ធទី១

**នៃអនុក្រឹត្យលេខ១៤០.អនក្រ.បក ចុះថ្ងៃទី១២. ខែ.កក្កដា....... ឆ្នាំ២០១៦**

**ស្ដីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្ដិរបស់មន្ត្រីអធិការកិច្ចការងារ**

**ស្រោមជើង ស្ត្រី**



## រូបភាពទី២០ ឧបសម្ព័ន្ធទី២

### នៃអនុក្រឹត្យលេខ១៤០អនក្រ.បក ចុះថ្ងៃទី១៥.. ខែ...កក្កដា..... ឆ្នាំ២០១៦

### ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចការងារ

### សញ្ញាសម្គាល់ លើដៃអាវខាងស្តាំ

២០/៨

**រូបភាពទី២១ ឧបសម្ព័ន្ធទី២**

**នៃអនុក្រឹត្យលេខ១៤០ អនក្រ.បក ចុះថ្ងៃទី១៤ ខែ...កក្កដា...... ឆ្នាំ២០១៦**

**ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចការងារ**

**សញ្ញាសម្គាល់ លើដៃអាវខាងឆ្វេង**



## រូបភាពទី២២ ឧបសម្ព័ន្ធទី២

### នៃអនុក្រឹត្យលេខ១៤០អនក្រ.បក ចុះថ្ងៃទី១៤ ខែ...កក្កដា..... ឆ្នាំ២០១៦

### ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចការងារ

### សញ្ញាសម្គាល់ លើហោប៉ៅអាវស្តាំ



## រូបភាពទី២៣ ឧបសម្ព័ន្ធទី២

**នៃអនុក្រឹត្យលេខ...១៤០ អនក្រ.បក...ចុះថ្ងៃទី...១៤... ខែ...កក្កដា...... ឆ្នាំ២០១៦**

**ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចការងារ**

**សញ្ញាសម្គាល់ នៅចុងករអាវ**



# រូបភាពទី២៤ ឧបសម្ព័ន្ធទី២

## នៃអនុក្រឹត្យលេខ១៤០ អនក្រ.បក ចុះថ្ងៃទី១២ ខែ..កក្កដា...... ឆ្នាំ២០១៦

## ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចការងារ

## ស្លាកសញ្ញាសម្គាល់ឈ្មោះ



## រូបភាពទី២៥ ឧបសម្ព័ន្ធទី៣

**នៃអនុក្រឹត្យលេខ១៤០ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០១៦**

**ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចការងារ**

**សញ្ញាសក្តិសម្រាប់ពាក់លើស្មាអាវសងខាង**



**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៥៧៣ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា១.** បំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **ឈ្លោក យ៉េម** ប្រធានអង្គការសម្រេចសុបិនកុមារកម្ពុជា បានខិតខំស្វែងរកជំនួយជួយកសាងអគារសិក្សា ចំនួន០១ខ្នង មាន០៤បន្ទប់ ធ្វើដងទង់ជាតិ ខ្លោងទ្វារ ព្រមទាំងបំពាក់គ្រឿងសង្ហារិម ជូនដល់សាលាបឋមសិក្សាអន្លង់មាន ស្ថិតនៅភូមិអន្លង់មាន ឃុំពេជ្រចិន្តា ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ។

**មាត្រា២.** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា អភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧៥៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១** -.បំពាក់មេដាយការងារថ្នាក់មាសជូនមន្ត្រីរាជការ និងសប្បុរសជន ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិ មាតុភូមិ និងបានចូលរួមកសាងអភិវឌ្ឍន៍ភូមិ ឃុំ ស្រុក ក្រុង ក្នុងខេត្តព្រះសីហនុ ដូចមានរាយនាមខាងក្រោម:

១- ឯកឧត្តម **យូរ សារុំ** សប្បុរសជន

២- លោក **ជុំ សារ៉ែន** សប្បុរសជន

៣- វរៈនារីត្រី **គួច ហុក** អត្តលេខ០២៩៣៦៩

៤- អនុសេនីយ៍ឯក **ថោង ជា** អត្តលេខ១៨៧៤៥៥

៥- អនុសេនីយ៍ឯក **មុំ ចំរើន** អត្តលេខ១៨៧៤៨៥

៦- លោក **សុខ ស៊ីនួន** សប្បុរសជន

៧- លោក **លន់ ម៉េងស្រន់** សប្បុរសជន

៨- អនុសេនីយ៍ត្រី **ហ៊ីន គាន់ម៉ូច** អត្តលេខ៧៤៤៦៩

៩- លោក **ឈៀង ហុង** សប្បុរសជន

**មាត្រា ២**-. រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ ២០១៦

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៧៥៣ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

**មាត្រា ១** : តម្លើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ឯក** ជូននាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៖

១- ឧត្តមសេនីយ៍ទោ **ស៊ិន ម៉ិនឈាន** អត្តលេខ ០៧២៩៦
២- ឧត្តមសេនីយ៍ទោ **ហាក់ ម៉ិនថា** អត្តលេខ ០៦២៧៤
៣- ឧត្តមសេនីយ៍ទោ **លឹម ហុកលី** អត្តលេខ ៤១០៦៨ ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងមាត្រា ១ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១៦*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ   សាសនា   ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:..៧៥៤..អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា ជាកិច្ចបច្ឆាមរណៈ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៣៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១** : ត្រូវបានដំឡើងឋានន្តរស័ក្តិថ្នាក់ **វរសេនីយ៍ឯក** ជាកិច្ចបច្ឆាមរណៈជូនចំពោះសពលោកវរសេនីយ៍ទោ **សេង រ៉ាវុធ** អត្តលេខ ០១០២២ នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១៦*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៥៥... អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១** : តម្លើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ឯក** ជូននាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៖

១- វរសេនីយ៍ទោ **ហេង បូរិន** អត្តលេខ ០៥៩៨៥
២- វរសេនីយ៍ទោ **កែវ ចន្ថា** អត្តលេខ ០៧០៣៦
៣- វរសេនីយ៍ទោ **គឹម តុលា** អត្តលេខ ៧៣៥៤៥ ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:៧៥៦...អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## ការតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា ជាកិច្ចបច្ឆាមរណៈ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** តម្លើងឋានន្តរស័ក្តិថ្នាក់ **វរសេនីយ៍ឯក** ជាកិច្ចបច្ឆាមរណៈជូនចំពោះសពវរសេនីយ៍ទោ **រិន រ៉ា** អត្តលេខ ០៦៩១១ នាយនគរបាលជាន់ខ្ពស់ នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា ក្រសួងមហាផ្ទៃ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១៦

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ  សាសនា  ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:..៧៥៣..អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យ លេខ ៧៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យ លេខ ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រង នៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា១ :** តែងតាំងមន្ត្រីរាជការចំនួន ០៤ របស់ក្រសួងអភិវឌ្ឍន៍ជនបទ ដូចមានខាងក្រោម÷

| | | |
|---|---|---|
| ១- លោក | ទូន ភិរម្យ | ជាអគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុ ជំនួសលោក ផាវ៉ា មង្គល ដែលបានផ្ទេរក្របខណ្ឌចេញ |
| ២- លោក | គង់ វិទ្យា | ជាអគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុ ជំនួសលោក យ៉ាន់ វ៉ាន់ដឺលុច ដែលបានផ្ទេរក្របខណ្ឌចេញ |
| ៣- លោកស្រី | ឈាង សុខណា | ជាអគ្គាធិការរង នៃអគ្គាធិការដ្ឋាន |
| ៤- លោក | អឿន ជារិទ្ធ | ជាប្រធាននាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ ជំនួសលោក ហួ កុលវ័ន្តដែលបានផ្ទេរក្របខណ្ឌចេញ ។ |

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីជនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅ រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល ៖</u>
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ -កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៧៥៤...អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យ លេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យ លេខ ១១៤ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១:** តែងតាំងលោក **ច័ន្ទ ប៉ុណ្ណរិកា** ជាអនុប្រធានរដ្ឋបាលព្រៃឈើ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ [illegible] ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល ÷
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៥៩ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមុខងារ នាយទាហាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកែសំរួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៩/១២១១ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ
- បានឃើញអនុក្រឹត្យលេខ ៨៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ
- តាមសំណើរបស់ប្រធានគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ

## សម្រេច

**មាត្រា១ :** តែងតាំងមុខងារនាយទាហាន នៃកងយោធពលខេមរភូមិន្ទ ចំនួន០២រូប ដូចមានរាយនាមខាងក្រោម៖

១- ឧត្តមនាវីទោ **យិន ច័ន្ទឌី** អត្តលេខ **០០៤៩៥១** ជាអគ្គលេខាធិការរង នៃគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ

២- ឧត្តមសេនីយ៍ទោ **សូ ម៉ៅ** អត្តលេខ **០០១៣៣៣** ជាប្រធាននាយកដ្ឋានរដ្ឋបាល អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ រដ្ឋមន្ត្រី គ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែកក្កដា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ -កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ**: ៧៥៧.អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** តម្លើងឋានន្តរស័ក្តិថ្នាក់ **វរសេនីយ៍ឯក** ជូននាយនគរបាលជាន់ខ្ពស់ ក្របខណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៖

១- វរសេនីយ៍ទោ **អេង បូរិទ្ធ** អត្តលេខ ៣៧៣៦៣
២- វរសេនីយ៍ទោ **ហាវ សុខា** អត្តលេខ ៧១៨៦៤
៣- វរសេនីយ៍ទោ **ប៉ុន សុធារ៉ូ** អត្តលេខ ៥៧៣០៦
៤- វរសេនីយ៍ទោ **រ័ត្ន ពិសី** អត្តលេខ ៦៣២៥៩
៥- វរសេនីយ៍ទោ **ម៉ុន រី** អត្តលេខ ០៧៥៨៧
៦- វរសេនីយ៍ទោ **ពេជ្រ សុវណ្ណា** អត្តលេខ ០៧៥៨៨ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១៦*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៥២៦១ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមន្ត្រីរាជការ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យ លេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១២០ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ២០១៦ ស្តីពីការបង្កើតនាយកដ្ឋានសម្បទានដីសង្គមកិច្ច ចំណុះអគ្គនាយកដ្ឋានលំនៅឋាន នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួងស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

**សម្រេច**

**មាត្រា ១** : តែងតាំងលោក **ហួ កុលច័ន្ទ** ជាប្រធាននាយកដ្ឋានសម្បទានដីសង្គមកិច្ច នៃអគ្គនាយកដ្ឋានលំនៅឋាន ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ខាងលើត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៧៦៤ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការដំឡើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១** : ដំឡើងឋានន្តរស័ក្តិ វរសេនីយ៍ឯក ជូនលោកវរសេនីយ៍ទោ **សុខ ម៉ារិន** អត្តលេខ ៣៦៧៩០ នាយនគរបាលជាន់ខ្ពស់ ក្របខណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧៦៣ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការតម្លើងឋានន្តរសក្តិមន្ត្រីនគរបាលជាតិកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់ក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១** : តម្លើងឋានន្តរសក្តិថ្នាក់ **វរសេនីយ៍ឯក** ជូននាយនគរបាលជាន់ខ្ពស់ ក្របខណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៖

១- វរសេនីយ៍ទោ **ហួន សំអាន**      អត្តលេខ ២៧៥៨៤

២- វរសេនីយ៍ទោ **គិន តុណ្ណា**      អត្តលេខ ៥៦២៧២

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល ៖</u>
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ..៧៦៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរបញ្ចូលទៅក្នុងឋានន្តរស័ក្តិនាយក្រមការ នៃក្របខ័ណ្ឌមន្ត្រីក្រមការ ក្រសួងមហាផ្ទៃ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៧៥ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ផ្ទេរបញ្ចូលមន្ត្រីរាជការចំនួន ០៧រូប ទៅក្នុងឋានន្តរស័ក្តិនាយក្រមការ នៃក្របខ័ណ្ឌមន្ត្រីក្រមការ ក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោមៈ

| | |
|---|---|
| ១- លោក **ឃុន ឃួរ** | ពីឋានន្តរស័ក្តិក្រមការដើមខ្សែ ថ្នាក់លេខ៤ មកឋានន្តរស័ក្តិនាយក្រមការ ថ្នាក់លេខ៦ |
| ២- លោក **ខឹម សម្បុរ** | ពីឋានន្តរស័ក្តិក្រមការ ថ្នាក់លេខ៣ មកឋានន្តរស័ក្តិនាយក្រមការ ថ្នាក់លេខ៦ |

៣- លោកស្រី **អ៊ិន សោភ័ណ្ឌា** ពីឋានន្តរស័ក្តិក្រមការ ថ្នាក់លេខ៣ មកឋានន្តរស័ក្តិនាយក្រមការ ថ្នាក់លេខ៦

៤- លោក **សាខ ស៊ីណេត** ពីឋានន្តរស័ក្តិក្រមការ ថ្នាក់លេខ៤ មកឋានន្តរស័ក្តិនាយក្រមការ ថ្នាក់លេខ៦

៥- លោក **ម៉ៅ ថេត** ពីឋានន្តរស័ក្តិក្រមការ ថ្នាក់លេខ៤ មកឋានន្តរស័ក្តិនាយក្រមការ ថ្នាក់លេខ៦

៦- លោក **ជុំ ធីរៈ** ពីឋានន្តរស័ក្តិក្រមការ ថ្នាក់លេខ៤ មកឋានន្តរស័ក្តិនាយក្រមការ ថ្នាក់លេខ៦

៧- លោក **គង់ សុគា** ពីឋានន្តរស័ក្តិលេខាធិការរដ្ឋបាល ថ្នាក់លេខ៩ មកឋានន្តរស័ក្តិនាយក្រមការ ថ្នាក់លេខ៦ ។

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល** :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាលកម្ពុជា**　　　　**ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខ:** ៧៣ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការជ្រើសរើសពលទាហាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**ប្រការ១ :** អនុញ្ញាតឲ្យក្រសួងការពារជាតិ ជ្រើសរើសពលទាហាន ចំនួន ១០០(មួយរយ)នាក់ សម្រាប់បំពេញក្របខ័ណ្ឌឲ្យបញ្ជាការដ្ឋានជាតិកម្លាំងពិសេសប្រឆាំងភេរវកម្ម ។

**ប្រការ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៦៤ . សសរ

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតគណៈកម្មាធិការសម្របសម្រួល អនុវត្តន៍ កាតព្វកិច្ចក្រោម ក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក និងរៀបចំឯកសារសម្រាប់ត្រួតពិនិត្យ គោលនយោបាយពាណិជ្ជកម្មកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## សម្រេច

**ប្រការ ១.**_

ត្រូវបានបង្កើត "គណៈកម្មាធិការសម្របសម្រួលអនុវត្តន៍ កាតព្វកិច្ចក្រោមក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក និងរៀបចំឯកសារសម្រាប់ត្រួតពិនិត្យគោលនយោបាយពាណិជ្ជកម្មកម្ពុជា"

ហៅកាត់ថា គ.អ.ក.ព ដើម្បីសម្របសម្រួលជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ សំដៅអនុវត្តន៍កាតព្វកិច្ចរបស់កម្ពុជាក្រោមក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក និងរៀបចំឯកសារនានាសម្រាប់កិច្ចប្រជុំត្រួតពិនិត្យ គោលនយោបាយពាណិជ្ជកម្មកម្ពុជា។

គ.អ.ក.ព មានលេខាធិការដ្ឋាននៅ ក្រសួងពាណិជ្ជកម្ម។ ការរៀបចំ និងប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន គ.អ.ក.ព ត្រូវកំណត់ដោយប្រធាន គ.អ.ក.ព ។

**ប្រការ ២.**_

គ.អ.ក.ព មានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| ១. រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | ប្រធាន |
| ២. រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| ៣. រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤. រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |
| ៥. រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៦. រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ៧. រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៨. រដ្ឋលេខាធិការក្រសួងរ៉ែ និងថាមពល | សមាជិក |
| ៩. រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១០. រដ្ឋលេខាធិការក្រសួងផែនការ | សមាជិក |
| ១១. រដ្ឋលេខាធិការក្រសួងអបរំ យុវជន និងកីឡា | សមាជិក |
| ១២. រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ១៣. រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ | សមាជិក |
| ១៤. រដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ១៥. រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ១៦. រដ្ឋលេខាធិការក្រសួងព័ត៌មាន | សមាជិក |
| ១៧. រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |
| ១៨. រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ១៩. រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ២០. រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ២១. រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ២២. រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ២៣. រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ២៤. អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ២៥. អនុរដ្ឋលេខាធិការ រដ្ឋលេខាធិការដ្ឋាន អាកាសចរណ៍ស៊ីវិល | សមាជិក |

២៦. អគ្គលេខាធិការរងគណៈកម្មការវិនិយោគនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក
២៧. ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា សមាជិក

**ប្រការ ៣.**_

គ.អ.ក.ព មានភារកិច្ចដូចខាងក្រោម៖

- តាមដាន និងសម្របសម្រួលការអនុវត្តកាតព្វកិច្ច និងការសន្យាដែលបានធ្វើឡើងក្រោមក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោកដើម្បីរាយការណ៍ជូនរាជរដ្ឋាភិបាល អំពីវឌ្ឍនភាពការងារ និងទិសដៅដែលត្រូវធ្វើបន្ត
- រៀបចំលិខិតបទដ្ឋានគតិយុត្តិថ្មី ឬ លើកទិសដៅសម្រាប់ធ្វើវិសោធនកម្មលិខិតបទដ្ឋានច្បាប់ជាធរមាន និងកែលម្អគោលនយោបាយពាណិជ្ជកម្ម ឲ្យមានអនុលោមភាព និងសង្គតិភាពជាមួយការសន្យាក្រោមក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក
- រៀបចំឯកសារ និងផ្ដល់អនុសាសន៍ជូនរាជរដ្ឋាភិបាល សម្រាប់ចរចាជាមួយបណ្ដាប្រទេសក្នុងបរិបទពាណិជ្ជកម្មតំបន់ និងពិភពលោក
- ចងក្រងឯកសារគោលនយោបាយទាក់ទងនិងពាណិជ្ជកម្ម សម្រាប់កិច្ចប្រជុំត្រួតពិនិត្យគោលនយោបាយពាណិជ្ជកម្ម នៅក្នុងក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក
- គៀងគរថវិកាពីដៃគូអភិវឌ្ឍន៍នានាសម្រាប់ជួយដល់ ក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្នុងការអនុវត្តកាតព្វកិច្ច និងការសន្យាក្រោមក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក
- ចូលរួម និងសម្របសម្រួលដល់ការរៀបចំកិច្ចប្រជុំនានា ពាក់ព័ន្ធនិងការត្រួតពិនិត្យ គោលនយោបាយពាណិជ្ជកម្មកម្ពុជា ទាំងក្នុងប្រទេស និងក្រៅប្រទេស
- អនុវត្តន៍ភារកិច្ចផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន

**ប្រការ ៤.**_

អនុប្រធាន និងសមាជិក គ.អ.ក.ព ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន ឬមានភារកិច្ចផ្សេង អនុប្រធានត្រូវដឹកនាំប្រជុំជំនួស តាមការប្រគល់ភារកិច្ចពីប្រធាន។ ប្រធាន គ.អ.ក.ព អាចអញ្ជើញមន្ត្រីតំណាងក្រសួង-ស្ថាប័នផ្សេងទៀតឲ្យចូលរួមប្រជុំតាមការចាំបាច់។

**ប្រការ ៥.**_

ការចំណាយសម្រាប់ដំណើរការ គ.អ.ក.ព ត្រូវយកពីថវិកាជាតិ ក្នុងគម្រោងថវិការបស់ក្រសួងពាណិជ្ជកម្ម ឬថវិកាទទួលបានពីប្រភពស្របច្បាប់ផ្សេងទៀត។

**ប្រការ ៦.**_

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នពាក់ព័ន្ធទាំងអស់ ត្រូវអនុវត្តន៍សេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្តិ**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៧ (ដើម្បីអនុវត្ត)
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៦៥...ស.ស.រ

**សេចក្តីសម្រេច**

**ស្តីពី**

**ការកែសម្រួលសមាសភាពគណៈកម្មការអន្តរក្រសួងដើម្បីរៀបចំ និងចូលរួមពិព័រណ៍ពិភពលោក និងពិព័រណ៍ពាណិជ្ជកម្មអន្តរជាតិ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និង បំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម
- បានឃើញសេចក្តីសម្រេចលេខ ១៣២ សសរ ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីរៀបចំ និងចូលរួមពិព័រណ៍ពិភពលោក និងពិព័រណ៍ពាណិជ្ជកម្មអន្តរជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សម្រេច**

**ប្រការ ១.-**

ត្រូវបានកែសម្រួលសមាសភាពគណៈកម្មការអន្តរក្រសួង ដើម្បីរៀបចំ និងចូលរួមពិព័រណ៍ពិភពលោក និងពិព័រណ៍ពាណិជ្ជកម្មអន្តរជាតិ នៅបណ្តាប្រទេសលើពិភពលោក ដែលមានសមាសភាពដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ប៉ាន សូរស័ក្តិ** | រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | ប្រធាន |
| ២-ឯកឧត្តម | **ឈួន ដារ៉ា** | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| ៣-ឯកឧត្តម | **ប៉ាក់ សុខុម** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | អនុប្រធាន |
| ៤-ឯកឧត្តម | **ឆាន់ ទឡ្ហៈ** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |

| | | |
|---|---|---|
| ៥-លោកជំទាវ **ឆឹង ស៊ីមន** | អនុរដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | សមាជិកា |
| ៦-ឯកឧត្តម **កែ គី** | អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |
| ៧-ឯកឧត្តម **កៅ ឆារ៉ូ** | អនុរដ្ឋលេខាធិការក្រសួងរ៉ែ និងថាមពល | សមាជិក |
| ៨-ឯកឧត្តម **ចាន់ សុខុឡ្យ** | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៩-ឯកឧត្តម **សឹង រេត** | ទីប្រឹក្សាឯកឧត្តមឧបនាយករដ្ឋមន្ត្រី **សុខ អាន** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១០-ឯកឧត្តម **ជា ឧត្តី** | អគ្គលេខាធិការរងគណៈកម្មាធិការវិនិយោគកម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ១១-ឯកឧត្តម **ស៊ាង ថៃ** | អគ្គនាយកជំរុញពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម | សមាជិកអចិន្ត្រៃយ៍ |
| ១២-ឯកឧត្តម **ហាប់ ទូច** | អគ្គនាយកបច្ចេកទេសវប្បធម៌នៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | សមាជិក |
| ១៣-ឯកឧត្តម **សារុន រ៉ាឌី** | ទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធាននាយកដ្ឋានផ្ទៃក្នុង នៃទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១៤-លោក**ឡៀប សេរីវិសុទ្ធ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានប្រេងកាត ក្រសួងរ៉ែ និងថាមពល | សមាជិក |
| ១៥-លោក **ហេង សោភ័ណា** | អគ្គនាយករងនៃអគ្គនាយកដ្ឋានសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម ក្រសួងឧស្សហកម្ម និងសិប្បកម្ម | សមាជិក |
| ១៦-លោក **ម៉ាក់ សឿន** | អគ្គនាយករងនៃអគ្គនាយកដ្ឋានកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១៧-លោក **សុខ ដារិទ្ធិ** | ប្រធាននាយកដ្ឋានកិច្ចការពិព័រណ៍នៃអគ្គនាយកដ្ឋាន ជំរុញពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១៨-លោក **គឹម ច័ន្ទរស្មី** | ប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ នៃអគ្គនាយកដ្ឋាន រដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១៩-លោក **ជា គៀត** | អនុប្រធាននាយកដ្ឋានទំនាក់ទំនងសាធារណៈ និងជំរុញ វិនិយោគឯកជននៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ២០.លោក **ស្រី ឧជ** | អនុប្រធាននាយកដ្ឋានហិរញ្ញកិច្ចនៃអគ្គនាយកដ្ឋានថវិកា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក។ |

**ប្រការ ២.-**

គណៈកម្មការអន្តរក្រសួងនេះ មានភារកិច្ចដូចតទៅ ៖

- ចាត់ចែង រៀបចំ និងចូលរួមគ្រប់ពិព័រណ៍ពិភពលោក និងពិព័រណ៍ពាណិជ្ជកម្មអន្តរជាតិ ដែលរៀបចំធ្វើនៅបណ្តាប្រទេសលើពិភពលោក ដោយប្រើប្រាស់កញ្ចប់ថវិកាក្រសួងពាណិជ្ជកម្មដែលអនុញ្ញាតដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ធ្វើទំនាក់ទំនងជាមួយភាគីម្ចាស់ផ្ទះ ដើម្បីសម្រួលដល់ការចាត់ចែង រៀបចំ និងចូលរួមពិព័រណ៍ពិភពលោក និងពិព័រណ៍ពាណិជ្ជកម្មអន្តរជាតិ
- ធ្វើទំនាក់ទំនងជាមួយក្រសួង ស្ថាប័ន អង្គការជាតិ អង្គការអន្តរជាតិ និងក្រុមហ៊ុននានា ពាក់ព័ន្ធនឹងការចាត់ចែង រៀបចំ និងទៅចូលរួមពិព័រណ៍ពិភពលោក និងពិព័រណ៍ពាណិជ្ជកម្មអន្តរជាតិ
- ទទួលខុសត្រូវ និងចាត់ចែងការងាររៀបចំសាងសង់ពន្លាជាតិ សម្របសម្រួល និងគ្រប់គ្រងស្តង់ឯកជន
- ចូលរួមសន្និសីទ សិក្ខាសាលា និងសកម្មភាពផ្សេងទៀត ដែលរៀបចំដោយគណៈកម្មការពិព័រណ៍ពិភពលោក និងការិយាល័យពិព័រណ៍អន្តរជាតិ (BIE)
- លើកយោបល់ ឬស្នើសុំការពិនិត្យ សម្រេចពីប្រមុខរាជរដ្ឋាភិបាល លើការងារជាក់ស្តែងក្នុងករណីចាំបាច់

- ធ្វើរបាយការណ៍បូកសរុបលទ្ធផលនៃការចូលរួមពិព័រណ៍ ជូនប្រមុខរាជរដ្ឋាភិបាល ក្រោយពេលពិព័រណ៍ពិភពលោក និងពិព័រណ៍ពាណិជ្ជកម្មអន្តរជាតិមួយលើកៗត្រូវបានបញ្ចប់
- បំពេញភារកិច្ចផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

**ប្រការ ៣.-**

អគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ជាលេខាធិការដ្ឋាននៃគណៈកម្មការអន្តរក្រសួង ដើម្បីរៀបចំ និងចូលរួមពិព័រណ៍ពិភពលោក និងពិព័រណ៍ពាណិជ្ជកម្មអន្តរជាតិ។

**ប្រការ ៤.-**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវពិនិត្យ និងផ្តល់ថវិកាសម្រាប់ចំណាយជូនដល់គណៈប្រតិភូ ដែលអញ្ជើញទៅចូលរួមពិព័រណ៍ពិភពលោក និងពិព័រណ៍ពាណិជ្ជកម្មអន្តរជាតិ។

**ប្រការ ៥.-**

ប្រធានគណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិបង្កើតអនុគណៈកម្មការមួយចំនួនសម្រាប់ជំនួយការងារ។

**ប្រការ ៦.-**

គណៈកម្មការអន្តរក្រសួងនេះ ត្រូវស្ថិតនៅជានិរន្តរ៍ និងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងពាណិជ្ជកម្ម។

**ប្រការ ៧.-**

សេចក្តីសម្រេចលេខ ១៣២ សសរ ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៤ និងបទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន និងសាមីខ្លួន ដែលមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ.៦២៥៤......សហវ.ប្រក

# ប្រកាសរួម

## ស្តីពី

## ការផ្តល់សេវាសាធារណៈរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**រដ្ឋមន្ត្រី**
**ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩២/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៨ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធប្រហាក់ប្រហែល



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664    Fax : 855-23-427 798

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការគ្រប់គ្រងត្រួតពិនិត្យសិល្បៈភាពយន្ត និងវីដេអូ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលតារាងពន្ធតែមប្រើសារពើពន្ធ
- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញប្រកាសលេខ ១៨៩០ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីនីតិវិធីនៃការគ្រប់គ្រងរដ្ឋទេយ្យចំណូលសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់
- បានឃើញសារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់
- សារាចរណែនាំលេខ ០៧ សរណ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០០ របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈលើការអនុវត្តអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការគ្រប់គ្រងត្រួតពិនិត្យសិល្បៈភាពយន្ត និងវីដេអូ
- យោងការចាំបាច់របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សម្រេច**

**ប្រការ១ .-**

អនុញ្ញាតឱ្យក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ អនុវត្តការប្រមូលចំណូលពីកម្រៃសេវាសាធារណៈ ដើម្បីជាគុណប្រយោជន៍ដល់ថវិកាជាតិ។

**ប្រការ២ .-**

សេវាសាធារណៈ ដែលផ្តល់ដោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវបានរៀបចំជាកម្រងសេវាសាធារណៈ ដែលមានរាយលម្អិតអំពីតម្លៃសេវា រយៈពេលអតិបរមានៃការផ្តល់សេវា និងសុពលភាព ទៅតាមប្រភេទសេវាសាធារណៈនីមួយៗ។

កម្រងសេវាសាធារណៈរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវបានរៀបចំចែកចេញជាពីរផ្នែក ដោយ ផ្នែកទី១ ជាកម្រងសេវាសាធារណៈដែលអនុវត្តដោយរដ្ឋបាលកណ្តាលក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងផ្នែកទី២ ជាកម្រងសេវាសាធារណៈដែលអនុវត្តដោយមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានី ខេត្ត ដូចមានចែងក្នុងឧបសម្ព័ន្ធ១ និងឧបសម្ព័ន្ធ២ ដែលភ្ជាប់នឹងប្រកាសរួមនេះ។

**ប្រការ៣ .-**

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវផ្សព្វផ្សាយជាសាធារណៈ ជាពិសេសនៅកន្លែងផ្តល់សេវាសាធារណៈ ត្រូវបិទផ្សាយប្រកាសរួម ព្រមទាំងកម្រងសេវាសាធារណៈ ដែលរួមមានឧបសម្ព័ន្ធ១ និងឧបសម្ព័ន្ធ២ នៃប្រកាសរួមនេះ ព្រមទាំងទម្រង់ឯកសារ និងនីតិវិធី សម្រាប់ការផ្តល់សេវាដែលមានការពាក់ព័ន្ធ។

នៅកន្លែងផ្តល់សេវាសាធារណៈ ត្រូវរៀបចំឱ្យមានកន្លែងទទួលបណ្តឹងតវ៉ា ដែលអាចកើតមានឡើងជាយថាហេតុ ជាពិសេសក្នុងករណីមានការអនុវត្តខុសពីស្តង់ដារសេវា ឬ មានការយកកម្រៃលើសការកំណត់ ឬ មានការយឺតយ៉ាវក្នុងការផ្តល់សេវាសាធារណៈជាដើម។

ការទទួលបណ្តឹងតវ៉ារបស់អតិថិជន ត្រូវមានការបើកទូលាយដោយមានដាក់លេខទូរស័ព្ទ សារអេឡិចត្រូនិក បណ្តាញសង្គម ប្រអប់សំបុត្រ និងផ្តល់ឱកាសឱ្យអតិថិជនអាចធ្វើទំនាក់ទំនង ឬ ប្តឹងទៅប្រធានស្ថាប័ន ឬ ប្តឹងទៅអង្គភាពប្រឆាំងអំពើពុករលួយផងដែរ។

**ប្រការ៤ .-**

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវកំណត់ទីតាំងជាក់លាក់ និងមានមន្ត្រីប្រចាំការដែលមានលក្ខណៈជាច្រកចេញចូលតែមួយនៅទីតាំងដែលបានកំណត់ ដើម្បីទទួលបម្រើសេវាជូនអតិថិជនឱ្យបានទាន់ពេលវេលា តាមការកំណត់។

**ប្រការ៥ .-**

រាល់ការទទួលប្រាក់ចំណូលជាសាច់ប្រាក់ ឬ ជាមូលប្បទានប័ត្រ លើការប្រមូលចំណូលពីកម្រៃសេវាសាធារណៈ ត្រូវប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ដែលបើកផ្តល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្របតាមប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ និងសារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ៦ .-**

រដ្ឋបាលកណ្តាលក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ រាជធានី ខេត្ត ត្រូវទទួលខុសត្រូវប្រាក់កាសលើប្រាក់ចំណូលដែលប្រមូលបាន បង់ប្រាក់ចំណូល និងធ្វើសលាកប័ត្រចំណូលថវិកាជាតិ ព្រមទាំងចុះកិច្ចបញ្ជិកាគណនេយ្យស្តីពីកិច្ចប្រតិបត្តិការចំណូល និងកត់ត្រាតាមដានប្រាក់ចំណូលនៅក្នុងជំពូក គណនី អនុគណនី នៃមាតិកាចំណូលថវិកា។

**ប្រការ៧ .-**

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តចំណូលប្រចាំខែ និងប្រចាំឆ្នាំ ផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានី ខេត្ត ត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តចំណូលប្រចាំខែ និងប្រចាំឆ្នាំ ផ្ញើជូនក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

**ប្រការ៨ .-**

កម្រងសេវាសាធារណៈដូចមានចែងក្នុងឧបសម្ព័ន្ធ ១ និងឧបសម្ព័ន្ធ ២ នៃប្រកាសរួមនេះ អាចកែប្រែបានតាមការចាំបាច់ ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

**ប្រការ៩ .-**

ត្រូវបាននិរាករណ៍ប្រកាសរួមទាំងឡាយដូចខាងក្រោម ÷

- ប្រកាសរួមលេខ ៩៨៧ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ប្រកាសរួមលេខ ៥២២ សហវ.ប្រក ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៤ ស្តីពីការកែប្រែកម្រងសេវាសាធារណៈនៃតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ ៩៨៧ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

**ប្រការ ១០ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសរួមនេះ ត្រូវទុកជានិរាករណ៍។

ប្រការ១១ .-

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវទទួលបន្ទុកអនុវត្តប្រកាសរួមនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃទី.០៦...ខែ.មិថុនា....ឆ្នាំ២០១៦ តទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ២០១៦

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

រដ្ឋមន្ត្រី
ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

ភឿង-សកុណា

កន្លែងទទួល :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- សាលារាជធានី ខេត្ត
- ដូចប្រការ ១១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ១ ភ្ជាប់នឹងប្រកាសរួមលេខ.៦៥៤......សហវ.ប្រក ចុះថ្ងៃទី.០៦....... ខែមិថុនា...... ឆ្នាំ២០១៦

ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

កម្រងសេវាសាធារណៈដែលអនុវត្តដោយរដ្ឋបាលកណ្តាលក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

| ល.រ | បរិយាយប្រភេទសេវា | តម្លៃសេវា | រយៈពេលអតិបរមា នៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| I. ផ្នែកសារមន្ទីរ | | | | |
| ក. | ការលក់សំបុត្រចូលទស្សនាសារមន្ទីរជាតិ | | | |
| 1 | សម្រាប់ជនជាតិខ្មែរ (អាយុក្រោម ១៨ឆ្នាំ) | ឥតគិតថ្លៃ | ភ្លាមៗ | 1ថ្ងៃ |
| 2 | សម្រាប់ជនជាតិខ្មែរ (អាយុចាប់ពី ១៨ឆ្នាំឡើងទៅ) | 500៛ | ភ្លាមៗ | 1ថ្ងៃ |
| 3 | សម្រាប់ជនជាតិបរទេស (អាយុក្រោម ១៨ឆ្នាំ) | 3$ | ភ្លាមៗ | 1ថ្ងៃ |
| 4 | សម្រាប់ជនជាតិបរទេស (អាយុចាប់ពី ១៨ឆ្នាំឡើងទៅ) | 5$ | ភ្លាមៗ | 1ថ្ងៃ |
| ខ. | ការលក់សំបុត្រចូលទស្សនាសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង | | | |
| 5 | សម្រាប់ជនជាតិខ្មែរ (គ្រប់វ័យ) | ឥតគិតថ្លៃ | ភ្លាមៗ | 1ថ្ងៃ |
| 6 | សម្រាប់ជនជាតិបរទេស (អាយុក្រោម ១៨ឆ្នាំ) | 1.5$ | ភ្លាមៗ | 1ថ្ងៃ |
| 7 | សម្រាប់ជនជាតិបរទេស (អាយុចាប់ពី ១៨ឆ្នាំឡើងទៅ) | 3$ | ភ្លាមៗ | 1ថ្ងៃ |

| ល.រ | បរិយាយប្រភេទសេវា | តម្លៃសេវា | រយៈពេលអតិបរមា នៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| II. **ផ្នែកសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល** | | | | |
| ក. | ការផ្តល់លិខិតអនុញ្ញាតសិទ្ធិប្រើប្រាស់លើស្នាដៃអក្សរសាស្ត្រគ្មានអ្នកទទួលមរតក ឬ គ្មានមតកសាសន៍ | | | |
| 8 | ផលិតឡើងវិញនូវស្នាដៃវចនានុក្រម (១ចំណងជើង) | 310 000៛ | 5ថ្ងៃ | 1ឆ្នាំ |
| 9 | ស្នាដៃវចនានុក្រមផលិតជាកម្មវិធីកុំព្យូទ័រ (១ចំណងជើង) | 410 000៛ | 5ថ្ងៃ | 1ឆ្នាំ |
| 10 | បន្តសុពលភាព | 205 000៛ | 5ថ្ងៃ | 1ឆ្នាំ |
| 11 | ផលិតឡើងវិញនូវស្នាដៃវចនានុក្រមផលិតជាកម្មវិធីកុំព្យូទ័រ (១ចំណងជើង) | 160 000៛ | 5ថ្ងៃ | 1ឆ្នាំ |
| 12 | បន្តសុពលភាព | 80 000៛ | 5ថ្ងៃ | 1ឆ្នាំ |
| 13 | ផលិតជាខ្សែភាពយន្ត (១រឿង) | 410 000៛ | 5ថ្ងៃ | 6ខែ |
| 14 | បន្តសុពលភាព | 205 000៛ | 5ថ្ងៃ | 1ឆ្នាំ |
| 15 | ផលិតជាខ្សែវីដេអូ (១រឿង) | 330 000៛ | 5ថ្ងៃ | 6ខែ |
| 16 | បន្តសុពលភាព | 165 000៛ | 5ថ្ងៃ | 1ឆ្នាំ |
| ខ. | ការផ្តល់លិខិតអនុញ្ញាតសិទ្ធិធ្វើអាជីវកម្មលើស្នាដៃតូរ្យតន្ត្រីគ្មានអ្នកទទួលមរតក ឬ គ្មានមរតកសាសន៍ | | | |
| 17 | ផលិតឡើងវិញនូវតន្ត្រីមានទំនុកច្រៀង ឬ គ្មានទំនុកច្រៀង (១បទ) | 30 000៛ | 5ថ្ងៃ | 1ឆ្នាំ |
| 18 | ផលិតជាស្នាដៃបន្តនូវតន្ត្រីមានទំនុកច្រៀង ឬ គ្មានទំនុកច្រៀង (១បទ) | 35 000៛ | 5ថ្ងៃ | 1ឆ្នាំ |

| ល.រ | បរិយាយប្រភេទសេវា | តម្លៃសេវា | រយៈពេលអនុវត្ត នៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| 19 | សំដែងតន្ត្រីមានទំនុកច្រៀង ឬ គ្មានទំនុកច្រៀង (១បទ) | 20 000៛ | 5ថ្ងៃ | 1ឆ្នាំ |
| 20 | តួរ្យតន្ត្រីដើមមានទំនុកច្រៀង ឬ គ្មានទំនុកច្រៀងបញ្ចូលប្រព័ន្ធអ៊ីនធើណេត (១បទ) | 10 000៛ | 5ថ្ងៃ | 1ឆ្នាំ |
| 21 | តូរ្យតន្ត្រីបន្តមានទំនុកច្រៀង ឬ គ្មានទំនុកច្រៀងបញ្ចូលប្រព័ន្ធអ៊ីនធើណេត (១បទ) | 10 000៛ | 5ថ្ងៃ | 1ឆ្នាំ |
| 22 | ការផ្សព្វផ្សាយតាមទូរផ្សាយស្នាដៃនូវតន្ត្រីមានទំនុកច្រៀង ឬ គ្មានទំនុកច្រៀង (១បទ) | 10 000៛ | 5ថ្ងៃ | 1ឆ្នាំ |
| 23 | ការផ្សព្វផ្សាយជាសាធារណៈតាមវិធីផ្សេងៗនូវស្នាដៃតន្ត្រីមានទំនុកច្រៀង ឬ គ្មានទំនុកច្រៀង (១បទ) ក្នុងស្រុក | 41 000៛ | 5ថ្ងៃ | 1ឆ្នាំ |
| 24 | ការផ្សព្វផ្សាយជាសាធារណៈតាមវិធីផ្សេងៗនូវស្នាដៃតន្ត្រីមានទំនុកច្រៀង ឬ គ្មានទំនុកច្រៀង (១បទ) ជាសាកល | 410 000៛ | 5ថ្ងៃ | 3ឆ្នាំ |
| គ. | ការផ្តល់លិខិតអនុញ្ញាតសិទ្ធិធ្វើអាជីវកម្មលើស្នាដៃសោតទស្សន៍គ្មានអ្នកទទួលមរតក ឬ គ្មានមតកសាសន៍ | | | |
| 25 | ការចាក់ផ្សាយតាមទូរផ្សាយ | 410 000៛ | 5ថ្ងៃ | 1ខែ |
| 26 | ការចាក់ផ្សាយតាមរោងភាពយន្ត | 820 000៛ | 5ថ្ងៃ | 1ខែ |
| 27 | បន្តសុពលភាព | 410 000៛ | 3ថ្ងៃ | 1ខែ |
| 28 | ការចាក់ផ្សាយតាមទីសាធារណៈ | 410 000៛ | 5ថ្ងៃ | 1ខែ |
| 29 | បន្តសុពលភាព | 205 000៛ | 3ថ្ងៃ | 1ខែ |

| ល.រ | បរិយាយប្រភេទសេវា | តម្លៃសេវា | រយៈពេលអតិបរមា នៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ឃ. | ការផ្តល់លិខិតអនុញ្ញាតសិទ្ធិធ្វើអាជីវកម្មលើស្នាដៃទស្សនីយភាពគ្មានអ្នកទទួលមរតក ឬ គ្មានមតកសាសន៍ | | | |
| 30 | សម្តែងមួយរឿង | 110 000៛ | 5ថ្ងៃ | 1ខែ |
| 31 | សម្តែងមួយឈុត | 30 000៛ | 5ថ្ងៃ | 1ខែ |
| ង. | ការផ្តល់លិខិតអនុញ្ញាតសិទ្ធិធ្វើអាជីវកម្មលើស្នាដៃសិល្បៈសូនរូបគ្មានអ្នកទទួលមរតក ឬ គ្មានមតកសាសន៍ | | | |
| 32 | ចម្លាក់បោះពុម្ពព្រះសិរសាព្រះបាទជ័យវរ្ម័នទី៧ ខ្នាតតូច ចាប់ពីកំពស់០១សម ទៅ ២០សម | 30 000៛ | 5ថ្ងៃ | 1ឆ្នាំ |
| 33 | ចម្លាក់បោះពុម្ពព្រះសិរសាព្រះបាទជ័យវរ្ម័នទី៧ ខ្នាតតូច ចាប់ពីកំពស់២១សម ឡើងទៅ | 50 000៛ | 5ថ្ងៃ | 1ឆ្នាំ |
| ច. | ការផ្តល់លិខិតបញ្ជាក់ការចុះបញ្ជីការពារស្នាដៃ | | | |
| 34 | សៀវភៅ, អត្ថបទ, គំនូរ, រូបថត, ផែនទី (១ស្នាដៃ/ ១ច្បាប់) | 20 000៛ | 5ថ្ងៃ | អចិន្ត្រៃយ៍ |
| 35 | ស្ថាបត្យកម្ម (១ស្នាដៃ/ ១ច្បាប់) | 60 000៛ | 5ថ្ងៃ | អចិន្ត្រៃយ៍ |
| 36 | ស្នាដៃសិល្បៈសិប្បកម្ម (១ស្នាដៃ/ ១ច្បាប់) | 20 000៛ | 5ថ្ងៃ | អចិន្ត្រៃយ៍ |
| 37 | កម្មវិធីកុំព្យូទ័រ (១ស្នាដៃ/ ១កម្មវិធី) | 60 000៛ | 5ថ្ងៃ | អចិន្ត្រៃយ៍ |
| 38 | ស្នាដៃហ្វូណូក្រាម និងសោតទស្សន៍ (១អាល់ប៊ុម/ ១ឌីស) | 30 000៛ | 5ថ្ងៃ | អចិន្ត្រៃយ៍ |
| 39 | ស្នាដៃឌីជីថល (វេបសាយ) (១កម្មវិធី/ ១វេបសាយ) | 60 000៛ | 5ថ្ងៃ | អចិន្ត្រៃយ៍ |
| ឆ. | ការផ្តល់លិខិតអនុញ្ញាត | | | |
| 40 | លិខិតអនុញ្ញាតនាំចេញ/ នាំចូល (សៀវភៅ ឬ អត្ថបទ) | 60 000៛ | 5ថ្ងៃ | 1ឆ្នាំ |

| ល.រ | បរិយាយប្រភេទសេវា | តម្លៃសេវា | រយៈពេលអតិបរមា នៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| 41 | លិខិតអនុញ្ញាតនាំចេញ/ នាំចូល (ឌីសអុបទិក) | 60 000៛ | 5ថ្ងៃ | 1ឆ្នាំ |
| 42 | លិខិតអនុញ្ញាតនាំចេញ/ នាំចូល (ឧបករណ៍ថតចម្លង) | 60 000៛ | 5ថ្ងៃ | 1ឆ្នាំ |
| 43 | លិខិតអនុញ្ញាតបើកអាជីវកម្មឧបករណ៍ថតចម្លង | 60 000៛ | 5ថ្ងៃ | 1ឆ្នាំ |
| 44 | បន្តសុពលភាពលិខិតអនុញ្ញាតបើកអាជីវកម្មឧបករណ៍ថតចម្លង | 30 000៛ | 3ថ្ងៃ | 1ឆ្នាំ |
| 45 | លិខិតអនុញ្ញាតបើកអាជីវកម្មសេវាថតចម្លង | 60 000៛ | 5ថ្ងៃ | 1ឆ្នាំ |
| 46 | បន្តសុពលភាពលិខិតអនុញ្ញាតបើកអាជីវកម្មសេវាថតចម្លង | 30 000៛ | 3ថ្ងៃ | 1ឆ្នាំ |
| 47 | លិខិតអនុញ្ញាតបោះពុម្ព (សៀវភៅ ឬ អត្ថបទ) | 60 000៛ | 5ថ្ងៃ | 1ឆ្នាំ |
| 48 | បន្តសុពលភាពលិខិតអនុញ្ញាតបោះពុម្ព (សៀវភៅ ឬ អត្ថបទ) | 30 000៛ | 3ថ្ងៃ | 1ឆ្នាំ |
| ជ. | ការប្រើប្រាស់រូបប្រាសាទបេតិកភ័ណ្ឌដើម្បីធ្វើអាជីវកម្ម | | | |
| 49 | ការប្រើប្រាស់រូបភាពប្រាសាទដែលជាបេតិកភ័ណ្ឌ (ក្នុងមួយរូបភាព) | 110 000៛ | 5ថ្ងៃ | 2ឆ្នាំ |
| **III. ផ្នែកសិល្បៈភាពយន្ត និងផ្សព្វផ្សាយវប្បធម៌** | | | | |
| ក. | ការផ្តល់អាជ្ញាប័ណ្ណ | | | |
| ក1. | បើកថ្មី | | | |
| 50 | ផលិតកម្មភាពយន្តវីដេអូ | 800 000៛ | 10ថ្ងៃ | 2ឆ្នាំ |
| 51 | ក្រុមហ៊ុននាំចេញ- នាំចូលភាពយន្តវីដេអូ | 2 000 000៛ | 10ថ្ងៃ | 2ឆ្នាំ |

| ល.រ | បរិយាយប្រភេទសេវា | តម្លៃសេវា | រយៈពេលផ្តល់សេវា នៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| 52 | ស្ទូឌីយោបញ្ចូលសំឡេងភាពយន្ត វីដេអូ | 600 000៛ | 10ថ្ងៃ | 2ឆ្នាំ |
| 53 | ស្ទូឌីយោដំឡើងរូបភាព ភាពយន្ត វីដេអូ | 600 000៛ | 10ថ្ងៃ | 2ឆ្នាំ |
| 54 | រោងបញ្ចាំងភាពយន្ត វីដេអូ ដែលមានកន្លែងអង្គុយក្រោម ២០០កៅអី | 1 200 000៛ | 10ថ្ងៃ | 2ឆ្នាំ |
| 55 | រោងបញ្ចាំងភាពយន្ត វីដេអូ ដែលមានកន្លែងអង្គុយចាប់ពី ២០០កៅអីឡើងទៅ | 1 800 000៛ | 10ថ្ងៃ | 2ឆ្នាំ |
| 56 | ផ្ទេរសិទ្ធិគ្រប់គ្រងផលិតកម្ម អាជីវកម្ម សេវាកម្ម ភាពយន្ត វីដេអូ (បណ្តោះអាសន្ន) | 100 000៛ | 3ថ្ងៃ | 6ខែ |
| 57 | ផ្ទេរសិទ្ធិគ្រប់គ្រងផលិតកម្ម អាជីវកម្ម សេវាកម្ម ភាពយន្ត វីដេអូ (អចិន្ត្រៃយ៍) | 400 000៛ | 10ថ្ងៃ | |
| 58 | ប្តូរនាមករណ៍ផលិតកម្ម អាជីវកម្ម សេវាកម្ម ភាពយន្ត វីដេអូ | 400 000៛ | 10ថ្ងៃ | |
| 59 | ប្តូរទីតាំងផលិតកម្ម អាជីវកម្ម សេវាកម្ម ភាពយន្ត វីដេអូ | ឥតគិតថ្លៃ | 10ថ្ងៃ | |
| ក2. | បន្តសុពលភាពអាជ្ញាប័ណ្ណ | | | |
| 60 | ផលិតកម្មភាពយន្ត វីដេអូ | 150 000៛ | 5ថ្ងៃ | 1ឆ្នាំ |
| 61 | ក្រុមហ៊ុននាំចេញ- នាំចូលភាពយន្ត វីដេអូ | 400 000៛ | 5ថ្ងៃ | 1ឆ្នាំ |
| 62 | បន្ទប់បញ្ចូលសំឡេងភាពយន្ត វីដេអូ | 200 000៛ | 5ថ្ងៃ | 1ឆ្នាំ |
| 63 | បន្ទប់កាត់ត- ដំឡើងរូបភាព ភាពយន្ត វីដេអូ | 200 000៛ | 5ថ្ងៃ | 1ឆ្នាំ |
| 64 | រោងបញ្ចាំងភាពយន្តវីដេអូដែលមានកន្លែងអង្គុយតិចជាង ២០០កៅអី | 500 000៛ | 5ថ្ងៃ | 1ឆ្នាំ |
| 65 | រោងបញ្ចាំងភាពយន្តវីដេអូដែលមានកន្លែងអង្គុយចាប់ពី ២០០កៅអីឡើងទៅ | 700 000៛ | 5ថ្ងៃ | 1ឆ្នាំ |

| ល.រ | បរិយាយប្រភេទសេវា | តម្លៃសេវា | រយៈពេលអតិបរមា នៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ខ. | សេវាពិនិត្យអត្ថបទនិពន្ធភាពយន្ត វីដេអូ និងផ្តល់លិខិតអនុញ្ញាតថតភាពយន្ត វីដេអូ | | | |
| ខ1 | ផលិតកម្មភាពយន្ត ឬ វីដេអូខ្មែរ | | | |
| 66 | អត្ថបទនិពន្ធភាពយន្ត វីដេអូរឿងខ្នាតវែង | 200 000៛ | 15ថ្ងៃ | |
| 67 | អត្ថបទនិពន្ធភាពយន្ត វីដេអូឯកសារខ្នាតវែង | 80 000៛ | 5ថ្ងៃ | |
| 68 | អត្ថបទនិពន្ធភាពយន្ត វីដេអូរឿងភាគ (១ភាគ) | 60 000៛ | 5ថ្ងៃ | |
| 69 | អត្ថបទនិពន្ធភាពយន្ត វីដេអូ ខារ៉ាអូខេ ឯកសារខ្នាតខ្លី ភាពយន្តខ្នាតខ្លី ស្ប៉ុត | 40 000៛ | 5ថ្ងៃ | |
| ខ2. | ផលិតកម្មភាពយន្ត ឬ វីដេអូបរទេស | | | |
| 70 | អត្ថបទនិពន្ធភាពយន្ត វីដេអូរឿងខ្នាតវែង | 800 000៛ | 15ថ្ងៃ | |
| 71 | អត្ថបទនិពន្ធភាពយន្ត វីដេអូឯកសារខ្នាតវែង | 300 000៛ | 10ថ្ងៃ | |
| 72 | អត្ថបទនិពន្ធភាពយន្ត វីដេអូរឿងភាគ (១ភាគ) | 300 000៛ | 10ថ្ងៃ | |
| 73 | អត្ថបទនិពន្ធភាពយន្ត វីដេអូ ខារ៉ាអូខេ ឯកសារខ្នាតខ្លី ភាពយន្តខ្នាតខ្លី ស្ប៉ុត | 200 000៛ | 5ថ្ងៃ | |
| គ. | សេវាពិនិត្យខ្លឹមសារ-រូបភាព ចំណាត់ថ្នាក់ និងផ្តល់ទិដ្ឋាការភាពយន្ត | | | |
| គ1. | ស្នាដៃភាពយន្ត ឬ វីដេអូខ្មែរ | | | |
| | ស្នាដៃភាពយន្ត ឬ វីដេអូរឿងខ្នាតវែង សម្រាប់បញ្ចាំងតាមរោងភាពយន្ត | | | |
| 74 | សម្រាប់ទស្សនិកជនទូទៅ | 100 000៛ | 5ថ្ងៃ | |

| ល.រ | បរិយាយប្រភេទសេវា | តម្លៃសេវា | រយៈពេលអតិបរមា នៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| 75 | សម្រាប់ទស្សនិកជនចាប់ពីអាយុ ១៥ឆ្នាំឡើង | 150 000៛ | 5ថ្ងៃ | |
| 76 | សម្រាប់ទស្សនិកជនចាប់ពីអាយុ ១៨ឆ្នាំឡើង | 200 000៛ | 5ថ្ងៃ | |
| | ស្នាដៃភាពយន្ត ឬ វីដេអូរឿងខ្នាតវែង សម្រាប់បញ្ចាំងតាមទូរទស្សន៍ ទូរទស្សន៍ខ្សែកាប និងធ្វើអាជីវកម្មជួល-លក់ | | | |
| 77 | សម្រាប់ទស្សនិកជនទូទៅ | 100 000៛ | 5ថ្ងៃ | |
| 78 | សម្រាប់ទស្សនិកជនចាប់ពីអាយុ ១៥ឆ្នាំឡើង | 150 000៛ | 5ថ្ងៃ | |
| | ស្នាដៃភាពយន្ត ឬ វីដេអូរឿងខ្នាតខ្លី | | | |
| 79 | សម្រាប់ទស្សនិកជនទូទៅ | 60 000៛ | 3ថ្ងៃ | |
| 80 | សម្រាប់ទស្សនិកជនចាប់ពីអាយុ ១៥ឆ្នាំឡើង | 75 000៛ | 3ថ្ងៃ | |
| 81 | សម្រាប់ទស្សនិកជនចាប់ពីអាយុ ១៨ឆ្នាំឡើង | 90 000៛ | 3ថ្ងៃ | |
| | ស្នាដៃភាពយន្ត ឬ វីដេអូរឿងភាគ សម្រាប់បញ្ចាំងតាមទូរទស្សន៍ ទូរទស្សន៍ខ្សែកាប និងធ្វើអាជីវកម្មជួល លក់ (១ភាគ) | | | |
| 82 | សម្រាប់ទស្សនិកជនទូទៅ | 60 000៛ | 3ថ្ងៃ | |
| 83 | ស្នាដៃភាពយន្ត ឬ វីដេអូឯកសារខ្នាតវែង | 50 000៛ | 3ថ្ងៃ | |
| 84 | ស្នាដៃភាពយន្ត ឬ វីដេអូឯកសារខ្នាតខ្លី គំនូរជីវចល តុក្កតា ស្ប៉តពាណិជ្ជកម្ម | 30 000៛ | 3ថ្ងៃ | |
| 85 | ស្នាដៃភាពយន្ត ឬ វីដេអូចម្រៀងកាយវិការ ឬ ខារ៉ាអូខេគ្រប់ទម្រង់ | 50 000៛ | 3ថ្ងៃ | |
| 86 | សេវាប្រថាប់ត្រាលើផលិតផលភាពយន្ត ឬ វីដេអូទម្រង់ VCD ឬ DVD/០១ច្បាប់ | 50៛ | 2ថ្ងៃ | |

| ល.រ | បរិយាយប្រភេទសេវា | តម្លៃសេវា | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| គ2. | ស្នាដៃភាពយន្ត ឬ វីដេអូបរទេស | | | |
| | ការចុះបញ្ជីស្នាដៃភាពយន្ត វីដេអូ (១ចំណងជើង ឬ ១រឿង) | | | |
| 87 | ស្នាដៃភាពយន្ត វីដេអូរឿងខ្នាតវែង | 20 000៛ | 2ថ្ងៃ | |
| 88 | ស្នាដៃភាពយន្ត វីដេអូរឿងខ្នាតខ្លី | 10 000៛ | 2ថ្ងៃ | |
| 89 | ស្នាដៃភាពយន្ត វីដេអូរឿងភាគ | 20 000៛ | 2ថ្ងៃ | |
| 90 | ស្នាដៃភាពយន្ត វីដេអូឯកសារខ្នាតវែង | 10 000៛ | 2ថ្ងៃ | |
| 91 | ស្នាដៃភាពយន្ត វីដេអូឯកសារខ្នាតខ្លី គំនូរជីវចល តុក្កតា ស្ប៉តពាណិជ្ជកម្ម | 5 000៛ | 2ថ្ងៃ | |
| 92 | ស្នាដៃភាពយន្ត វីដេអូចម្រៀងកាយវិការ ឬ ខារ៉ាអូខេគ្រប់ទម្រង់ | 5 000៛ | 2ថ្ងៃ | |
| | សេវាត្រួតពិនិត្យរឿងសន្ទនាជាភាសាខ្មែរ ឬ បរទេស | | | |
| | - ការបញ្ចូលពាក្យសន្ទនាជាភាសាខ្មែរ | | | |
| 93 | ស្នាដៃភាពយន្ត វីដេអូរឿងខ្នាតវែង | 500 000៛ | 5ថ្ងៃ | |
| 94 | ស្នាដៃភាពយន្ត វីដេអូរឿងខ្នាតខ្លី | 200 000៛ | 3ថ្ងៃ | |
| 95 | ស្នាដៃភាពយន្ត វីដេអូរឿងភាគ | 400 000៛ | 3ថ្ងៃ | |
| 96 | ស្នាដៃភាពយន្ត វីដេអូឯកសារខ្នាតវែង | 150 000៛ | 3ថ្ងៃ | |
| 97 | ស្នាដៃភាពយន្ត វីដេអូឯកសារខ្នាតខ្លី គំនូរជីវចល តុក្កតា ស្ប៉តពាណិជ្ជកម្ម | 100 000៛ | 3ថ្ងៃ | |
| 98 | ស្នាដៃភាពយន្ត វីដេអូចម្រៀងកាយវិការ ឬ ខារ៉ាអូខេគ្រប់ទម្រង់ | 100 000៛ | 3ថ្ងៃ | |

| ល.រ | បរិយាយប្រភេទសេវា | តម្លៃសេវា | រយៈពេលអតិបរមា នៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| | - ការរក្សាពាក្យសន្ទនាជាភាសាដើម ឬ ដាក់ចំណងជើងរងជាភាសាខ្មែរ | | | |
| 99 | ស្នាដៃភាពយន្ត វីដេអូរឿងខ្នាតវែង | 200 000៛ | 5ថ្ងៃ | |
| 100 | ស្នាដៃភាពយន្ត វីដេអូរឿងខ្នាតខ្លី | 30 000៛ | 3ថ្ងៃ | |
| 101 | ស្នាដៃភាពយន្ត វីដេអូរឿងភាគ | 100 000៛ | 3ថ្ងៃ | |
| 102 | ស្នាដៃភាពយន្ត វីដេអូឯកសារខ្នាតវែង | 100 000៛ | 3ថ្ងៃ | |
| 103 | ស្នាដៃភាពយន្ត វីដេអូឯកសារខ្នាតខ្លី គំនូរជីវចល តុក្កតា ស្ប៉តពាណិជ្ជកម្ម | 50 000៛ | 3ថ្ងៃ | |
| 104 | ស្នាដៃភាពយន្ត វីដេអូចម្រៀងកាយវិការ ឬ ខារ៉ាអូខេគ្រប់ទម្រង់ | 100 000៛ | 3ថ្ងៃ | |
| | អាជ្ញាប័ណ្ណអាជីវកម្មស្នាដៃភាពយន្ត វីដេអូរឿងខ្នាតវែង | | | |
| | - បញ្ចាំងតាមរោងភាពយន្ត | | | |
| 105 | សម្រាប់ទស្សនិកជនទូទៅ | 800 000៛ | 1ថ្ងៃ | 1ឆ្នាំ |
| 106 | សម្រាប់ទស្សនិកជនទូទៅ | 1 400 000៛ | 1ថ្ងៃ | 2ឆ្នាំ |
| 107 | សម្រាប់ទស្សនិកជនចាប់ពីអាយុ ១៥ឆ្នាំឡើង | 900 000៛ | 1ថ្ងៃ | 1ឆ្នាំ |
| 108 | សម្រាប់ទស្សនិកជនចាប់ពីអាយុ ១៥ឆ្នាំឡើង | 1 500 000៛ | 1ថ្ងៃ | 2ឆ្នាំ |
| 109 | សម្រាប់ទស្សនិកជនចាប់ពីអាយុ ១៨ឆ្នាំឡើង | 1 000 000៛ | 1ថ្ងៃ | 1ឆ្នាំ |
| 110 | សម្រាប់ទស្សនិកជនចាប់ពីអាយុ ១៨ឆ្នាំឡើង | 1 600 000៛ | 1ថ្ងៃ | 2ឆ្នាំ |

| ល.រ | បរិយាយប្រភេទសេវា | តម្លៃសេវា | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| | - បញ្ចាំងតាមស្ថានីយ៍ទូរទស្សន៍ ទូរទស្សន៍ខ្សែកាប | | | |
| 111 | សម្រាប់ទស្សនិកជនទូទៅ | 250 000៛ | 1ថ្ងៃ | 1ឆ្នាំ |
| 112 | សម្រាប់ទស្សនិកជនទូទៅ | 400 000៛ | 1ថ្ងៃ | 2ឆ្នាំ |
| 113 | សម្រាប់ទស្សនិកជនចាប់ពីអាយុ ១៥ឆ្នាំឡើង | 260 000៛ | 1ថ្ងៃ | 1ឆ្នាំ |
| 114 | សម្រាប់ទស្សនិកជនចាប់ពីអាយុ ១៥ឆ្នាំឡើង | 450 000៛ | 1ថ្ងៃ | 2ឆ្នាំ |
| | - ធ្វើអាជីវកម្មជួល-លក់ | | | |
| 115 | សម្រាប់ទស្សនិកជនទូទៅ | 240 000៛ | 1ថ្ងៃ | 2ឆ្នាំ |
| 116 | សម្រាប់ទស្សនិកជនចាប់ពីអាយុ ១៥ឆ្នាំឡើង | 260 000៛ | 1ថ្ងៃ | 2ឆ្នាំ |
| | អាជ្ញាប័ណ្ណអាជីវកម្មស្នាដៃភាពយន្ត វីដេអូរឿងភាគ (បញ្ចាំងតាមស្ថានីយ៍ទូរទស្សន៍ ទូរទស្សន៍ខ្សែកាប ឬ ធ្វើអាជីវកម្មជួល លក់) | | | |
| 117 | សម្រាប់ទស្សនិកជនទូទៅ | 400 000៛ | 1ថ្ងៃ | 2ឆ្នាំ |
| 118 | សេវាប្រថាប់ត្រាលើផលិតផលភាពយន្ត ឬ វីដេអូទម្រង់ VCD ឬ DVD/ ០១ច្បាប់ | 50៛ | 2ថ្ងៃ | |

| ល.រ | បរិយាយប្រភេទសេវា | តម្លៃសេវា | | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|---|
| IV. ផ្នែកបុរាណវត្ថុ | | | | | |
| ក. | ពិនិត្យ និងផ្តល់លិខិតអនុញ្ញាតឱ្យនាំវត្ថុសិល្បៈចេញទៅបរទេស | ប្រភេទវត្ថុសិល្បៈផលិតថ្មី | ប្រភេទវត្ថុសិល្បៈចម្លងដូច | | |
| ក1. | វត្ថុសិល្បៈធ្វើពីឈើ ឬ លោហៈ ឬ ថ្ម | | | | |
| 119 | កម្ពស់ចាប់ពី ០១ ដល់ ៥០ ស.ម. | 5 000៛ | 30 000៛ | 5ថ្ងៃ | 1ខែ |
| 120 | កម្ពស់ចាប់ពី ៥១ ដល់ ១៥០ ស.ម. | 12 000៛ | 80 000៛ | 5ថ្ងៃ | 1ខែ |
| 121 | កម្ពស់ចាប់ពី ១៥១ ស.ម. ឡើងទៅ | 30 000៛ | 100 000៛ | 5ថ្ងៃ | 1ខែ |
| ក2. | វត្ថុសិល្បៈធ្វើពីដីដុត ឬ ខ្ទុកសាច់ ឬ គំនូរលើក្រណាត់ ឬ លើក្ដារ ឬ លើសូត្រ | | | | |
| 122 | កម្ពស់ចាប់ពី ០១ ដល់ ៥០ ស.ម. | 4 000៛ | 8 000៛ | 5ថ្ងៃ | 1ខែ |
| 123 | កម្ពស់ចាប់ពី ៥១ ដល់ ១០០ ស.ម. | 6 000៛ | 20 000៛ | 5ថ្ងៃ | 1ខែ |
| 124 | កម្ពស់ចាប់ពី ១០១ ស.ម. ឡើងទៅ | 20 000៛ | 95 000៛ | 5ថ្ងៃ | 1ខែ |
| ខ. | ពិនិត្យ និងផ្តល់លិខិតអនុញ្ញាតឱ្យនាំវត្ថុសិល្បៈចូលពីបរទេស | | | | |
| ខ1. | វត្ថុសិល្បៈធ្វើពីឈើ ឬ លោហៈ ឬ ថ្ម | | | | |
| 125 | កម្ពស់ចាប់ពី ០១ ដល់ ៥០ ស.ម. | 9 000៛ | មិនអនុញ្ញាត | 5ថ្ងៃ | 1ខែ |

| ល.រ | បរិយាយប្រភេទសេវា | តម្លៃសេវា | | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|---|
| 126 | កម្ពស់ចាប់ពី ៥១ ដល់ ១៥០ ស.ម. | 20 000៛ | មិនអនុញ្ញាត | 5ថ្ងៃ | 1ខែ |
| 127 | កម្ពស់ចាប់ពី ១៥១ ដល់ ២០០ ស.ម. | 40 000៛ | មិនអនុញ្ញាត | 5ថ្ងៃ | 1ខែ |
| 128 | កម្ពស់ចាប់ពី ២០១ ស.ម. ឡើងទៅ | មិនអនុញ្ញាត | មិនអនុញ្ញាត | | |
| ១២. | វត្ថុសិល្បៈធ្វើពីដីដុត ឬ ខ្មុកសាច់ ឬ គំនូរលើក្រណាត់ ឬ លើក្ដារ ឬ លើស្ងួត្រ | | | | |
| 129 | កម្ពស់ចាប់ពី ០១ ដល់ ៥០ ស.ម. | 6 000៛ | មិនអនុញ្ញាត | 5ថ្ងៃ | 1ខែ |
| 130 | កម្ពស់ចាប់ពី ៥១ ដល់ ១០០ ស.ម. | 8 000៛ | មិនអនុញ្ញាត | 5ថ្ងៃ | 1ខែ |
| 131 | កម្ពស់ចាប់ពី ១០១ ដល់ ២០០ ស.ម. | 25 000៛ | មិនអនុញ្ញាត | 5ថ្ងៃ | 1ខែ |
| 132 | កម្ពស់ចាប់ពី ២០១ ស.ម. ឡើងទៅ | មិនអនុញ្ញាត | មិនអនុញ្ញាត | | |

**បញ្ជាក់:**

- តម្លៃសេវាពិនិត្យវត្ថុសិល្បៈនាំចេញទៅបរទេស អនុវត្តចំពោះការនាំចេញវត្ថុសិល្បៈ តាមយន្តហោះ កប៉ាល់ រថយន្ត ឬ ប៉ុស្តិ៍ប្រៃសណីយ៍
- តម្លៃសេវាពិនិត្យវត្ថុសិល្បៈនាំចេញទៅបរទេសមិនអនុវត្តចំពោះភ្ញៀវដែលយកវត្ថុសិល្បៈផលិតថ្មីតាមខ្លួន(យួរដៃ) ប៉ុន្តែតម្រូវឱ្យមានវិក្កយបត្រ (ឈ្មោះហាង លេខទូរស័ព្ទ និងអាសយដ្ឋានទីកន្លែងលក់វត្ថុសិល្បៈ) បង្ហាញដល់អាជ្ញាធរដែលមានសមត្ថកិច្ចត្រួតពិនិត្យ ។

ឧបសម្ព័ន្ធ២ ភ្ជាប់នឹងប្រកាសរួមលេខ.៦៥៧......សហវ.ប្រក ចុះថ្ងៃទី.០៦...... ខែ.មិថុនា...... ឆ្នាំ២០១៦

ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

កម្រងសេវាសាធារណៈដែលអនុវត្តដោយមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានី ខេត្ត

| ល.រ | បរិយាយប្រភេទសេវា | តម្លៃសេវា | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ក. | ការផ្តល់លិខិតអនុញ្ញាត | | | |
| 1 | ការប្រគំតន្ត្រីតាមទីសាធារណៈលក្ខណៈជាតិ | 400 000៛ | 7ថ្ងៃ | 1លើក |
| 2 | ការប្រគំតន្ត្រីតាមទីសាធារណៈលក្ខណៈអន្តរជាតិ | 1 000 000៛ | 7ថ្ងៃ | 1លើក |
| 3 | ការសម្តែងល្ខោនគ្រប់ទម្រង់ | ឥតគិតថ្លៃ | 7ថ្ងៃ | 1លើក |
| ខ. | ការផ្តល់ប័ណ្ណអនុញ្ញាតបើកអាជីវកម្ម | | | |
| 4 | ហាងលក់ជួលកាសែត ស៊ីឌី វីស៊ីឌី ឌីវីឌី | 40 000៛ | 7ថ្ងៃ | 1ឆ្នាំ |
| 5 | អគារលក់ស៊ីឌី វីស៊ីឌី ឌីវីឌី | 100 000៛ | 7ថ្ងៃ | 1ឆ្នាំ |
| 6 | ផ្ទះថតរូប ផ្តិតរូប ថតវីដេអូ | 25 000៛ | 7ថ្ងៃ | 1ឆ្នាំ |
| 7 | អគារផ្តិតរូប ថតរូប ថតវីដេអូ | 100 000៛ | 7ថ្ងៃ | 1ឆ្នាំ |
| 8 | បណ្ណាគារ ដែលមានផ្ទៃក្រឡាក្រោម ៥០ម៉ែត្រការ៉េ | 100 000៛ | 7ថ្ងៃ | 1ឆ្នាំ |
| 9 | បណ្ណាគារ ដែលមានផ្ទៃក្រឡាចាប់ពី ៥០ម៉ែត្រការ៉េឡើងទៅ | 200 000៛ | 7ថ្ងៃ | 1ឆ្នាំ |

| ល.រ | បរិយាយប្រភេទសេវា | តម្លៃសេវា | រយៈពេលអតិបរមា នៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| 10 | ហាងកាត់សក់ ចាប់ពី ២កៅអី ដល់ ៤កៅអី | 20 000៛ | 7ថ្ងៃ | 1ឆ្នាំ |
| 11 | ហាងកាត់សក់ ចាប់ពី ៥កៅអីឡើងទៅ | 40 000៛ | 7ថ្ងៃ | 1ឆ្នាំ |
| 12 | ហាងអ៊ុតសក់ កាត់សក់ លម្អក្រចក ចាប់ពី ២កៅអី ដល់ ៤ កៅអី | 40 000៛ | 7ថ្ងៃ | 1ឆ្នាំ |
| 13 | ហាងអ៊ុតសក់ កាត់សក់ លម្អក្រចក ចាប់ពី ៥កៅអីឡើងទៅ | 60 000៛ | 7ថ្ងៃ | 1ឆ្នាំ |
| 14 | ជាងគំនូរ | 40 000៛ | 7ថ្ងៃ | 1ឆ្នាំ |
| 15 | ផលិតស្លាកសញ្ញា ផ្ទាំងសញ្ញា ផ្ទាំងផ្សាយពាណិជ្ជកម្ម | 100 000៛ | 7ថ្ងៃ | 1ឆ្នាំ |
| 16 | ផលិតលក់ចម្លាក់ពុម្ពស៊ីម៉ង់ត៍ | 100 000៛ | 7ថ្ងៃ | 1ឆ្នាំ |
| 17 | ផលិតលក់ចម្លាក់ម្ទាងសិលា | 100 000៛ | 7ថ្ងៃ | 1ឆ្នាំ |
| 18 | សម្អាងការ (ថ្លៃឈ្នួលក្រោម ៥០០ ដុល្លារអាម៉េរិក) | 100 000៛ | 7ថ្ងៃ | 1ឆ្នាំ |
| 19 | សម្អាងការ (ថ្លៃឈ្នួលចាប់ពី ៥០០ ដុល្លារអាម៉េរិក ដល់ ១ ០០០ ដុល្លារដុល្លារអាម៉េរិក ) | 200 000៛ | 7ថ្ងៃ | 1ឆ្នាំ |
| 20 | សម្អាងការ (ថ្លៃឈ្នួលចាប់ពី ១ ០០០ ដុល្លារអាម៉េរិកឡើងទៅ) | 400 000៛ | 7ថ្ងៃ | 1ឆ្នាំ |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៦២៨........សហវ.ប្រក

# ប្រកាសរួម
## ស្តីពី
## ការផ្តល់រង្វាន់លើកទឹកចិត្ត
## លើការផ្តល់សេវាសាធារណៈរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**រដ្ឋមន្ត្រី**
**ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩២/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៨ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធប្រហាក់ប្រហែល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការគ្រប់គ្រងត្រួតពិនិត្យសិល្បៈភាពយន្ត និងវីដេអូ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលតារាងពន្ធតែមប្រើសារពើពន្ធ
- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញប្រកាសរួមលេខ ៦៥៥ សហវ.ប្រក ចុះថ្ងៃទី.០៦... ខែ.មិថុនា ឆ្នាំ២០១៦ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញប្រកាសលេខ ១៨៩០ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីនីតិវិធីនៃការគ្រប់គ្រងរដ្ឋទេយ្យចំណូលសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- សារាចរណែនាំលេខ ០០១ សហវ.ចមព ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីគោលការណ៍ និងនីតិវិធីផ្តល់រង្វាន់លើកទឹកចិត្តលើការផ្តល់សេវាសាធារណៈ
- យោងតាមការចាំបាច់របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១ .–**

ត្រូវបានផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តជូនក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសម្រាប់ឧបត្ថម្ភជូនមន្ត្រីដែលបំពេញភារកិច្ចផ្ទាល់ និងមន្ត្រីផ្សេងៗទៀត លើការបម្រើសេវាសាធារណៈ ព្រមទាំងសម្រាប់ពង្រឹងយន្តការប្រមូលចំណូល។

**ប្រការ២ .–**

ការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តនេះ ត្រូវបានបែងចែកដាច់ដោយឡែកពីគ្នារវាងរដ្ឋបាលកណ្តាល និងមន្ទីរជំនាញរាជធានី ខេត្ត នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយផ្អែកលើមូលដ្ឋាននៃការបែងចែកភារកិច្ចក្នុងការផ្តល់សេវាសាធារណៈ ដែលអនុវត្តដោយរដ្ឋបាលកណ្តាល និងការផ្តល់សេវាសាធារណៈដែលអនុវត្តដោយមន្ទីរជំនាញរាជធានី ខេត្ត។

**ប្រការ៣ .-**

អនុញ្ញាតឱ្យរដ្ឋបាលកណ្តាលក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានី ខេត្ត កាត់ទុកជាមុននូវចំណែកប្រាក់រង្វាន់ ដោយដកយកពីប្រាក់ចំណូលដែលប្រមូលបានរៀងៗខ្លួន ពីការផ្តល់សេវាសាធារណៈ តាមការកំណត់នៃប្រកាសរួមលេខ ៦៥៥ សហវ.ប្រក ចុះថ្ងៃទី០៦... ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។ ការកាត់ទុកជាមុននូវចំណែកប្រាក់រង្វាន់នេះ ត្រូវបានចាត់ទុកថាថវិកាជាតិបានបើកផ្តល់ជាប្រាក់បុរេប្រទាន សម្រាប់ការចំណាយដូចបានកំណត់នៅក្នុងប្រការ ១ នៃប្រកាសរួមនេះ។ ប្រាក់រង្វាន់ដែលអនុញ្ញាតឱ្យកាត់ទុកជាមុននេះ រួមមានចំណែកប្រាក់រង្វាន់របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងចំណែកប្រាក់រង្វាន់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ៤ .-**

ការផ្តល់ប្រាក់រង្វាន់ជូនក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបានកំណត់ជាសមាមាត្រភាគរយធៀបទៅនឹងប្រាក់ចំណូលប្រមូលបានពីការផ្តល់សេវាសាធារណៈ ដែលមានក្នុងឧបសម្ព័ន្ធ ១ និងឧបសម្ព័ន្ធ ២ នៃប្រកាសរួមលេខ ៦៥៥ សហវ.ប្រក ចុះថ្ងៃទី០៦... ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងត្រូវបានបែងចែក ដូចខាងក្រោម ÷

**ក. ការបែងចែកសម្រាប់រដ្ឋបាលកណ្តាល**

ក១. ចំពោះប្រាក់ចំណូលប្រមូលបានពីការលក់សំបុត្រចូលទស្សនាសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ដែលមានចែងក្នុងឧបសម្ព័ន្ធ ១ ត្រូវបានបែងចែកដូចខាងក្រោម ÷

- បង់ចូលថវិកាជាតិ ១០% នៃចំណូលដែលប្រមូលបាន
- ជូនក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ៨៩% នៃចំណូលដែលប្រមូលបាន
- ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ១% នៃចំណូលដែលប្រមូលបាន។

ក២. ចំពោះប្រាក់ចំណូលប្រមូលបានពីការផ្តល់សេវាសាធារណៈ នៅផ្នែកទី III. ផ្នែកសិល្បៈភាពយន្ត និងផ្សព្វផ្សាយវប្បធម៌ ដែលមានចែងក្នុងឧបសម្ព័ន្ធ ១ ត្រូវបានបែងចែកដូចខាងក្រោម ÷

- បង់ចូលថវិកាជាតិ ៥០% នៃចំណូលដែលប្រមូលបាន
- ជូនក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ៤៩% នៃចំណូលដែលប្រមូលបាន
- ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ១% នៃចំណូលដែលប្រមូលបាន។

ក៣. ចំពោះប្រាក់ចំណូលប្រមូលបានពីការផ្តល់សេវាសាធារណៈ ដែលមានចែងក្នុងឧបសម្ព័ន្ធ ១ លើកលែងការលក់សំបុត្រចូលទស្សនាសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង (ចំណុច ក១) និងផ្នែកទី III. ផ្នែកសិល្បៈភាពយន្ត និងផ្សព្វផ្សាយវប្បធម៌ (ចំណុច ក២) ត្រូវបានបែងចែកដូចខាងក្រោម ÷

- បង់ចូលថវិកាជាតិ ៧០% នៃចំណូលដែលប្រមូលបាន
- ជូនក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ២៩% នៃចំណូលដែលប្រមូលបាន
- ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ១% នៃចំណូលដែលប្រមូលបាន។

**ខ. ការបែងចែកសម្រាប់មន្ទីរជំនាញរាជធានី ខេត្ត**

ចំណូលប្រមូលបានពីការផ្តល់សេវាសាធារណៈ ដែលមានចែងក្នុងឧបសម្ព័ន្ធ២ ត្រូវបានបែងចែកដូចខាងក្រោម ÷

- បង់ចូលថវិកាជាតិ ៧០% នៃចំណូលដែលប្រមូលបាន
- ជូនមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានី ខេត្ត ២៩% នៃចំណូលដែលប្រមូលបាន
- ជូនមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ១% នៃចំណូលដែលប្រមូលបាន។

**ប្រការ៥ .–**

រដ្ឋបាលកណ្តាលក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានី ខេត្ត ត្រូវគ្រោងចំណូល និងចំណាយដែលជាកម្មវត្ថុសម្រាប់ការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត នៅក្នុងគម្រោងចំណូល និងចំណាយនៃថវិកាប្រចាំឆ្នាំរបស់ខ្លួនដោយឡែកពីគ្នា។ រដ្ឋបាលកណ្តាលក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវគ្រោងឥណទានប្រាក់រង្វាន់ ដោយគិតបញ្ចូលរួមទាំងឥណទានសម្រាប់ទូទាត់ការចំណាយលើប្រាក់រង្វាន់របស់រដ្ឋបាលកណ្តាលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានី ខេត្ត ត្រូវគ្រោងឥណទានប្រាក់រង្វាន់ ដោយគិតបញ្ចូលរួមទាំងឥណទានសម្រាប់ទូទាត់ការចំណាយលើប្រាក់រង្វាន់របស់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត។

ឥណទានដែលបានគ្រោងសម្រាប់ការចំណាយលើប្រាក់រង្វាន់នេះ ជាកម្មវត្ថុនៃការធ្វើអាណត្តិបើកប្រាក់ (អាណត្តិនិយ័តកម្ម) ដើម្បីទូទាត់ជាមួយចំនួនទឹកប្រាក់ដែលចាត់ទុកថាបានបុរេប្រទានពីចំណូលថវិកាជាតិ (រង្វាន់ដែលបានកាត់ទុក)។

រាល់ប្រតិបត្តិការនៃចំណូល និងចំណាយទាំងនេះ ត្រូវកត់ត្រាឆ្លុះបញ្ចាំងក្នុងថវិកាជាតិ ដូចប្រតិបត្តិការនៃចំណូល និងចំណាយដទៃទៀតរបស់រដ្ឋបាលកណ្តាលក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានី ខេត្ត ដែរ។

**ប្រការ៦ .–**

ការទូទាត់រង្វាន់លើកទឹកចិត្ត ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម ÷

**ក. ផ្នែកចំណូល**

ធ្វើសលាកប័ត្រចំណូលថវិកាជាតិនូវចំនួនទឹកប្រាក់ដែលបានបុរេប្រទាន និងសំណើសុំកត់ត្រាចំណូល ÷

- **ចំពោះរដ្ឋបាលកណ្តាលក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ :** បញ្ជូនសំណើ និងសលាកប័ត្រចំណូលថវិកាជាតិមកអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ស្ថានភាពស្តីពីការអនុវត្តចំណូល, តារាងសម្រង់សលាកប័ត្រចំណូលថវិកាជាតិ និងប័ណ្ណបង់ប្រាក់, តារាងស្តីពីការគណនាប្រាក់រង្វាន់ និងរបាយការណ៍ស្តីពីការបែងចែកប្រាក់រង្វាន់ដែលបានបើកផ្តល់កន្លងមក។ អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ ត្រូវចេញលិខិតពិនិត្យបញ្ជាក់លើចំនួនទឹកប្រាក់ដែលបានចុះក្នុងសលាកប័ត្រចំណូលថវិកាជាតិ។

- **ចំពោះមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានី ខេត្ត៖** បញ្ជូនសំណើ និងសលាកប័ត្រចំណូលថវិកាជាតិ មកមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ស្ថានភាពស្តីពីការអនុវត្តចំណូល, តារាងសម្រង់សលាកប័ត្រចំណូលថវិកាជាតិ និងប័ណ្ណបង់ប្រាក់, តារាងស្តីពីការគណនាប្រាក់រង្វាន់ និងរបាយការណ៍ស្តីពីការបែងចែកប្រាក់រង្វាន់ដែលបានបើកផ្តល់កន្លងមក។ មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ត្រូវចេញលិខិតពិនិត្យបញ្ជាក់លើចំនួនទឹកប្រាក់ដែលបានចុះក្នុងសលាកប័ត្រចំណូលថវិកាជាតិ។

**ខ. ផ្នែកចំណាយ**

រដ្ឋបាលកណ្តាលក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានី ខេត្ត ត្រូវធ្វើសំណើសុំទូទាត់ចំណាយប្រាក់រង្វាន់លើកទឹកចិត្ត និងធ្វើអាណត្តិបើកប្រាក់ ដោយចុះចំនួនទឹកប្រាក់ស្មើនឹងចំនួនទឹកប្រាក់បុរេប្រទានដែលបានចុះនៅក្នុងសលាកប័ត្រចំណូលថវិកាជាតិ។

**ប្រការ៧ .-**

ការបើកផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត ត្រូវអនុវត្តដូចខាងក្រោម ៖

ក. ការបើកផ្តល់ប្រាក់រង្វាន់ជូនមន្ត្រីរាជការនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដោយឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។

ខ. ការបើកផ្តល់ប្រាក់រង្វាន់ជូនមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។

**ប្រការ៨ .-**

ការផ្តល់អត្រាប្រាក់រង្វាន់លើកទឹកចិត្តជូនក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ អាចកែប្រែបានតាមការចាំបាច់ ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

**ប្រការ៩ .-**

ត្រូវបាននិរាករណ៍ប្រកាសរួមទាំងឡាយដូចខាងក្រោម ៖

- ប្រកាសរួមលេខ ៩៨៨ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់រង្វាន់លើកទឹកចិត្តជូនក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ប្រកាសរួមលេខ ៥២៣ សហវ.ប្រក ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៤ ស្តីពីការផ្តល់រង្វាន់លើកទឹកចិត្តជូនក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើការប្រមូលចំណូលពីការលក់សំបុត្រជូនភ្ញៀវទេសចរចូលទស្សនាសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង។

**ប្រការ១០ .‑**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសរួមនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១១ .‑**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវទទួលបន្ទុកអនុវត្តប្រកាសរួមនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃទី.០៦......ខែ.មិថុនា..ឆ្នាំ២០១៦ តទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី០៦  ខែមិថុនា  ឆ្នាំ២០១៦

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**
**ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ**

**ភឿង-សកុណា**

កន្លែងទទួល ៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- សាលារាជធានី ខេត្ត
- ដូចប្រការ ១១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៦០៦ .........សហវ.ប.ក

# ប្រកាសអន្តរក្រសួង
# ស្តីពី
# ការបង្កើតរង្វាន់ថវិកាប្រចាំឆ្នាំ២០១៦
# របស់អគ្គនាយកដ្ឋានកីឡា

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ន.ស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ន.ស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៦ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញប្រកាសលេខ ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ញាទូទៅ នៃគណនេយ្យសាធារណៈ

(ទំព័រទី១)

- បានឃើញប្រកាសលេខ ១៨៩ សហវ.ប្រក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឲ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ២១១ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ ស្តីពីការដាក់ឲ្យអនុវត្តមាតិកាគណនី នៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- ប្រកាសលេខ ៨២៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួល ប្រការ៤ ប្រការ៥ ប្រការ១៤ ប្រការ១៦ និងប្រការ១៧ នៃប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាម រជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- បានឃើញប្រកាសអន្តរក្រសួងលេខ ១៦២ អយក.ប្រក ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ២០១៥ ស្តីពីការដាក់ឲ្យអនុវត្តអង្គភាពថវិកា
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា

**សម្រេច**

**ប្រការ ១ ៖**

ត្រូវបានបង្កើតរជ្ជទេយ្យបុរេប្រទានជំពូក ៦០ "ការទិញ", ជំពូក៦១ "សេវាកម្ម", ជំពូក ៦២ "អត្ថប្រយោជន៍សង្គម", ជំពូក" ៦៤ "បន្ទុកបុគ្គលិក" ជំពូក៦៥ "ឧបត្ថម្ភធន" នៅអគ្គនាយកដ្ឋានកីឡា នៃក្រសួងអប់រំ យុវជន និងកីឡា សម្រាប់មុខសញ្ញា ចំណាយដូចមានចែងក្នុងប្រការ៥ ថ្មី នៃប្រកាសលេខ ៨២៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួល ប្រការ៤ ប្រការ៥ ប្រការ១៤ ប្រការ១៦ និងប្រការ១៧ នៃប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ ។

តារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន ត្រូវបានកំណត់ជាឧបសម្ព័ន្ធនៃប្រកាសអន្តរក្រសួងនេះ ។

**ប្រការ ២ ៖**

ចំនួនទឹកប្រាក់មួយជុំបង្វិលនៃរជ្ជទេយ្យបុរេប្រទាន ត្រូវកំណត់ដូចក្នុងតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន ។

**ប្រការ ៣ ៖**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៤ ៖**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានកីឡា ប្រធានគ្រប់អង្គភាព ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០១៦

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

**បណ្ឌិត ហង់ ជួន ណារ៉ុន**

**កន្លែងទទួល ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
អគ្គនាយកដ្ឋានកីឡា(កម្មវិធីទី៣)

## តារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទាន
## ថវិកាកម្មវិធីឆ្នាំ២០១៦ របស់អគ្គនាយកដ្ឋានកីឡា

ឯកតាគិតជារៀល

| ជំពូក | គណនី | អនុគណនី | ករណមុខចំណាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០១៦ | ឥណទាន ដែលជ្រើសរើស | ឥណទាន រដ្ឋទេយ្យបុរេប្រទាន | ឥណទាន ទូទាត់ធម្មតា | ឥណទានទទួលបង្វិល រដ្ឋទេយ្យបុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ =២-៣ | ៥ = ៣/៤ជុំ | ៦=៣/២ |
| | | | **សរុប** | **39,884,500,000** | **33,181,200,000** | **7,123,263,600** | **26,057,936,400** | **1,780,815,900** | **21.5%** |
| 60 | | | **ការទិញ** | **6,173,400,000** | **4,755,400,000** | **1,659,843,600** | **3,095,556,400** | **414,960,900** | **34.9%** |
| | 6001 | | **សម្ភារផ្គត់ផ្គង់ថែទាំ** | **154,200,000** | **154,200,000** | **154,200,000** | **-** | **38,550,000** | **100.0%** |
| | | 60011 | សម្ភារផ្គត់ផ្គង់សម្អាតនិងអនាម័យ | 22,200,000 | 22,200,000 | 22,200,000 | - | 5,550,000 | 100.0% |
| | | 60012 | សម្ភារផ្គត់ផ្គង់សម្រាប់ថែទាំអគារ ប្រាសាទ និងសំណង់ផ្សេងៗ | 40,000,000 | 40,000,000 | 40,000,000 | - | 10,000,000 | 100.0% |
| | | 60013 | សម្ភារផ្គត់ផ្គង់សម្រាប់ថែទាំផ្លូវថ្នល់ ស្ពាន និងលូ | 10,000,000 | 10,000,000 | 10,000,000 | - | 2,500,000 | 100.0% |
| | | 60014 | សម្ភារផ្គត់ផ្គង់សម្រាប់ថែទាំសម្ភារឧបករណ៍ | 52,000,000 | 52,000,000 | 52,000,000 | - | 13,000,000 | 100.0% |
| | | 60015 | ប្រេងឥន្ធនៈនិងប្រេងរំអិល | 30,000,000 | 30,000,000 | 30,000,000 | - | 7,500,000 | 100.0% |
| | 6002 | | **សម្ភារផ្គត់ផ្គង់ផ្នែករដ្ឋបាល** | **733,300,000** | **733,300,000** | **239,623,600** | **493,676,400** | **59,905,900** | **32.7%** |
| | | 60021 | សម្ភារការិយាល័យនិងការបោះពុម្ព | 675,300,000 | 675,300,000 | 203,623,600 | 471,676,400 | 50,905,900 | 30.2% |
| | | 60022 | សៀវភៅមើលនិងឯកសារ | 28,000,000 | 28,000,000 | 28,000,000 | - | 7,000,000 | 100.0% |
| | | 60028 | សម្ភារផ្គត់ផ្គង់ផ្នែករដ្ឋបាលផ្សេងៗ | 30,000,000 | 30,000,000 | 8,000,000 | 22,000,000 | 2,000,000 | 26.7% |
| | 6003 | | **ស្បៀងអាហារនិងផលិតផលកសិកម្ម** | **105,600,000** | **105,600,000** | **83,600,000** | **22,000,000** | **20,900,000** | **79.2%** |
| | | 60031 | ស្បៀង | 105,600,000 | 105,600,000 | 83,600,000 | 22,000,000 | 20,900,000 | 79.2% |
| | 6004 | | **សំលៀកបំពាក់និងការតុបតែង** | **214,600,000** | **214,600,000** | **89,600,000** | **125,000,000** | **22,400,000** | **41.8%** |
| | | 60041 | ឯកសណ្ឋាន | **211,600,000** | **211,600,000** | **86,600,000** | **125,000,000** | **21,650,000** | **40.9%** |
| | | 60043 | មេដាយ(គ្រឿងឥស្សរិយយស) | 3,000,000 | 3,000,000 | 3,000,000 | - | 750,000 | 100.0% |
| | 6005 | | **សម្ភារតូចតាច សង្ហារឹម និងសម្ភារបរិក្ខារ** | **3,546,700,000** | **3,522,700,000** | **1,067,820,000** | **2,454,880,000** | **266,955,000** | **30.3%** |
| | | 60051 | សម្ភារនិងបរិក្ខារបច្ចេកទេស | 375,800,000 | 375,800,000 | 61,520,000 | 314,280,000 | 15,380,000 | 16.4% |
| | | 60052 | សង្ហារឹម | 136,000,000 | 136,000,000 | 53,000,000 | 83,000,000 | 13,250,000 | 39.0% |
| | | 60053 | សម្ភារប្រើប្រាស់ | 2,955,900,000 | 2,955,900,000 | 933,300,000 | 2,022,600,000 | 233,325,000 | 31.6% |
| | | 60054 | សម្ភារនិងឧបករណ៍ដឹកជញ្ជូន | 24,000,000 | - | - | 24,000,000 | - | #DIV/0! |
| | | 60058 | សម្ភារតូចតាច សង្ហារឹម និងសម្ភារៈបរិក្ខារផ្សេងៗ | 55,000,000 | 55,000,000 | 20,000,000 | 35,000,000 | 5,000,000 | 36.4% |
| | 6006 | | **ថាមពលនិងទឹក** | **1,394,000,000** | - | - | - | - | #DIV/0! |
| | | 60061 | អគ្គិសនី | 1,046,000,000 | - | - | - | - | #DIV/0! |
| | | 60062 | ទឹក | 348,000,000 | - | - | - | - | #DIV/0! |
| | 6007 | | **សម្ភារបរិក្ខារថែទាំសុខភាព** | **22,000,000** | **22,000,000** | **22,000,000** | **-** | **5,500,000** | **100.0%** |
| | | 60071 | បំពង់ហ្គាសនិងអុកស៊ីសែន | 4,000,000 | 4,000,000 | 4,000,000 | - | 1,000,000 | 100.0% |
| | | 60072 | សម្ភារបរិក្ខារពេទ្យ | 16,000,000 | 16,000,000 | 16,000,000 | - | 4,000,000 | 100.0% |
| | | 60078 | សម្ភារបរិក្ខារថែទាំសុខភាពផ្សេងៗ | 2,000,000 | 2,000,000 | 2,000,000 | - | 500,000 | 100.0% |
| | 6098 | | **សម្ភារផ្គត់ផ្គង់ផ្សេងៗ** | **3,000,000** | **3,000,000** | **3,000,000** | **-** | **750,000** | **100.0%** |
| 61 | | | **សេវាកម្ម** | **12,770,800,000** | **12,424,800,000** | **4,866,120,000** | **7,311,980,000** | **1,216,530,000** | **39.2%** |
| | 6102 | | **ការផ្សព្វផ្សាយដឹកជញ្ជូន** | **80,000,000** | **80,000,000** | **40,000,000** | **40,000,000** | **10,000,000** | **50.0%** |
| | 6104 | | សោហ៊ុយបណ្តុះបណ្តាលបុគ្គលិក ក្នុងនិងក្រៅប្រទេស | **178,000,000** | **178,000,000** | **178,000,000** | **-** | **44,500,000** | **100.0%** |

| ជំពូក | គណនី | អនុគណនី | រាយមុខចំណាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០១៦ | ឥណទាន ដែលជ្រើសរើស | ឥណទាន ផ្ទេរទៅឲ្យបុរេប្រទាន | ឥណទាន ទូទាត់ធម្មតា | ឥណទានខ្ទង់បង្វិល ផ្ទេរទៅឲ្យបុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ =២-៣ | ៥ = ៣/៤ជុំ | ៦=៣/២ |
| | 6105 | | ការថែទាំនិងជួសជុល | 6,813,700,000 | 6,813,700,000 | 573,700,000 | 6,240,000,000 | 143,425,000 | 8.4% |
| | | 61051 | ការថែទាំដីធ្លី សួនច្បារ ព្រៃឈើ តំបន់ឆ្នេរ និងដែននេសាទ | 8,000,000 | 8,000,000 | 8,000,000 | - | 2,000,000 | 100.0% |
| | | 61052 | ការថែទាំ ជួសជុលអគារផ្សេងៗ និងប្រាសាទ | 6,431,700,000 | 6,431,700,000 | 231,700,000 | 6,200,000,000 | 57,925,000 | 3.6% |
| | | 61053 | ការថែទាំនិងជួសជុលផ្លូវ ផ្លូវលំ ស្ពាន និងលូ | 30,000,000 | 30,000,000 | 30,000,000 | - | 7,500,000 | 100.0% |
| | | 61054 | ការថែទាំបណ្ដាញផ្សេងៗ | 99,000,000 | 99,000,000 | 84,000,000 | 15,000,000 | 21,000,000 | 84.8% |
| | | 61056 | ការថែទាំនិងជួសជុលមធ្យោបាយដឹកជញ្ជូន | 100,000,000 | 100,000,000 | 90,000,000 | 10,000,000 | 22,500,000 | 90.0% |
| | | 61057 | ការថែទាំនិងជួសជុលសម្ភារ និងឧបករណ៍បច្ចេកទេស | 105,000,000 | 105,000,000 | 90,000,000 | 15,000,000 | 22,500,000 | 85.7% |
| | | 61058 | ការថែទាំនិងជួសជុលផ្សេងៗ | 40,000,000 | 40,000,000 | 40,000,000 | - | 10,000,000 | 100.0% |
| | 6108 | | សោហ៊ុយដឹកជញ្ជូន | 7,000,000 | 7,000,000 | 7,000,000 | - | 1,750,000 | 100.0% |
| | | 61081 | សម្ភារនិងទំនិញ | 6,000,000 | 6,000,000 | 6,000,000 | - | 1,500,000 | 100.0% |
| | | 61088 | សោហ៊ុយដឹកជញ្ជូនផ្សេងៗ | 1,000,000 | 1,000,000 | 1,000,000 | - | 250,000 | 100.0% |
| | 6109 | | បុគ្គលិកខាងក្រៅ | 346,000,000 | - | - | - | - | #DIV/0! |
| | | 61092 | ភ្នាក់ងារបរទេសជាប់កិច្ចសន្យា | 346,000,000 | - | - | - | - | #DIV/0! |
| | 6110 | | ទំនាក់ទំនងសាធារណៈនិងផ្សព្វផ្សាយ | 516,600,000 | 516,600,000 | 475,600,000 | 41,000,000 | 118,900,000 | 92.1% |
| | | 61101 | សោហ៊ុយទទួលភ្ញៀវជាតិ | 128,000,000 | 128,000,000 | 108,000,000 | 20,000,000 | 27,000,000 | 84.4% |
| | | 61102 | សោហ៊ុយទទួលភ្ញៀវបរទេស | 110,000,000 | 110,000,000 | 95,000,000 | 15,000,000 | 23,750,000 | 86.4% |
| | | 61103 | ប្រជុំ សិក្ខាសាលា និងសន្និសីទ | 217,600,000 | 217,600,000 | 217,600,000 | - | 54,400,000 | 100.0% |
| | | 61104 | ចំណាយរៀបចំពិធីបុណ្យ | 26,000,000 | 26,000,000 | 26,000,000 | - | 6,500,000 | 100.0% |
| | | 61105 | ចំណាយសម្រាប់វត្តអនុស្សាវរីយ៍ នៅក្នុងនិងក្រៅប្រទេស | 29,000,000 | 29,000,000 | 23,000,000 | 6,000,000 | 5,750,000 | 79.3% |
| | | 61107 | ការឃោសនានិងផ្សព្វផ្សាយព័ត៌មានសាធារណៈ | 6,000,000 | 6,000,000 | 6,000,000 | - | 1,500,000 | 100.0% |
| | 6112 | | ចំណាយទូទាត់សោហ៊ុយក្នុងប្រទេស | 2,424,800,000 | 2,424,800,000 | 2,409,800,000 | 15,000,000 | 602,450,000 | 99.4% |
| | | 61121 | សោហ៊ុយដឹកជញ្ជូន | 370,000,000 | 370,000,000 | 355,000,000 | 15,000,000 | 88,750,000 | 95.9% |
| | | 61122 | សោហ៊ុយបេសកកម្ម | 317,300,000 | 317,300,000 | 317,300,000 | - | 79,325,000 | 100.0% |
| | | 61123 | សោហ៊ុយស្នាក់នៅ | 1,737,500,000 | 1,737,500,000 | 1,737,500,000 | - | 434,375,000 | 100.0% |
| | 6113 | | ចំណាយទូទាត់សោហ៊ុយក្រៅប្រទេស | 2,363,000,000 | 2,363,000,000 | 1,152,020,000 | 1,210,980,000 | 288,005,000 | 48.8% |
| | | 61131 | សោហ៊ុយដឹកជញ្ជូន | 700,000,000 | 700,000,000 | 307,000,000 | 393,000,000 | 76,750,000 | 43.9% |
| | | 61132 | សោហ៊ុយបេសកកម្ម | 436,000,000 | 436,000,000 | 266,000,000 | 170,000,000 | 66,500,000 | 61.0% |
| | | 61133 | សោហ៊ុយស្នាក់នៅ | 1,192,000,000 | 1,192,000,000 | 564,020,000 | 627,980,000 | 141,005,000 | 47.3% |
| | | 61138 | ចំណាយទូទាត់សោហ៊ុយក្រៅប្រទេសផ្សេងៗ | 35,000,000 | 35,000,000 | 15,000,000 | 20,000,000 | 3,750,000 | 42.9% |
| | 6114 | | សោហ៊ុយប្រៃសណីយ៍និងទូរគមនាគមន៍ | 26,700,000 | 26,700,000 | 15,000,000 | 11,700,000 | 3,750,000 | 56.2% |
| | | 61141 | សោហ៊ុយប្រៃសណីយ៍ | 4,000,000 | 4,000,000 | 4,000,000 | - | 1,000,000 | 100.0% |
| | | 61142 | សោហ៊ុយទូរគមនាគមន៍ | 22,700,000 | 22,700,000 | 11,000,000 | 11,700,000 | 2,750,000 | 48.5% |
| | 6198 | | សោហ៊ុយនិងសេវាកម្មផ្សេងៗ | 15,000,000 | 15,000,000 | 15,000,000 | - | 3,750,000 | 100.0% |
| **64** | | | **បន្ទុកបុគ្គលិក** | **3,506,300,000** | **111,000,000** | **47,300,000** | **63,700,000** | **11,825,000** | **42.6%** |
| | 6402 | | លាភការនិងប្រាក់បំណាច់ បុគ្គលិកក្របខ័ណ្ឌអចិន្ត្រៃយ៍ | 5,200,000 | - | - | - | - | #DIV/0! |
| | | 64023 | ប្រាក់បំណាច់ម៉ោងបន្ថែម | 5,200,000 | - | - | - | - | #DIV/0! |
| | 6403 | | រង្វាន់និងប្រាក់បំណាច់ផ្សេងៗ | 3,433,600,000 | 111,000,000 | 47,300,000 | 63,700,000 | 11,825,000 | 42.6% |
| | | 64032 | ប្រាក់បំណាច់សម្រាប់ប្រឡង-ប្រឡងប្រជែង | 3,316,600,000 | - | - | - | - | #DIV/0! |
| | | 64033 | រង្វាន់ | 2,000,000 | 2,000,000 | 2,000,000 | - | 500,000 | 100.0% |
| | | 64034 | ប្រាក់បំណាច់បុគ្គលិកអង្គភាពផ្សេងៗ | 48,900,000 | 48,900,000 | 22,000,000 | 26,900,000 | 5,500,000 | 45.0% |

| ជំពូក | គណនី | អនុគណនី | កាយមុខចំណាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០១៦ | ឥណទាន ដែលជ្រើសរើស | ឥណទាន រដ្ឋលេខាធិការប្រទាន | ឥណទាន ទូទាត់ធម្មតា | ឥណទានទជុំបង្វិល រដ្ឋលេខាធិការប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ =២-៣ | ៥ = ៣/៤ជុំ | ៦=៣/២ |
| | | 64036 | ប្រាក់ឧបត្ថម្ភគ្រូនិងសិក្ខាកាម | 14,800,000 | 14,800,000 | 10,000,000 | 4,800,000 | 2,500,000 | 67.6% |
| | | 64038 | ប្រាក់បំណាច់ផ្សេងៗ | 51,300,000 | 45,300,000 | 13,300,000 | 32,000,000 | 3,325,000 | 29.4% |
| | 6405 | | ប្រាក់វិភាជន៍សង្គមសម្រាប់មន្ត្រីរាជការ | 67,500,000 | - | - | - | - | #DIV/0! |
| | | 64051 | មន្ត្រីមានជំងឺ | 42,000,000 | 0 | 0 | 0 | 0 | #DIV/0! |
| | | 64055 | ឧបត្ថម្ភដល់អ្នកសុំឈប់ពីការងារ | 12,000,000 | 0 | 0 | 0 | 0 | #DIV/0! |
| | | 64056 | គ្រោះថ្នាក់ក្នុងការងារនិងទុព្វលភាព | 10,500,000 | 0 | 0 | 0 | 0 | #DIV/0! |
| | | 64058 | ប្រាក់វិភាជន៍សង្គមផ្សេងៗទៀតសម្រាប់មន្ត្រីរាជការ | 3,000,000 | 0 | 0 | 0 | 0 | #DIV/0! |
| | 6498 | | បន្ទុកផ្សេងៗទៀត | | | | | | |
| 62 | | | **អត្ថប្រយោជន៍សង្គម** | **17,284,000,000** | **15,770,000,000** | **500,000,000** | **15,270,000,000** | **125,000,000** | **3.2%** |
| | 6202 | | ជំនួយសង្គមដល់ប្រជាពលរដ្ឋ | 3,470,000,000 | 2,000,000,000 | 40,000,000 | 1,960,000,000 | 10,000,000 | 2.0% |
| | | 62028 | ជំនួយសង្គមផ្សេងៗទៀត | 3,350,000,000 | 3,350,000,000 | 40,000,000 | 3,310,000,000 | 10,000,000 | 1.2% |
| | 6203 | | ឧបត្ថម្ភដល់អង្គភាពដែលមានលក្ខណៈសង្គមនិងវប្បធម៌ | 13,814,000,000 | 13,770,000,000 | 460,000,000 | 13,310,000,000 | 115,000,000 | 3.3% |
| | | 62035 | ឧបត្ថម្ភសហគមន៍កីឡានិងវប្បធម៌ | 13,770,000,000 | 13,770,000,000 | 460,000,000 | 13,310,000,000 | 115,000,000 | 3.3% |
| | | 62038 | ឧបត្ថម្ភដល់អង្គភាពផ្សេងៗទៀត | 44,000,000 | - | - | - | - | #DIV/0! |
| 65 | | | **ឧបត្ថម្ភកធន** | **150,000,000** | **120,000,000** | **50,000,000** | **70,000,000** | **12,500,000** | **41.7%** |
| | 6502 | | ឧបត្ថម្ភកធនដល់រង្គការសាធារណៈ | 40,000,000 | 40,000,000 | 40,000,000 | 0 | 10,000,000 | 100.0% |
| | | 65023 | ឧបត្ថម្ភកធនដល់អង្គភាពដែលមានលក្ខណៈអប់រំ និងកីឡា | 40,000,000 | 40,000,000 | 40,000,000 | 0 | 10,000,000 | 100.0% |
| | 6506 | | វិភាគទានដល់អង្គការអន្តរជាតិនានា | 110,000,000 | 80,000,000 | 10,000,000 | 70,000,000 | 2,500,000 | 12.5% |
| | | 65064 | សហព័ន្ធអន្តរជាតិខាងកីឡាផ្សេងៗ | 110,000,000 | 80,000,000 | 10,000,000 | 70,000,000 | 2,500,000 | 12.5% |

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៦
ជ.អគ្គនាយក
អគ្គនាយកដ្ឋានរតនាគារជាតិ
អគ្គនាយករង

មុិញ បានសុវណ្ណអានិច្ចាសីលា

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី០៧ ខែ មេសា ឆ្នាំ២០១៦
ជ.អគ្គនាយក
នៃអគ្គនាយកដ្ឋានថវិកា
ប្រធានក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ
អមក្រសួងអប់រំ យុវជន និងកីឡា

គីន_កោសល្ល

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី ១៥ ខែមេសា ឆ្នាំ២០១៦
អគ្គនាយកកីឡានិងជាប្រធានកម្មវិធីទី៣

អ៊ុក_សិទ្ធីជាតិ

ភ្នំពេញថ្ងៃទី ១៨ ខែមេសា ឆ្នាំ២០១៦
រដ្ឋលេខាធិការ

គង់ សុខគ្គី

បានឃើញ និងឯកភាព
ថ្ងៃទី ខែ មេសា ឆ្នាំ២០១៦
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

បានឃើញ និងឯកភាព
ថ្ងៃទី ១៦ ខែ មេសា ឆ្នាំ២០១៦
រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

បណ្ឌិត ហង់ ជួន ណារ៉ុន